សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Unisité Royale de Droit et des Sciences Economiques

Royal University of Law and Economic

# សារណាបញ្ចប់ការសិក្សា

# សន្តិកម្មតាមច្បាប់

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: កញ្ញា **ថុង សៀវអាន់**

កញ្ញា **តាំង សូម៉ាលីហ្សា**

ណែនាំដោយ

លោកស្រី **សំណាង ផលដេត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំនិស្សិត **ថុង សៀវអាន់** និង **តាំង សូម៉ាលីហ្សា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ឆ្នាំទី៤ ជំនាន់ទី២៤ ក្រុមL4C6 ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

**យើងខ្ញុំសូមក្រាបប្រណិប័តន៍ និងសម្តែងនូវភាពកតញ្ញូតាធំធ៌ កតវេទី ដ៏ជ្រាលជ្រៅចំពោះ៖**

- អ្នកមានគុណដ៏ធំធេងរបស់ពួកខ្ញុំទាំងពីររូប ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ទូន្មានប្រៀនប្រដៅ ថែរក្សាបានធំដឹងក្តី ព្រមទាំងព្យាយាមអស់ពីកម្លាំងកាយកម្លាំងចិត្ត មិនថាមានភាពហត់នឿយ និងជួបឧបសគ្គនានានោះឡើយ។ លោកតែងតែបានទំនុកបម្រុងពួកខ្ញុំ ទាំងផ្នែកស្មារតី ថវិកា សម្ភារៈប្រើប្រាស់ និងសម្ភារៈសិក្សានានា ដើម្បីឲ្យទទួលបាននូវចំណេះដឹង និងលទ្ធផលល្អក្នុងការសិក្សារហូតមកដល់បច្ចុប្បន្ននេះ។
- **ឯកឧត្តមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រី សាស្រ្តាចារ្យ បុគ្គលិក**នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចគ្រប់ជាន់ថ្នាក់ទាំងអស់។
- លោកស្រី **សំណាង ផលដេត** ដែលជាអនុប្រធានការិយាល័យសិក្សា និងជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះ។ លោកស្រីបានជួយបង្ហាត់បង្រៀន អប់រំ បង្ហាញទិសដៅ និងចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការណែនាំ ពន្យល់ ផ្តល់ជាមតិយោបល់ ព្រមទាំងបទពិសោធន៍ល្អៗ និងកែសម្រួលនូវសារណានេះបញ្ចប់ដោយរលូន។
- **គណៈគ្រប់គ្រង និងបុគ្គលិកនៃបណ្ណាល័យនីតិសាស្រ្ត** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានរៀបចំ និងគ្រប់គ្រងទុកដាក់សៀវភៅ ថែមមទាំងបានបង្កើននូវភាពងាយស្រួលដល់ការសិក្សារបស់សិស្សនិស្សិត នៃសាកលវិទ្យាល័យទាំងមូល។

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីរសូមប្រសិទ្ធិពរជ័យជូនទៅដល់អ្នកមានគុណទាំងឡាយ ព្រមទាំងឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រី សាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសេដ្ឋកិច្ចទាំងអស់ ឲ្យជួបតែសំណាងល្អ និងជោគជ័យគ្រប់ភារកិច្ចក្នុងការបំពេញការងារទាំងអស់ ពិសេសសូមឲ្យជួបតែពុទ្ធពរជ័យទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពេលបានសិក្សាក្នុងថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រក្នុងរយៈបួនឆ្នាំ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក យើងខ្ញុំទទួលបានចំណេះដឹងយ៉ាងអនេក ក្នុងការស្វែងយល់អំពីការស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យច្បាប់ជាពិសេសគឺវិធានគតិយុត្តនៃនីតិរដ្ឋប្បវេណី យើងខ្ញុំចាប់អារម្មណ៍ទៅនឹងគន្ថីទី៨ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ យ៉ាងខ្លាំងទាក់ទងនឹងចំណុចសន្តតិកម្មតាមច្បាប់ ដែលជាផ្នែកមួយនៃនីតិគ្រួសារ។ លើសពីនេះទៅទៀត យើងខ្ញុំក៏បានឃើញអំពីចំណុចស្មុគស្មាញជាច្រើនទៅលើការបែងចែកទ្រព្យសម្បត្តិ នៃសន្តតិកម្មតាមច្បាប់ផងដែរនៃក្រមរដ្ឋប្បវេណី ដោយមិនអាចគ្រាន់តែអានយល់បានទេ ពោលគឺតម្រូវឲ្យមានការសិក្សាទៅលើបទបញ្ញត្តិនីមួយៗ ឲ្យបានច្បាស់លាស់ដែលមានភាពប្រទាក់ក្រឡាគ្នាទើបយល់ច្បាស់។ ម៉្យាងទៀត យើងខ្ញុំសង្កេតឃើញថាស្ថានភាពនៃការបែងចែកទ្រព្យសម្បត្តិនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន គឺមានភាពស្មុគស្មាញ ហើយបង្កជាទំនាស់ពាក់ព័ន្ធនឹងចំណែកមត៌ក ទើបយើងខ្ញុំមានឱកាស និងទទួលបានសិទ្ធិក្នុងការសរសេរ និងចងក្រងសារណាបញ្ចប់ការសិក្សាបានលើកយកប្រធានបទដែលទាក់ទងទៅនឹង "**សន្តតិកម្មតាមច្បាប់**" នេះឡើងមកធ្វើការបកស្រាយ ក្នុងគោលបំណងជាកិច្ចបញ្ចប់នៃកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ និងជាចំណងឯកសារចងក្រងទុកជាផលប្រយោជន៍ដល់និស្សិតជំនាន់ក្រោយដែលមានគោលបំណងក្នុងការស្រាវជ្រាវលើប្រធានបទសន្តតិកម្មតាមច្បាប់នេះ ព្រមទាំងទុកជាចំណេះដឹងដល់ប្រជាពលរដ្ឋទូទៅជាការបំពេញវិជ្ជាជាដើម។ បន្ថែមពីនេះ កិច្ចការស្រាវជ្រាវនៃប្រធានបទនេះ យើងខ្ញុំបានប្រើប្រាស់ពាក្យងាយយល់យកមកបកស្រាយ ដើម្បីឲ្យអ្នកអានងាយយល់នៃចំណុចសំខាន់របស់ប្រធានបទនេះ។ យើងខ្ញុំបានប្រឹងប្រែងស្វែងរកឯកសារដែលពាក់ព័ន្ធអស់ពីកម្លាំងកាយចិត្ត តែមិនមានន័យថាកិច្ចការនេះល្អឥតខ្ចោះនោះទេ។ នេះគ្រាន់តែសបញ្ជាក់ពីស្នាដៃ ឆន្ទៈ ព្រមទាំងចំណេះដឹងក្នុងការសិក្សារយៈបួនឆ្នាំកន្លងមកនេះប៉ុណ្ណោះ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីររូបសង្ឃឹមយ៉ាងមុះមុតថា ការសិក្សាស្រាវជ្រាវពីសន្តតិកម្មតាមច្បាប់ពិតជាបានចូលរួមចំណែកដល់ការចែករំលែកចំណេះដឹងដល់និស្សិតគ្រប់រូប និងប្រជាពលរដ្ឋទូទៅដែលមានគោលបំណងក្នុងការពង្រីកចំណេះដឹងនៃការសិក្សាស្វែងយល់បន្ថែម ក៏ដូចជាកាត់បន្ថយនូវវិវាទនៅក្នុងសង្គមបានច្រើន។ ទោះជាយ៉ាងណាក៏ដោយរាល់ការស្រាវជ្រាវតែងតែមានកង្វះខាតនានាដែលយើងខ្ញុំមានការខ្វះខាតត្រង់ចំណុចណាមួយដោយមិន បានវិភាគគ្រប់ជ្រុងជ្រោយនោះទេ ព្រោះការស្រាវជ្រាវមានដែនកំណត់ ហើយយើងខ្ញុំសង្ឃឹមថានឹងទទួលបានការរិះគន់ចាំបាច់នៅក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ និងសិស្សនិស្សិតដែលសិក្សាស្រាវជ្រាវបន្តដើម្បីធ្វើការកែតម្រូវនូវចំណុចខ្វះខាតទាំងអស់នោះ។ យើងខ្ញុំសូមអភ័យទោសនូវរាល់កំហុសឆ្គងពាក្យពេចន៍ អក្ខរាវិរុទ្ធមួយចំនួន ឬរាល់ចំណុចខ្វះខាតទាំងឡាយណាដែលបាន កើតមានឡើងដោយចេតនាក្តី និងអចេតនាក្តី សូមអ្នកអានទាំងអស់មេត្តាអធ្យាស្រ័យ។ យើងខ្ញុំក៏សូមធានាថាកិច្ចការស្រាវជ្រាវមួយនេះដែលបានតាក់តែងឡើងនេះ គឺពុំបានចម្លងពីស្នាដៃរបស់បុគ្គលមួយរូបណាឡើយ។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ២
៣. គោលបំណងនៃការស្រាវជ្រាវ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ៣
៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ៣
៦. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៤


## ជំពូកទី១
## សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់


១.១ ការកំណត់ពីខ្លឹមសារនៃសន្តតិកម្មតាមច្បាប់ ៥
១.១.១ សញ្ញាណគតិយុត្តដែលពាក់ព័ន្ធ ៥
១.១.១.១ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ៦
១.១.១.២ ច្បាប់ភូមិបាល ឆ្នាំ២០០១ ៦
១.១.១.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ៧
១.១.២ និយមន័យនៃសន្តតិកម្មតាមច្បាប់ ៨
១.១.៣ ចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់ ៩
១.២ ការកំណត់សន្តតិជន ១០
១.២.១ ភាពគ្រប់លក្ខណៈសម្បត្តិនៃសន្តតិជន ១០
១.២.១.១ អ្នកដែលមានសិទ្ធិទទួលសន្តតិកម្ម ១០
ក. ជនមានជីវិត ១០
ខ. ទារកក្នុងគភ៌ ១៥
១.២.១.២ អ្នកដែលគ្មានសិទ្ធិទទួលសន្តតិកម្ម ១៥
ក. អភ័ព្វបុគ្គល ១៦
ខ. ជនដែលត្រូវបានផ្តាច់ចេញពីមត៌ក ១៦
១.២.២ លំដាប់នៃសន្តតិជនក្នុងការទទួលបានសន្តតិកម្ម ១៧
១.២.២.១ សន្តតិជនលំដាប់ទី១ និងសន្តតិជនជំនួស ១៧

១.២.២.២ សន្តតិជនលំដាប់ទី២ ១៩
១.២.២.៣ សន្តតិជនលំដាប់ទី៣ និងសន្តតិជនជំនួស ១៩
១.២.២.៤ សន្តតិជនជានិច្ច ២០
១.៣ អានុភាពនៃសន្តតិកម្មតាមច្បាប់ ២១
១.៣.១ ពេលវេលាបើកសន្តតិកម្មតាមច្បាប់ ២១
១.៣.១.១ មរណភាពនៃមតកជន ២១
១.៣.១.២ ការបាត់ខ្លួននៃមតកជន ២២
១.៣.២. ទីកន្លែងបើកសន្តតិកម្មតាមច្បាប់ ២៣

## ជំពូកទី២

## នីតិវិធីមុនការទទួលសន្តតិកម្មតាមច្បាប់

២.១ ការអនុវត្តសិទ្ធិរបស់សន្តតិជនក្នុងសន្តតិកម្ម ២៤
២.១.១ ការយល់ព្រម និងការបោះបង់សន្តតិកម្ម ២៤
២.១.១.១ ការយល់ព្រមទទួលយកសន្តតិកម្ម ២៥
ក. ការទទួលយកទាំងស្រុង ២៦
ខ. ការទទួលយកមានកម្រិត ២៧
២.១.១.២ ការបោះបង់ចោលសន្តតិកម្ម ២៩
២.១.២ ការលុបចោលការយល់ព្រម ឬការបោះបង់សន្តតិកម្ម ៣០
២.១.២.១ មូលហេតុនៃការលុបចោលការយល់ព្រម ឬការបោះបង់សន្តតិកម្ម ៣០
២.១.២.២ រយៈពេលនៃការលុបចោលការយល់ព្រម ឬការបោះបង់សន្តតិកម្ម ៣០
២.២ របបនៃការគ្រប់គ្រង និងការបែងចែកមត៌កតាមច្បាប់ ៣១
២.២.១ ការគ្រប់គ្រងមត៌ក ៣១
២.២.១.១ ការគ្រប់គ្រងមត៌កដោយសន្តតិជន ៣២
២.២.១.២ ការគ្រប់គ្រងមត៌កដោយអ្នកប្រតិបត្តិមតកសាសន៍ ៣២
២.២.១.៣ ការគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ៣៣
២.២.២ ការបែងចែកមត៌ក ៣៣
២.២.២.១ ការបែងចែកតាមការពិភាក្សា ៣៣

២.២.២.២ ការបែងចែកតាមផ្លូវតុលាការ ៣៥
២.២.២.៣ អានុភាពនៃការបែងចែក ៣៦
២.២.៣ ការសម្រួលរវាងម្ចាស់បំណុល ៣៩

## ជំពូកទី៣
## នីតិវិធីក្នុងការទទួលចំណែកមត៌ក

៣.១ ការកំណត់អំពីចំណែកមត៌ក ៤១
៣.១.១ ចំណែកដែលសន្តតិជនទទួលបាន ៤១
៣.១.១.១ ករណីគ្មានសហព័ទ្ធ ៤១
ក. បច្ឆាញាតិ ៤១
ខ. បុព្វញាតិ ៤៣
គ. សាខាញាតិ ៤៤
៣.១.១.២ ករណីមានតែសហព័ទ្ធ ៤៥
៣.១.១.៣ ទំនាក់ទំនងរវាងសហព័ទ្ធ និងសន្តតិជនជាញាតិលោហិត ៤៦
ក. សហព័ទ្ធ និងបច្ឆាញាតិ ៤៦
ខ. សហព័ទ្ធ និងបុព្វញាតិ ៤៧
គ. សហព័ទ្ធ និងសាខាញាតិ ៤៩
៣.១.២ ចំណែកមត៌កជាក់ស្តែង ៥០
៣.១.២.១ ករណីទទួលបានផលប្រយោជន៍ពិសេស ៥០
ក. ករណីចំណែកមត៌កច្រើនជាងផលប្រយោជន៍ពិសេស ៥១
ខ. ករណីចំណែកមត៌ក និងផលប្រយោជន៍ពិសេសមានចំនួនស្មើគ្នា ៥២
គ. ករណីចំណែកមត៌កតិចជាងផលប្រយោជន៍ពិសេស ៥៣
៣.១.២.២ ករណីមានភាគនៃវិភាគទាន ៥៤
៣.១.២.៣ ករណីមានភាគនៃវិភាគទាន និងផលប្រយោជន៍ពិសេសក្នុងពេលតែមួយ ៥៧
៣.១.២.៤ ករណីមានប្រទានកម្ម ៥៨
៣.២ អំពីស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់ ៥៩
៣.២.១ នត្ថិភាពនៃសន្តតិជន ៥៩

៣.២.១.១ មត៌កជានីតិបុគ្គល ៥៩
ក. ការជ្រើសតាំងអ្នកគ្រប់គ្រង ៦០
ខ. ការជូនដំណឹងជាសាធារណៈ ៦១
៣.២.១.២ ជនដែលមាននិស្ស័យពិសេស ៦២
៣.២.១.៣ មត៌កដែលក្លាយជារបស់រដ្ឋ ៦៣
៣.២.២ ការធ្វើបដិទាននៃសន្តតិកម្ម ៦៣
**សេចក្តីសន្និដ្ឋាន** ៦៦
**អនុសាសន៍** ៦៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

មជ្ឈដ្ឋានភាគច្រើនអាចស្គាល់ពីកេរអាកររបស់ដូនតា ដែលបានបន្សល់ទុកឲ្យកូនចៅជំនាន់ក្រោយ ប៉ុន្តែពួកគាត់ មិនស្គាល់ថាកេរអាករនោះថាជាអ្វីឲ្យពិតប្រាកដនោះទេ។ ជាការពិតណាស់ គ្រប់មជ្ឈដ្ឋានទូទៅស្គាល់តែពាក្យ ទ្រព្យ កេរអាករ និងកេរ្តិ៍ដំណែល។ រីឯទំនាក់ទំនងសិទ្ធិ និងទ្រព្យរបស់មនុស្សកំពុងនៅមានជីវិតគេហៅថា កម្មសិទ្ធិ ចំណែកឯទ្រព្យរបស់មនុស្សដែលបានបាត់បង់ជីវិតទៅហើយ ត្រូវប្រែក្លាយពីកម្មសិទ្ធិនោះមកហៅថាជាមត៌កវិញ។ ការផ្លាស់ប្តូរ ឬការផ្ទេរកម្មសិទ្ធិរវាងមនុស្សនៅរស់ អាចធ្វើក្រោមរូបភាពដូចជា ការលក់ ការដូរ ប្រទានកម្ម ឬអំណោយជាដើម។ ផ្ទុយទៅវិញនោះ ការផ្ទេរមត៌ករបស់អ្នកស្លាប់មកឲ្យមនុស្សនៅរស់ត្រូវធ្វើតាមរយៈអច្ច័យទាន ឬតាមសន្តតិកម្ម។ សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជន (អ្នកស្លាប់) មកឲ្យអ្នកដែលនៅរស់ដែលត្រូវជាសន្តតិជនម្នាក់ ឬច្រើននាក់ តាមរយៈឆន្ទៈរបស់មតកជន ឬតាមច្បាប់។[1]

សន្តតិកម្មត្រូវបានបែងចែកជាពីរគឺ សន្តតិកម្មតាមមតកសាសន៍ ឬសន្តតិកម្មមានបណ្តាំ និងសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មឥតបណ្តាំ។ ចំពោះសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មឥតបណ្តាំ គឺជាការចាត់ចែងទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុរបស់សន្តតិកម្ម ហើយច្បាប់ជាអ្នកកំណត់ឲ្យទៅសាច់ញាតិដែលជាញាតិលោហិត របស់មតកជនម្នាក់ ឬច្រើននាក់ទទួលបន្តនូវកម្មសិទ្ធិ និងករណីយកិច្ចរបស់មតកជន។ បន្ថែមពីនេះ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គន្ថីទី៨ បានបញ្ញត្តិកំណត់អំពីសន្តតិកម្ម។ លើសពីនេះ ក៏មាននូវសញ្ញាណគតិយុត្តដែលពាក់ព័ន្ធមួយចំនួន ដូចជារដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងច្បាប់ភូមិបាលឆ្នាំ២០០១ផងដែរ។ សន្តតិកម្មតាមច្បាប់មានអនុភាព នៅពេលមតកជនមិនបានបន្សល់ទុកនូវបណ្តាំ ឬមតកសាសន៍មុនពេលខ្លួនទទួលមរណភាព ឬសន្មតថាបានស្លាប់ ឬក៏មតកសាសន៍បានធ្វើឡើង ប៉ុន្តែផ្ទុយពីបញ្ញត្តិច្បាប់បានកំណត់។

ក្នុងការអនុវត្តសន្តតិកម្មតាមច្បាប់គឺ មានការដោះស្រាយដោយការពិភាក្សាក្នុងការចែកមត៌ក ដែលការពិភាក្សានេះធ្វើឡើងក្រៅប្រព័ន្ធតុលាការ ដោយសហសន្តតិជនដែលបានទទួលចំណែកមត៌ក និងការបែងចែកដោយតុលាការឲ្យអនុវត្ត តាមនីតិវិធីក្នុងការដែលសហសន្តតិជនមិនអាចធ្វើការពិភាក្សាត្រូវគ្នាបាន។ ក្នុងការទទួលបានសិទ្ធិនៃការបែងចែងមត៌ករបស់មតកជន គឺមានតែសន្តតិជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប៉ុណ្ណោះទើបមានសិទ្ធិទទួល ចំពោះអភ័ព្វបុគ្គល និងជនដែលត្រូវបានផ្តាច់ចេញពីមត៌កមិនអាចក្លាយជាសន្តតិជនបានទេ។ ការធ្វើការបែងចែកមត៌ក ដែលសហសន្តតិជនបានចាត់ចែង គឺធ្វើឡើងពេលចាប់ផ្តើមសន្តតិកម្ម។

[1] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, , សន្ធានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២១, លេខ ១៤៣ (ពីពេលនេះតទៅហៅថា ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧)។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

សន្តតិកម្មតាមច្បាប់ បង្កើតឡើងជាជម្រើសក្នុងការការពារមត៌ករបស់មតកជន ដែលបានទទួលមរណភាពដោយមិនបន្សល់ទុកមតកសាសន៍ កុំឲ្យមត៌ករបស់មតកជនក្លាយជាគ្មានម្ចាស់ ថែមទាំងការពារដល់ផលប្រយោជន៍របស់សន្តតិជន ឬម្ចាស់បំណុល។ ប្រទេសកម្ពុជាមានការកើនឡើងនៃការស្លាប់របស់មតកជន ដោយមិនបន្សល់ទុកបណ្តាំមត៌ក ក៏ព្រោះតែពួកគាត់យល់ថាការធ្វើមតកសាសន៍ ឬបណ្តាំមត៌ក គឺដូចជាការអបមង្គលក្នុងការប្រមាថដល់ជីវិតខ្លួន។ ចំណោទបញ្ហាកើតមានជាច្រើននៅពេលសន្តតិកម្មតាមច្បាប់កើតឡើង ព្រមទាំងត្រូវការដំណោះស្រាយឆ្លើយតបនឹងចំណោទបញ្ហានោះរួមមាន៖

- តើសន្តតិជនមានលក្ខណៈសម្បត្តិដូចម្តេចខ្លះ ដើម្បីទទួលបានចំណែកមត៌កពីមតកជន?
- តើនីតិវិធីមុនការទទួលបានសន្តតិកម្មតាមច្បាប់ ត្រូវធ្វើឡើងយ៉ាងដូចម្តេច?
- តើសន្តតិជនទទួលបាននូវចំណែកមត៌កតាមច្បាប់ដូចម្តេចពីមតកជន?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវប្រធានបទ "សន្តតិកម្មតាមច្បាប់" យើងសង្ឃឹមថា បានបង្ហាញពីសង្គមទាំងមូលឲ្យមានការយល់ដឹងកាន់តែច្បាស់ពីគោលបំណងនៃប្រធានបទនេះ ដែលគោលបំណងទាំងនោះរួមមាន៖

- បង្ហាញពីសញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់
- បង្ហាញពីចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់
- បង្ហាញពីការកំណត់នូវសន្តតិជន និងភាពគ្រប់លក្ខណៈសម្បត្តិនៃសន្តតិជន
- បង្ហាញពីលំដាប់នីមួយៗនៃសន្តតិជន ក្នុងការទទួលបានសន្តតិកម្មតាមច្បាប់
- បង្ហាញពីអានុភាពនៃសន្តតិកម្ម
- បង្ហាញពីសិទ្ធិរបស់សន្តតិជនក្នុងការយល់ព្រម និងបោះបង់សន្តតិកម្ម
- បង្ហាញពីរបបនៃការគ្រប់គ្រង និងការបែងចែកមត៌កតាមច្បាប់
- បង្ហាញពីការសម្រួលក្នុងករណីមានម្ចាស់បំណុល
- បង្ហាញពីការកំណត់នៃចំណែកមត៌កដែលសន្តតិជនត្រូវទទួលបាន
- បង្ហាញពីស្ថានភាពមាននត្ថិភាពនៃសន្តតិកម្ម
- បង្ហាញពីការធ្វើបដិទាននៃសន្តតិកម្ម
- បង្ហាញពីចំណេះដឹងផ្លូវច្បាប់ និងឆ្លើយតបនូវស្ថានភាពដែលបានកើតឡើងក្នុងទិដ្ឋភាព ក្នុងករណីដែលបុគ្គលណាម្នាក់បានទទួលមរណភាពហើយមិនបានបន្សល់ទុកបណ្តាំ

- បង្ហាញពីសិទ្ធិនៃជនជាសន្តតិជន ក្នុងការទាមទារចំណែកមត៌កតាមចំនួនដែលខ្លួនទទួលបាន
- ដើម្បីជាការចងក្រងទុកជាឯកសារសម្រាប់និស្សិតច្បាប់ ក៏ដូចជាប្រជាជនទូទៅក្នុងការសិក្សាស្វែងយល់ ឬយល់ដឹងបន្ថែម។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

មុននឹងធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ពួកយើងបានខិតខំធ្វើការស្រាវជ្រាវយ៉ាងលម្អិត ទៅលើក្រមរដ្ឋប្បវេណី ដោយហេតុថាក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងពីសន្តតិកម្ម ហើយសន្តតិកម្មបានបែងចែកជា ២ ប្រភេទគឺសន្តតិកម្មតាមមតកសាសន៍ និងសន្តតិកម្មតាមច្បាប់។ សន្តតិកម្មទាំងពីរនេះផងដែរ មានវិសាលភាពយ៉ាងធំទៅលើស្ថានភាពច្រើនប្រភេទផ្សេងៗពីគ្នា។ ហេតុដូចនេះហើយ ទើបយើងសម្រេចជ្រើសយកប្រធាននេះដែលជា "សន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មគ្មានមតកសាសន៍" មកធ្វើជាអត្ថបទសារណានេះយកមកបង្ហាញ ព្រមទាំងបានលើកយកច្បាប់ដែលពាក់ព័ន្ធរួមមាន រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ច្បាប់ភូមិបាលឆ្នាំ២០០១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ និងច្បាប់ដែលពាក់ព័ន្ធមួយចំនួនបន្ថែម លើសពីនេះក៏រួមបញ្ចូលនូវចំណេះដឹងដែលទទួលបានពីសាស្ត្រាចារ្យ មេធាវី និងរៀមច្បងក្នុងការបង្កើតនូវកិច្ចការសារណានេះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ក្នុងនាមជានិស្សិតផ្នែកនីតិសាស្ត្រ ដែលបានលើកយកប្រធានបទ "សន្តតិកម្មតាមច្បាប់" យកមកបកស្រាយឲ្យកាន់តែច្បាស់ ដោយផ្អែកទៅលើឯកសារច្បាប់ជាផ្លូវការយកមកស្រាវជ្រាវ ដើម្បីជាប្រយោជន៍យ៉ាងសំខាន់ដល់និស្សិតដែលសិក្សាផ្នែកច្បាប់ និងប្រើប្រាស់នូវពាក្យងាយយល់សម្រាប់ប្រជាពលរដ្ឋទូទៅដែលចង់ស្វែងយល់នូវចំណេះដឹងបន្ថែមដូចជា យល់ដឹងពីការចាត់ចែងទ្រព្យសម្បត្តិ របស់ជនដែលបានទទួលមរណភាពថាត្រូវបែងចែករបៀបណា? តើតុលាការនៅទីកន្លែងណាមានសមត្ថកិច្ចក្នុងការចាត់ចែងមត៌ក? តើនរណាខ្លះអាចទទួលបានចំណែកមត៌កពីមតកជន? ក្នុងករណីដែលខ្លួនជាសន្តតិជននៅក្នុងលំដាប់ណាមួយហើយ ប៉ុន្តែមិនទទួលបានមត៌ក ក្នុងករណីនេះតើជននោះត្រូវធ្វើរបៀបណា? តើត្រូវមានលក្ខណៈសម្បត្តិជាសន្តតិជនដូចម្តេចខ្លះដើម្បីអាចទទួលបានមត៌កពីមតកជនស្របទៅតាមច្បាប់?

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ក្នុងការស្រាវជ្រាវប្រធានបទសន្តតិកម្មតាមច្បាប់នេះ ពួកយើងបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងស៊ីជម្រៅព្រមទាំងបានស្វែងរកនូវឯកសារ ដែលពាក់ព័ន្ធក្នុងប្រធានបទនេះពីច្បាប់ និងបទដ្ឋានគតិយុត្តសំខាន់ៗនានាដែលបានចែងជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ពីក្នុងបណ្ណាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីសៀវភៅមេរៀនដែលពួកយើងបានសិក្សារយៈពេល៤ឆ្នាំ និងតាមរយៈប្រព័ន្ធ

អ៊ីនធើណេត ព្រមជាមួយនឹងការពន្យល់ណែនាំពីសាស្ត្រាចារ្យថែមទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវប្រធានសន្តតិកម្មតាមច្បាប់ ពួកយើងបានធ្វើការបែងចែកខ្លឹមសារទាំងនោះជា បីជំពូកធំៗ ដើម្បីលើកយកមកធ្វើការបកស្រាយឲ្យកាន់តែមានអត្ថន័យច្បាស់លាស់ និងមានខ្លឹមសារក្បោះក្បាយ ដែលជំពូកទាំងបីនោះរួមមាន៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់**

**ជំពូកទី២៖ នីតិវិធីមុនការទទួលសន្តតិកម្មតាមច្បាប់**

**ជំពូកទី៣៖ នីតិវិធីក្នុងការទទួលចំណែកមត៌ក**

# ជំពូកទី១
# សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

# ជំពូកទី១
# សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

ដើម្បីស្វែងយល់ពីសន្តតិកម្មតាមច្បាប់ឲ្យកាន់តែមានអត្ថន័យក្បោះក្បាយ និងស៊ីជម្រៅបន្ថែមទៀតនោះ យើងគប្បីសិក្សាពីបទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធ និយមន័យ ជាមួយចរិតលក្ខណៈនៃសន្តតិកម្ម រួមទាំងលក្ខណៈនៃសន្តតិជន និងសន្តតិជនដែលច្បាប់បានកំណត់ ព្រមទាំងពេលវេលា និងទីកន្លែងបើកសន្តតិកម្មតាមច្បាប់។ ដោយចំណុចទាំងនេះនឹងត្រូវលើកយកមកបកស្រាយនៅក្នុងជំពូកទី១នេះ ដោយបានបែងចែកជា៣ផ្នែកធំៗ ដែលក្នុងនោះមានដូចជា ការកំណត់ពីខ្លឹមសារនៃសន្តតិកម្មតាមច្បាប់ (១.១) សញ្ញាណនៃសន្តតិជន (១.២) និងអានុភាពនៃសន្តតិកម្មតាមច្បាប់ (១.៣)។

## ១.១ ការកំណត់ពីខ្លឹមសារនៃសន្តតិកម្មតាមច្បាប់

ដើម្បីធ្វើការស្វែងយល់ពីខ្លឹមសារនៃសន្តតិកម្មតាមច្បាប់ឲ្យកាន់តែច្បាស់ ងាយយល់ និងកាន់តែមានអត្ថន័យទៀតនោះ យើងត្រូវយល់ពីសញ្ញាណគតិយុត្តមួយចំនួនដែលពាក់ព័ន្ធ និងនិយមន័យនៃសន្តតិកម្មតាមច្បាប់ រួមនឹងចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់ជាមុនសិន។ ដោយផ្នែកទាំងនេះ យើងនឹងលើកមកបកស្រាយជាចំណុចដូចជា សញ្ញាណគតិយុត្តដែលពាក់ព័ន្ធ (១.១.១) និយមន័យនៃសន្តតិកម្មតាមច្បាប់ (១.១.២) ព្រមទាំងចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់ (១.១.៣)។

### ១.១.១ សញ្ញាណគតិយុត្តដែលពាក់ព័ន្ធ

យោងទៅតាមបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជាយើងសង្កេតឃើញថា ច្បាប់ និងវិធានគតិយុត្តនានាមានច្រើន និងមានលក្ខណៈទូលំទូលាយដែលត្រូវបានចងក្រង និងតាក់តែងឡើងយ៉ាងល្អិតល្អន់ និងហ្មត់ចត់ដោយក្រុមប្រឹក្សាអ្នកច្បាប់ជាច្រើនរូប។ សមិទ្ធផលទាំងនេះផងដែរ បានបង្កើតជាថ្នូរសម្រាប់គ្រប់គ្រងលើវិស័យទាំងអស់នៃសង្គមជាតិ ពិសេសបានចូលរួមលើកស្ទួយដល់គ្រប់វិស័យទាំងមូលនៃប្រទេសជាតិ។ ដោយឡែក យើងឃើញថាមានបទដ្ឋានគតិយុត្តមួយចំនួនមានការចូលរួមពាក់ព័ន្ធ និងដោះស្រាយរាល់វិវាទទាំងឡាយដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិ កេរមត៌ក និងសិទ្ធិកម្មសិទ្ធិនៃរូបវន្តបុគ្គលនីមួយៗ។ ទាក់ទងនឹងបទដ្ឋានគតិយុត្តទាំងនោះរួមមានៈ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។ បទដ្ឋានគតិយុត្តទាំងនេះយើងនឹងធ្វើការបកស្រាយនៅក្នុងចំណុចខាងក្រោមៈ

### ១.១.១.១ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ហេតុដូចនេះ រាល់ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋដែលពាក់ព័ន្ធត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ផ្ទុយទៅវិញ បទដ្ឋានគតិយុត្តទាំងនោះនឹងចាត់ទុកជាអធម្មនុញ្ញភាព ប្រសិនបើមិនស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋធម្មនុញ្ញមានចែងអំពីប្រជាធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជាជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ[2] នេះបានបង្ហាញពីភាពឯករាជ្យនៅក្នុងសង្គម ភាពស្មើគ្នាក្នុងការរស់នៅពោរពេញដោយសន្តិភាព និងភាពស្មើគ្នាចំពោះមុខច្បាប់។ បន្ថែមពីនេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប ដែលសិទ្ធិ និងករណីយកិច្ចទាំងនេះរួមបញ្ចូលទាំងសិទ្ធិទទួលបានសន្តតិកម្មតាមច្បាប់ផងដែរ ដោយបានឆ្លុះបង្ហាញពីភាពស្មើគ្នាចំពោះមុខច្បាប់ ភាពមានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយមិនមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ឬស្ថានភាពនានាឡើយ។ ប៉ុន្តែ ការប្រើប្រាស់សិទ្ធិសេរីភាព និងករណីយកិច្ចនីមួយៗនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌដែលកំណត់នៅក្នុងច្បាប់។[3] លើសពីនេះទៅទៀត ច្បាប់នេះក៏បានចែងអំពីសិទ្ធិជាម្ចាស់កម្មសិទ្ធិ ហើយចំពោះសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី គឺមានតែរូបវន្តបុគ្គល ឬនីតិបុគ្គលមានសញ្ជាតិជាខ្មែរតែប៉ុណ្ណោះ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លីដែលជាអចលនវត្ថុនោះបាន។[4]

### ១.១.១.២ ច្បាប់ភូមិបាល ឆ្នាំ២០០១

ក្រៅពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងបញ្ញត្តិទាក់ទងនឹងសិទ្ធិ កម្មសិទ្ធិ និងករណីយកិច្ចរបស់បុគ្គលគ្រប់រូបក្នុងការគោរពសិទ្ធិ និងទទួលស្គាល់នូវកម្មសិទ្ធិឯកជនលើអចលនវត្ថុ(ដីធ្លី) ក៏មាននូវច្បាប់មួយផ្សេងទៀតផងដែរ ដែលបានចែងពាក់ព័ន្ធនឹងកម្មសិទ្ធិ ដែលមានការតភ្ជាប់នឹងប្រធានបទស្រាវជ្រាវខាងលើនេះផងដែរ នោះគឺច្បាប់ភូមិបាល។ យើងដឹងហើយថា ច្បាប់ភូមិបាល ឆ្នាំ២០០១នៃព្រះរាជាណាចក្រកម្ពុជា ជាច្បាប់ដែលមានគោលបំណងកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា។[5]

[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា ១ កថាខណ្ឌទី ២ (ពីពេលនេះតទៅហៅថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣) ។

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា ៣១ កថាខណ្ឌទី ២។

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា ៤៤ កថាខណ្ឌទី ១។

[5] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា ១ (ពីពេលនេះតទៅហៅថា ច្បាប់ភូមិបាលឆ្នាំ២០០១) ។

ក្រៅពីនេះ ច្បាប់នេះបានចែងពីកាតព្វកិច្ចរបស់ជនគ្រប់រូបត្រូវតែគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ[6] និងបានបង្ហាញពីកម្មសិទ្ធិលើដីធ្លីនៃព្រះរាជាណាចក្រកម្ពុជា ថាមានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបបានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។[7] បន្ថែមពីនេះ លទ្ធកម្មដោយសន្តតិកម្មអាចផ្ទេរតាមរយៈសន្តតិកម្មគតបណ្តាំ សន្តតិកម្មមានបណ្តាំ ឬអច្ច័យទាននូវ៖

- ទ្រព្យជាអចលនវត្ថុដែលប័ណ្ណកម្មសិទ្ធិត្រូវបានរៀបចំជាស្ថាពរស្របតាមបញ្ញត្តិទាំងឡាយនៃច្បាប់នេះ
- ភោគៈទាំងឡាយស្របតាមច្បាប់ដោយយោងទៅលើប័ណ្ណ ឬឯកសារគតិយុត្ត ឬភស្តុតាងផ្សេងៗទៀត
- រាល់អវយវៈភេទនៃកម្មសិទ្ធិ និងរាល់សិទ្ធិភណ្ឌិកអចលនវត្ថុ។[8]

### ១.១.១.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្រៅពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងច្បាប់ភូមិបាលឆ្នាំ២០០១ នៃព្រះរាជាណាចក្រកម្ពុជា យើងក៏មានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាមួយទៀតដែរ ដែលជាសញ្ញាណគតិយុត្តយ៉ាងសំខាន់មួយដែលទាក់ទងជាមួយនឹងប្រធានបទស្រាវជ្រាវនេះ ពីព្រោះក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់អំពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និងសិទ្ធិលើទ្រព្យសម្បត្តិ[9] នេះសរបញ្ជាក់ឲ្យឃើញនូវសិទ្ធិឯកជនរបស់បុគ្គលនីមួយៗ។ បន្ថែមពីនេះទៀត នៅគន្ថីទី៨ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពី "សន្តតិកម្ម" ក្នុងគោលបំណងការពារសិទ្ធិដល់មតកជន និងសន្តតិជនក្នុងការផ្ទេរទ្រព្យសម្បត្តិទាំងទ្រព្យសកម្ម និងទ្រព្យអកម្មពីព្រោះជាទូទៅរាល់ការផ្ទេរនូវសិទ្ធិកម្មសិទ្ធិ ករណីយកិច្ច ទ្រព្យសម្បត្តិពីបុគ្គលទទួលមរណភាព (មតកជន) ទៅជនដែលនៅរស់ទទួលបន្ត(សន្តតិជន) ក្រៅពីការបង្ហាញឆន្ទៈតាមមតកសាសន៍ដែលជាលិខិតបណ្តាំ ច្បាប់ក៏បានជួយការពារផលប្រយោជន៍ដល់សន្តតិជន ដែលក្នុងនោះច្បាប់បានកំណត់ញាតិលោហិតរបស់មតកជន ហេតុនេះទើបគន្ថីទី៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបង្ហាញពីការកំណត់ពីសន្តតិជនតាមច្បាប់យ៉ាងក្បោះក្បាយ។

បន្ថែមពីនេះ ក៏មាននូវគោលការណ៍មួយចំនួនដែលពាក់ព័ន្ធនីតិឯកជនតភ្ជាប់នឹងប្រធានបទនៃកិច្ចការស្រាវជ្រាវនេះដែរ ហើយគោលការណ៍ទាំងនោះរួមមាន៖

- គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ដែលគោលការណ៍នេះគោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និងបញ្ញត្តិអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល[10] ដូច

[6] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា ៣ កថាខណ្ឌទី ១។
[7] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា ៨ កថាខណ្ឌទី ១។
[8] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា ៧១។
[9] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ២។
[10] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ៣។

ជាសេរីភាពនៃលក្ខណៈតាមច្បាប់ សេរីភាពក្នុងការប្រើប្រាស់អាស្រ័យផល និងចាត់ចែងទ្រព្យ (កម្មសិទ្ធិ) រួមទាំងសេរីភាពក្នុងការធ្វើកិច្ចសន្យា។

- រីឯគោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ ដោយរូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន[11] ដោយមិនមានការរើសអើងវណ្ណៈ ភេទ អាយុ មុខរបរ សាសនានោះទេ ប៉ុន្តែចំពោះការទទួលសិទ្ធិរបស់ជនបរទេស គឺមានការកម្រិតទៅលើសិទ្ធិមួយចំនួនដែលមានបញ្ញត្តិនៅក្នុងច្បាប់ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។

- ចំណែកឯគោលការណ៍កំណត់សិទ្ធិប្រត្យក្ស ដោយក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិពីនិយមន័យ សិទ្ធិប្រត្យក្ស (សិទ្ធិភណ្ឌិក) សំដៅលើសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលអះអាងចំពោះបុគ្គលដទៃទៀតបាន។[12] ចំពោះគោលការណ៍នេះអាចបង្កើតបាន លុះត្រាបានទទួលស្គាល់ដោយក្រមរដ្ឋប្បវេណី ឬដោយច្បាប់ពិសេសដទៃទៀត។ ដោយសារសិទ្ធិប្រត្យក្សផ្តោតលើសិទ្ធិនៃការគ្រប់គ្រងលើវត្ថុ ហើយអាចបញ្ជាក់ចំពោះបុគ្គលដទៃបាន ទើបបង្កើតឲ្យមានគោលការណ៍នៃការបង្កើតការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស ដើម្បីជាគោលបំណងធ្វើការផ្ទេរនូវទ្រព្យសម្បត្តិរវាងភាគីមួយទៅភាគីមួយទៀត ឬជាការផ្ទេរទ្រព្យសម្បត្តិពីបុគ្គលដែលបានទទួលមរណភាព ហើយបុគ្គលនោះមានករណីយកិច្ច និងទ្រព្យសម្បត្តិ ឲ្យទៅបុគ្គលដែលនៅរស់ជាអ្នកស្នងបន្ត។

### ១.១.២ និយមន័យនៃសន្តតិកម្មតាមច្បាប់

ការចាត់ចែងទ្រព្យសម្បត្តិពីបុគ្គលដែលទទួលមរណភាព (មតកជន) ទៅបុគ្គលដែលអាចមានសិទ្ធិទទួលបាននូវទ្រព្យសម្បត្តិ (សន្តតិជន) ដែលនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ហៅការចាត់ចែងនៃការផ្ទេរមតកនេះថាជា "សន្តតិកម្ម"[13] ឬក៏ជាការផ្ទេរតាមច្បាប់នូវទ្រព្យរបស់អ្នកស្លាប់ឲ្យទៅអ្នករស់ ហើយមត៌ក ឬទ្រព្យរបស់ខ្មោចដែលត្រូវបានទៅទាយាទ(អ្នកបន្តមត៌ក) នេះហៅថា "សន្តតិកម្ម" ដែរ។[14]

រីឯពាក្យ មតកជន សំដៅទៅលើជនដែលបានស្លាប់ទៅហើយ។[15] ចំណែក សន្តតិជន គឺជាជនដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។[16] រីឯ សិទ្ធិ និងករណីយកិច្ចដែលសន្តតិជនត្រូវទទួលបានពីមតកជននោះ គឺមានទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម(បំណុល)។[17] បន្ថែមពីនេះទៀត

---

[11] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ៦។

[12] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៣០។

[13] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២១, លេខ ១៤៣។

[14] ច្បាប់ភូមិបាលឆ្នាំ២០០១, សន្ទានុក្រម, ទំព័រ ៩៥។

[15] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ១៧, លេខ ១១៧។

[16] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២១, លេខ ១៤៤។

[17] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៤៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី១។

ពាក្យ សហសន្តតិជន សំដៅដល់អ្នកដែលត្រូវចូលរួមក្នុងការចែកមត៌កណាមួយ។[18] សរុបមក តាមរយៈការបកស្រាយខាងលើ យើងទទួលបាននូវនិយមន័យនៃសន្តតិកម្មតាមច្បាប់ ដែលមានអត្ថន័យថាជាការផ្ទេរនូវមត៌ករបស់មតកជន ដែលបានទទួលមរណភាពឲ្យទៅសន្តតិជនដែលជាជនទទួលបន្តម្នាក់ ឬច្រើននាក់ ដោយមិនបានបន្សល់ទុកនូវមតកសាសន៍ដែលជាលិខិតបណ្ដាំ ក្នុងការបែងចែកមត៌ករបស់បុគ្គលដែលបានស្លាប់ ហើយការបែងចែកនេះ គឺមិនបានយកឆន្ទៈរបស់មតកជនកាលនៅរស់មកអនុវត្តនោះទេ គឺត្រូវតែធ្វើការអនុវត្តតាមច្បាប់ដែលបានបញ្ញត្តិ។

ម្យ៉ាងទៀត មូលហេតុដែលនាំឲ្យកើតមានឡើងនូវសន្តតិកម្មមាន ២ ករណីគឺៈ

- ករណីទី១ មតកជនមិនបានបន្សល់ទុកមតកសាសន៍ មុនពេលខ្លួនទទួលមរណភាពដោយមានអភូតហេតុ ឬគ្រោះថ្នាក់ណាមួយកើតឡើងដោយចៃដន្យ ដែលមតកសាសន៍នោះបានបង្ហាញពីចំណែកមត៌ក សម្រាប់សន្តតិជនម្នាក់ៗត្រូវទទួលបាន ពេលមតកជនជាម្ចាស់នៃទ្រព្យសម្បត្តិបានស្លាប់ទៅ។
- ករណីទី២ មតកជនបានធ្វើលិខិតបណ្ដាំ(មតកសាសន៍) មុនខ្លួនបានស្លាប់ ប៉ុន្តែលិខិតបណ្ដាំនោះមិនត្រឹមត្រូវតាមច្បាប់ គ្មានសុពលភាពគតិយុត្ត ឬអាចមានវិការៈនៃលិខិតបណ្ដាំរបស់មតកជន។ ហេតុដូចនេះបណ្ដាំគឺគ្មានសុពលភាពក្នុងការអនុវត្ត ហើយត្រូវប្ដូរមកអនុវត្តសន្តតិកម្មតាមច្បាប់ដែលបានបញ្ញត្តិ។

### ១.១.៣ ចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់

ទាក់ទិននឹងចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានបង្ហាញឲ្យឃើញថាសន្តតិកម្មតាមច្បាប់ គឺមានលក្ខណៈដាច់ខាត ចាប់បង្ខំក្នុងការអនុវត្ត និងក្នុងការបែងចែងសន្តតិកម្មឲ្យសន្តតិជន។ ប៉ុន្តែច្បាប់បានបើកសិទ្ធិអនុញ្ញាត ដោយគោរពទៅតាមឆន្ទៈរបស់សន្តតិជនដែលអាចឲ្យសន្តតិជននោះមានសិទ្ធិអាចយល់ព្រមទទួលយក ឬបោះបង់សន្តតិកម្មនោះបាន ដោយមូលហេតុមតកជនបានបន្សល់នូវកាតព្វកិច្ចច្រើនអនេកពេក ដែលជាហេតុនាំឲ្យខូចប្រយោជន៍ដល់ខ្លួនជាសន្តតិជន ឬអាចមានការយល់ព្រមដោយមានកម្រិត ក្នុងការទទួលទ្រព្យសម្បត្តិរបស់មតកជនដែលផ្ដល់ឲ្យ បន្ថែមពីនេះ សន្តតិជនក៏អាចមានសិទ្ធិក្នុងការទាមទារភាគនៃវិភាគទាន ដែលខ្លួនបានជួយមតកជនទៅលើការទំនុកបម្រុង ក្នុងការបង្កើនផ្នែកសេដ្ឋកិច្ច ឬក្នុងការថែរក្សាផ្នែកសេដ្ឋកិច្ចមុនពេលមតកជនបានទទួលមរណភាព។ ការធ្វើបែបនេះ គឺដើម្បីថែរក្សាការពារទៅដល់ប្រយោជន៍របស់សន្តតិជន។ លើសពីនេះ ក្នុងការទទួលយកទាំងស្រុងទៅលើសន្តតិកម្ម ដែលជាទ្រព្យសម្បត្តិរបស់មតកជនបានផ្ដល់ឲ្យ គឺការទទួលយកនោះត្រូវទទួលយកទាំងស្រុងលើចំណែកមត៌កដែលជាទ្រព្យសកម្ម និងចំណែកមត៌កដែលជាទ្រព្យអកម្ម។

[18] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២២, លេខ ១៥១។

## ១.២ ការកំណត់សន្តតិជន

ក្នុងការកំណត់អំពីសន្តតិជន គឺច្បាប់បានបញ្ញត្តិយ៉ាងច្បាស់អំពីភាពគ្រប់លក្ខណៈសម្បត្តិនៃសន្តតិជន និងលំដាប់នៃសន្តតិជនក្នុងការទទួលបានសន្តតិកម្ម។ ហេតុដូចនេះ សន្តតិជនដែលមានសិទ្ធិទទួលបានសន្តតិកម្ម ត្រូវតែជាជនដែលច្បាប់បានចែងតាមបញ្ញត្តិដូចជា សហព័ទ្ធ និងជនដែលជាញាតិលោហិតរបស់មតកជន។ លើសពីនេះ រាល់ជនដែលទទួលសន្តតិកម្ម ត្រូវតែជាជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជនតាមច្បាប់ ហើយមិនមែនជាអភ័ព្វបុគ្គល និងជនដែលត្រូវបានផ្តាច់ចេញពីមត៌ក។

ចំពោះភាពគ្រប់លក្ខណៈសម្បត្តិនៃសន្តតិជន និងលំដាប់នៃសន្តតិជនក្នុងការទទួលបានសន្តតិកម្ម យើងបានលើកមកធ្វើការបកស្រាយក្នុងចំណុច ភាពគ្រប់លក្ខណៈសម្បត្តិនៃសន្តតិជន (១.២.១) និងលំដាប់នៃសន្តតិជនក្នុងការទទួលបានសន្តតិកម្ម (១.២.២) ដើម្បីឲ្យកាន់តែងាយយល់ ក្បោះក្បាយ និងច្បាស់លាស់។

### ១.២.១ ភាពគ្រប់លក្ខណៈសម្បត្តិនៃសន្តតិជន

កាលណាមានសន្តតិកម្មតាមច្បាប់កើតឡើង នោះត្រូវផ្តល់សន្តតិកម្មនោះឲ្យទៅសន្តតិជន ដែលជាជនត្រូវបានកំណត់តាមច្បាប់ ដែលបានចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។ ជនដែលត្រូវបានទទួលសន្តតិកម្មនោះហៅថា "សន្តតិជន" ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមច្បាប់បានកំណត់ ពិសេសបុគ្គលនោះត្រូវតែមានជីវិតរស់នៅពេលចាប់ផ្តើមបើកសន្តតិកម្ម បន្ទាប់ពីមតកជនបានទទួលមរណភាព។ ដើម្បីស្វែងយល់ឲ្យកាន់តែស៊ីជម្រៅពីភាពគ្រប់លក្ខណៈសម្បត្តិនៃសន្តតិជន យើងនឹងលើកមកធ្វើការបកស្រាយក្នុងចំណុចអ្នកដែលមានសិទ្ធិទទួល (១.២.១.១) និងអ្នកគ្មានសិទ្ធិទទួល (១.២.១.២)។

#### ១.២.១.១ អ្នកដែលមានសិទ្ធិទទួលសន្តតិកម្ម

ក្នុងករណីសន្តតិជនបានទទួលមរណភាព ឬបានសន្មតថាបានទទួលមរណភាពមុន ឬព្រមគ្នាជាមួយមតកជន សន្តតិជននោះមិនបានបំពេញលក្ខខណ្ឌជាសន្តតិជនមានជីវិតរស់នៅទេ ដូចនេះមិនអាចទទួលសន្តតិកម្មបានឡើយ។ បន្ថែមពីនេះ ទោះបីសន្តតិជននោះជាទារកក្នុងគភ៌ក៏ដោយ ក៏អាចទទួលបានសន្តតិកម្មបានដែរ ទោះបីទារកនោះមានកំណើតក្រោយពេលចាប់ផ្តើមសន្តតិកម្ម។ ដូចនេះ ជនដែលមានសិទ្ធិទទួលបានសន្តតិកម្មគឺមានជនមានជីវិត (ក.) និង ទារកក្នុងគភ៌ (ខ.)។

##### ក. ជនមានជីវិត

ជនមានជីវិត មានន័យថាជាជនទាំងឡាយណាដែលមានកំណើតរស់រានមានជីវិត អាចទទួលសន្តតិកម្មបាន។ នៅពេលសន្តតិកម្មកើតឡើងជនដែលមានជីវិតទាំងនោះរួមមានរូបវន្តបុគ្គល ជាអនីតិជន ជាជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ បន្ថែមពីនេះ ក្នុងលក្ខខណ្ឌដែលអាចក្លាយជាសន្តតិជនដែល

មានសិទ្ធិទទួលសន្តតិកម្មបាន ដរាបណាបុគ្គលនោះមានជីវិតរស់រាន រហូតដល់ថ្ងៃចាប់ផ្តើមសន្តតិកម្មតែប៉ុណ្ណោះ។[19]

**ក.១ រូបវន្តបុគ្គល**

រូបវន្តបុគ្គល មានន័យថាជាបុគ្គលពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល[20] ឬជាបុគ្គលដែលមានរូបមែនៗ គឺមនុស្សមែនៗ ផ្ទុយនឹងនីតិបុគ្គលដែលជាមនុស្សដោយសន្មតតាមរបៀបច្បាប់។[21] ជាទូទៅ រូបវន្តបុគ្គលគ្រប់រូបមានសមត្ថភាពតាមផ្លូវច្បាប់ដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។[22] នៅពេលរូបវន្តបុគ្គលចាប់កំណើត នោះប្រធាននៃសិទ្ធិ និងកាតព្វកិច្ចនឹងកើតឡើង ហើយវាបានរលត់ទៅវិញនៅពេលរូបវន្តបុគ្គលបានស្លាប់។ នេះបង្ហាញថា ជនគ្រប់រូបដែលបានចាប់កំណើតមានជីវិត មិនថាជនជាតិខ្មែរមានសញ្ជាតិជាខ្មែរ ឬជាជនបរទេសមានសញ្ជាតិខ្មែរ ក៏អាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបានផងដែរ។ ម៉្យាងទៀត ចំពោះសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី គឺមានតែរូបវន្តបុគ្គល ឬនីតិបុគ្គលមានសញ្ជាតិជាខ្មែរទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។[23] ហេតុដូចនេះក្នុងករណីសន្តតិជនមិនមែនសញ្ជាតិខ្មែរ មិនមានសិទ្ធិក្នុងការទទួលបានសន្តតិកម្មជាអចលនវត្ថុ (ដីធ្លី) បានឡើយ។

**ក.២ ជនបរទេស**

យោងតាមច្បាប់ស្តីពីអន្តោប្រវេសន៍បានចែងអំពី បុគ្គលដែលចាត់ទុកជាជនបរទេស សំដៅទៅលើជនទាំងឡាយណាដែលគ្មានសញ្ជាតិជាខ្មែរ ដោយគ្មានការរើសអើងទោះបីជនទោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតណាមួយក៏ដោយ។[24] រីឯ ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស បានឲ្យនិយមន័យដល់ពាក្យ ជនបរទេស សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលបរទេសដែលមិនមានសញ្ជាតិខ្មែរ ទោះបីជាបុគ្គលនោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតពីពូជសាសន៍ណាមួយក៏ដោយ ដោយគ្មានការរើសអើងនោះទេ។[25] ហេតុនេះជនបរទេសក៏អាចក្លាយជា សន្តតិជនក្នុងការទទួលបានមត៌កពីមតកជនបានផងដែរ។ ក៏ប៉ុន្តែ ចំពោះជនបរទេសដែលមិនមែនសញ្ជាតិខ្មែរ ហើយរស់នៅលើទឹកដីខ្មែរ ត្រូវបានកម្រិតនូវសិទ្ធិខ្លះៗ ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាថាជនបរទេសមិនអាច

[19] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៩។

[20] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ១៩, លេខ ១២៧។

[21] ច្បាប់ភូមិបាលឆ្នាំ២០០១, សន្ទានុក្រម, ទំព័រ ៩៥។

[22] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ៦។

[23] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា ៤៤ កថាខណ្ឌទី ១

[24] ច្បាប់ស្តីពីអន្តោប្រវេសន៍, ២៦ សីហា ១៩៩៤, មាត្រា ២។

[25] ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស, នស/រកម/0៥១0/00៦, 0៥ មេសា ២០១០, មាត្រា ៤ (ពីពេលនេះតទៅហៅថា ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស) ។

ទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។[26] ដោយជនបរទេសមិនមានសញ្ជាតិខ្មែរមិនអាចមានសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុ ដែលជាកម្មវត្ថុ(ដីធ្លី)នៃសន្តតិកម្មបាននោះទេ[27] ប៉ុន្តែជនបរទេសមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ចាប់ពីជាន់ទី១(មួយ)ឡើងទៅ ចំពោះជាន់ផ្ទាល់ដី និងជាន់ក្រោមដី មិនត្រូវបានអនុញ្ញាតឲ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិឡើយ។[28] អចលនវត្ថុសំដៅលើ ដីធ្លី និងវត្ថុជាប់នឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិជាអាទិ៍។[29] ដូចនេះ ក្នុងករណីដែលសហសន្តតិជនខ្លះជាជនបរទេស និងខ្លះជាជនដែលមានសញ្ជាតិខ្មែរហើយទទួលបានចំណែកមត៌កជាអចលនវត្ថុ(ដីធ្លី) នោះជនដែលមានសញ្ជាតិខ្មែរអាចធ្វើលទ្ធកម្ម ឬ អាចចាត់ចែងដីធ្លីនោះបានដែរ ហេតុដូច្នេះ ការបែងចែកមត៌កត្រូវគួរគិតពិចារណាលើចំណុចនេះ។[30] ករណីនេះ គឺឲ្យសន្តតិជនដែលជាជនបរទេសនោះធ្វើការដោះស្រាយជាមួយនឹង សហសន្តតិជនផ្សេងទៀតដែលមានសញ្ជាតិខ្មែរ ដើម្បីធ្វើការលក់ចំណែកមត៌កជាអចលនវត្ថុ (ដីធ្លី) ហើយធ្វើការបែងចែកគ្នា បើពុំនោះទេគឺធ្វើការឲ្យទ្រព្យដែលជាអចលនវត្ថុនោះទៅសហសន្តតិជនជាសញ្ជាតិខ្មែរ ហើយទូទាត់នឹងទ្រព្យផ្សេងឲ្យសន្តតិជនជាជនបរទេស។ ប៉ុន្តែក្នុងករណីដែលសន្តតិជនទាំងអស់ពុំមានសញ្ជាតិខ្មែរដែលក្នុងករណីនេះត្រូវប្តូរដីធ្លីនោះជាប្រាក់ ហើយធ្វើការបែងចែកមត៌កនោះ។ ក៏ប៉ុន្តែ ក្នុងករណីនេះដោយហេតុថាសន្តតិជនមិនអាចមានកម្មសិទ្ធិលើដីធ្លី នោះសន្តតិជនមិនអាចចាត់ចែងលើដីធ្លីបានដែរ ដូច្នេះករណីនេះ ក៏ដូចជាករណីដែលពុំមានអត្ថិភាពសន្តតិជនដែរ គឺគេផ្តល់មូលដ្ឋានគតិយុត្តដល់ការចាត់ចែងលើដីធ្លី ដោយចាត់ទុកថាដីធ្លីដែលជាមត៌កនោះជានីតិបុគ្គលហើយនីតិបុគ្គលនោះមានកម្មសិទ្ធិទៅលើដីធ្លី និងសន្តតិជនមានសិទ្ធិគ្រប់គ្រងចាត់ចែងដីនោះដែរ។ បើមិនធ្វើដូច្នេះទេដីធ្លីនោះនឹងក្លាយទៅជាដីធ្លីគ្មានម្ចាស់ ហើយនឹងក្លាយជាទ្រព្យសម្បត្តិរដ្ឋ។ ប៉ុន្តែការដែលដាក់ដីធ្លីក្រោមកម្មសិទ្ធិនីតិបុគ្គល ដែលត្រូវបានចាត់ទុកដោយមិនមានពេលកំណត់នោះ មិនត្រឹមត្រូវឡើយ។ ដូចនេះត្រូវមានការកម្រិតអំឡុងពេលម្តង៣(បី)ខែ ជាអំឡុងពេលចាត់ចែងបន្ទាប់ពីសន្តតិជនទាំងអស់ដែលមានលំដាប់ខ្ពស់ជាងគេបានយល់ព្រមទាំងស្រុង ឬយល់ព្រមដោយកម្រិត។ ហើយប្រសិនបើក្នុងអំឡុងពេលនោះ មិនមានការចាត់ចែងដីធ្លីនេះទេ សន្តតិជនដែលមានលំដាប់បន្ទាប់ជាសន្តតិជនទៅវិញ។ ក្នុងករណីដែលសន្តតិជនមានលំដាប់បន្ទាប់ទាំងអស់សុទ្ធតែគ្មានសញ្ជាតិខ្មែរ ក៏ត្រូវធ្វើតាមនីតិវិធីដូចគ្នានេះដែរ។[31]

[26] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ៧។

[27] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៥ កថាខណ្ឌទី១។

[28] ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស, មាត្រា៦។

[29] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២៦, លេខ ១៧៦ កថាខណ្ឌ ១។

[30] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*, ភាគ៦, គន្ថីទី៨-ទី៩ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ១៣ (ពីពេលនេះតទៅហៅថា សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្ថីទី៨-ទី៩) ។

[31] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្ថីទី៨-ទី៩, ១៣-១៤។

លើសពីនេះទៅទៀត ជនបរទេសអាចធ្វើការទាមទារស្នើសុំសញ្ជាតិខ្មែរបានផងដែរ ដោយធ្វើការរៀបអាពាហ៍ពិពាហ៍ ហើយដាក់ពាក្យសុំ និងបំពេញបែបបទនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ។[32] ចំពោះការដាក់ពាក្យសុំ ជនបរទេសនោះត្រូវបំពេញបែបបទដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិ។ នៅពេលដែលជនបរទេសទទួលបានសញ្ជាតិខ្មែរហើយ នោះបានសេចក្តីថាជននោះទទួលបានសិទ្ធិ កាតព្វកិច្ច និងករណីយកិច្ចក្នុងការទទួលបាននូវសន្តតិកម្មដូចគ្នានឹងពលរដ្ឋខ្មែរដែរ ដោយទទួលបានទាំងចលនវត្ថុ និងអចលនវត្ថុ ដូចជាដីធ្លីជាដើម។

### ក.៣ អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ

មុនឈានដល់ការអធិប្បាយពីសន្តតិជនដែលអាចជាអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ យើងនឹងធ្វើការពន្យល់ទៅលើពាក្យគន្លឹះនីមួយៗជាមុនសិន។ ពាក្យថា អនីតិជន សំដៅទៅលើជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម១៨ឆ្នាំ។[33] រីឯ ជននៅក្រោមអាណាព្យាបាលទូទៅ សំដៅលើជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យដោយសារតែមានវិបត្តិផ្នែកបញ្ញាស្មារតី។ ឧទាហរណ៍៖ ជនដែលមិនអាចទៅទិញអីវ៉ាន់ប្រចាំថ្ងៃដោយខ្លួនឯងបាន ហើយចាំបាច់ត្រូវមានអ្នកណាធ្វើជំនួស ជនដែលមិនដឹងអ្វីៗដែលកើតមានឡើងរៀងរាល់ថ្ងៃ អាចជាឈ្មោះ គ្រួសារ ទីកន្លែងដែលខ្លួនរស់នៅជាដើម ឬជនដែលធ្លាក់ក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ (ស្ថានភាពស្លាប់ខួរក្បាល)។[34] បន្ថែមពីនេះ ក៏មានការរួមបញ្ចូលអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិដាក់ពាក្យសុំការចាប់ផ្តើមអាណាព្យាបាលទូទៅ ចំពោះជនដែលជាអនីតិជនដែលមានពិការខាងបញ្ញា និងខាងផ្លូវចិត្ត។ ក្នុងករណីនេះ ពេលចាប់ផ្តើមអាណាព្យាបាលទូទៅ ជននោះគឺជាជននៅក្រោមការអាណាព្យាបាលសម្រាប់អនីតិជនផង និងជាជននៅក្រោមអាណាព្យាបាលទូទៅផង ប៉ុន្តែការទទួលស្គាល់អំពីអត្ថិភាពព្រមគ្នានៃអាណាព្យាបាលទូទៅនេះ មិនមានភាពចាំបាច់ក្នុងការទទួលស្គាល់នូវអត្ថិភាពព្រមគ្នានៃអាណាព្យាបាលចំពោះអនីតិជនដែលមានអាយុទាបពេកទេ។ ហេតុនេះហើយ ការកម្រិតអាយុនោះ ដោយគិតដល់អាយុដែលត្រូវបញ្ចប់ការទទួលការអប់រំជាកាតព្វកិច្ច មានន័យថាទទួលស្គាល់ការដាក់ពាក្យសុំឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ លុះត្រាតែសាមីខ្លួនមានអាយុយ៉ាងតិច ១៥ឆ្នាំ នៅពេលដាក់ពាក្យសុំនោះ។[35]

[32] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិ, លេខ ១១២ អនក្រ.បក, ៣០ សីហា ២០១៨, មាត្រា ៥។

[33] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ធានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២៧, លេខ ១៨៧។

[34] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*, ភាគ១, គន្ថីទី១-ទី៣ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ១៨ (ពីពេលនេះតទៅហៅថា សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ១, គន្ថីទី១-ទី៣) ។

[35] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ១, គន្ថីទី១-ទី៣, ១៩។

ចំណែកឯ ជននៅក្រោមហិតូបត្ថម្ភ សំដៅលើជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតីតុលាការអាចប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤(បួន)ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។[36]

យ៉ាងណាមិញ ជនទាំងបីរូបដែលបានរៀបរាប់ខាងលើត្រូវបានកម្រិតសិទ្ធិក្នុងការអនុវត្ត យល់ព្រម និងបោះបង់នូវកាតព្វកិច្ចមួយចំនួនចំពោះការយល់ព្រមទទួលស្គាល់ ឬបោះបង់សន្តតិកម្ម ឬក៏ជាការបែងចែកនូវមត៌កជាដើម។ ចំពោះអនីតិជន ក្នុងការអនុវត្តនូវសន្តតិកម្មដូចជាការយល់ព្រមទទួលស្គាល់ ឬបោះបង់ គឺត្រូវមានការយល់ព្រមពីអ្នកដែលជាអាណាព្យាបាលក្នុងការសម្រេចចិត្តលើការអនុវត្តនៃសន្តតិកម្ម បើពុំនោះទេនឹងត្រូវចាត់ទុកជាមោឃលើសកម្មភាពដែលអនីតិជនបានអនុវត្ត។[37] ចំពោះជននៅក្រោមអាណាព្យាបាលទូទៅវិញ បើគ្មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅនោះទេ រាល់សកម្មភាពដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើនឹងត្រូវលុបចោល លើកលែងសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។[38] ចំណែកជននៅក្រោមហិតូបត្ថម្ភ ក៏ដូចគ្នានឹងអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅដែរ ហិតូបត្ថម្ភកៈមានសិទ្ធិលុបចោលសកម្មភាពដែលខ្លួនគ្មានការយល់ព្រម ទៅលើសកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើឡើង លើកលែងសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។

### ក.៤ អនីតិជនទទួលបានអត្តាធីនភាព

អត្តាធីនភាព គឺផ្ដោតទៅលើស្ថានភាពមួយ ដែលផ្ដល់ឲ្យអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។[39] ហេតុដូចនេះ ក្នុងករណីដែលអនីតិជនចង់រួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជន នោះអនីតិជននោះត្រូវមានល័ក្ខខ័ណ្ឌ ឬលក្ខណៈសម្បត្តិដូចខាងក្រោមទើបទទួលបានអត្តាធីនភាព៖

- ក្នុងករណីដែលអនីតិជនដែលមានអាយុដល់ ១៦ (ដប់ប្រាំមួយ)ឆ្នាំ អាចទ្រទ្រង់ទៅលើជីវភាពរបស់ខ្លួនឯងបានដោយឯករាជ្យ នោះអនីតិជននោះអាចទទួលបាននូវអត្តាធីនភាពដោយធ្វើការដាក់ពាក្យទៅតុលាការហើយ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់ជននោះបាន ទៅតាមពាក្យសុំរបស់អនីតិជននោះ លុះត្រាតែតុលាការបានយល់ឃើញថា អត្តាធីនភាពដែលជននោះបានដាក់សមស្របនឹងផលប្រយោជន៍របស់អនីតិជន

[36] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ២៨ កថាខណ្ឌទី ១។
[37] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៨ វាក្យខណ្ឌទី ១។
[38] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ២៦។
[39] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២៦, លេខ ១៨៣។

នោះ។ ប៉ុន្តែករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបារបស់អនីតិជននោះផងដែរ។

- អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ តែអនីតិជននោះត្រូវមានអាយុមិនតិចជាង១៦ (ដប់ប្រាំមួយ)ឆ្នាំ ទើបអាចរៀបអាពាហ៍ពិពាហ៍បានហើយទទួលបានអត្តាធីនភាព។ ល័ក្ខខ័ណ្ឌកំណត់អាយុក្នុងការរៀបអាពាហ៍ពិពាហ៍ មានចែងក្នុងមាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី។ នៅក្នុងករណីនេះ ទោះបីជាភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាពមិនត្រូវរលត់ឡើយ។[40]

ទន្ទឹមនឹងនេះ ប្រសិនបើអនីតិជនទទួលបានអត្តាធីនភាពដោយស្របតាមល័ក្ខខ័ណ្ឌណាមួយខាងលើ អនីតិជននោះនឹងក្លាយជានីតិជនពេញសិទ្ធិស្របតាមច្បាប់ ហេតុដូចនេះ នាំឲ្យរាល់សន្តតិកម្មដែលនីតិជនបានទទួលពីមតកជនដែលបានសម្រេចផ្តល់ឲ្យជននេះ គឺអាចទទួលយកបានដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលឡើយ។

**ខ. ទារកក្នុងគភ៌**

ជាទូទៅ គោលការណ៍ដើម្បីក្លាយជាសន្តតិជន ហើយអាចមានសិទ្ធិទទួលបាននូវសន្តតិកម្មបានលុះត្រាតែបុគ្គលនោះមានជីវិតរស់រាន រហូតដល់ថ្ងៃចាប់ផ្តើមសន្តតិកម្ម។ តែក្នុងករណីនេះ បើសិននៅពេលចាប់ផ្តើមសន្តតិកម្មមានទារកនៅក្នុងគភ៌ដែលមិនទាន់ចាប់កំណើតជាសន្តតិជន នោះអាចនាំឲ្យខូចនូវប្រយោជន៍ដល់ទារកនៅក្នុងគភ៌នោះ។ ហេតុនេះ បានជាក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីការការពារដល់ផលប្រយោជន៍របស់ទារកក្នុងគភ៌ ទោះបីជាទារកនៅក្នុងគភ៌នោះមានកំណើតរស់រាន នៅក្រោយពេលនៃការចាប់ផ្តើមសន្តតិកម្មក៏ដោយ ក៏ទារកក្នុងគភ៌នោះអាចមានសិទ្ធិទទួលបានមត៌ក ដោយសន្តតិកម្មនោះបានផងដែរ។[41] ប្រសិនបើធ្វើការដកសិទ្ធិជាសន្តតិជនរបស់ទារកនៅក្នុងគភ៌ដែលមិនទាន់កើតមកនោះ នឹងនាំឲ្យមានការខូចខាតដល់ផលប្រយោជន៍ និងសិទ្ធិស្របច្បាប់របស់ទារកនៅក្នុងគភ៌នោះ។ ហេតុនេះ ទើបនាំឲ្យច្បាប់បានបញ្ញត្តិយ៉ាងច្បាស់ក្នុងការការពារទៅលើទារកនៅក្នុងគភ៌នោះ គឺកាលបើទារកនោះបានកើតមកហើយមានជីវិតរស់រានម្ល៉ោះហើយទារកនៅក្នុងគភ៌នោះនឹងមានសិទ្ធិក្លាយជាសន្តតិជនហើយទទួលបានសន្តតិកម្ម។

**១.២.១.២ អ្នកដែលគ្មានសិទ្ធិទទួលសន្តតិកម្ម**

ជនដែលគ្មានសិទ្ធិទទួល សំដៅលើជនទាំងឡាយណាដែលមិនមានភាពគ្រប់លក្ខណៈសម្បត្តិជាសន្តតិជនក្នុងការទទួលបានសន្តតិកម្ម។ យោងតាមក្រមរដ្ឋប្បវេណី ក៏បានបញ្ញត្តិអំពីជនដែលគ្មានសិទ្ធិទទួលបានចំណែកមត៌កពីមតកជននៅពេលចាប់ផ្តើមសន្តតិកម្មបានឡើយ ដែលជនទាំងនោះរួមមាន៖

[40] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ២១។
[41] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ៩។

### ក. អភ័ព្វបុគ្គល

ដើម្បីស្វែងយល់ពីអភ័ព្វបុគ្គល ដែលជាជនគ្មានសិទ្ធិទទួលបាននូវសន្តតិកម្មនោះគឺយើងត្រូវយល់ពីពាក្យអភ័ព្វបុគ្គលជាមុនសិន។ អភ័ព្វបុគ្គល សំដៅទៅលើបុគ្គលដែលពុំអាចក្លាយជាសន្តតិជន ឬពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន។[42] ដូចនេះ ជនដែលបានកំណត់ថាជាអភ័ព្វបុគ្គលនោះស្ថិតក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម៖

- បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតលើមតកជន ឬលើជនដែលមានលំដាប់សន្តតិកម្មមុន ឬលំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។
- បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬមិនបានប្តឹង។ ប៉ុន្តែចំណុចនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬអំពើអាក្រក់បាន ឬករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។
- បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬកែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬគម្រាមកំហែង ។
- បុគ្គលដែលបានឲ្យមតកជនធ្វើ លុបចោល ឬកែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬគម្រាមកំហែង ។
- បុគ្គលដែលបានក្លែងបន្លំ បំផ្លាញចោល ឬលាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន។[43]

### ខ. ជនដែលត្រូវបានផ្តាច់ចេញពីមត៌ក

ជនដែលត្រូវផ្តាច់ចេញពីមត៌កនៅពេលដែលមតកជននៅរស់បានដាក់ពាក្យសុំទៅតុលាការ ឲ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះមិនឲ្យទទួលសន្តតិកម្មបាន លើជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង។ មតកជនអាចផ្តាច់មត៌កពីជនដែលជាសន្តតិជនបាន លុះត្រាតែជននោះបានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ៖

- បានធ្វើបាបចំពោះមតកជន
- បានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ
- អាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ

[42] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២៧, លេខ ១៩០។

[43] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥០។

- ត្រូវបានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយជីវិត
- បានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍។[44]

## ១.២.២ លំដាប់នៃសន្តតិជនក្នុងការទទួលបានសន្តតិកម្ម

លំដាប់នៃសន្តតិជន សំដៅលើការកំណត់នៃការទទួលបានសិទ្ធិ និងករណីយកិច្ចពីមតកជនដែលបានទទួលមរណភាព ទៅឲ្យបុគ្គលដែលជាជនមានសិទ្ធិទទួលដែលច្បាប់បានចែង ទៅតាមលំដាប់លំដោយ។ ជនដែលមានសិទ្ធិទទួលពោលគឺ "សន្តតិជន" ត្រូវបានកំណត់ថាជាជនដែលជាញាតិលោហិតរបស់មតកជនប៉ុណ្ណោះ មិនមែនជាតតិយជនដែលមានទំនាក់ទំនងពិសេសជាមួយមតកជននោះទេ។ ដោយយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានបញ្ញត្តិអំពីញាតិលោហិតមាន ៦ (ប្រាំមួយ)ថ្នាក់[45] ប៉ុន្តែញាតិលោហិតរបស់មតកជនមានតែ៣ (បី) ថ្នាក់នោះទេដែលមានសិទ្ធិគ្រប់គ្រាន់ក្លាយជាសន្តតិជនបាន ក្នុងនោះរួមមាន សន្តតិជនលំដាប់១និងសន្តតិជនជំនួស សន្តតិជនលំដាប់២ ព្រមទាំងសន្តតិជនលំដាប់៣និងសន្តតិជនជំនួស។ ក្រៅពីនេះជនដែលជាសហព័ទ្ធរបស់មតក ក៏ក្លាយជាសន្តតិជនមួយដែរ ដែលសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជនជានិច្ច។[46]

### ១.២.២.១ សន្តតិជនលំដាប់ទី១ និងសន្តតិជនជំនួស

សន្តតិជនលំដាប់ទី១នេះ គេអាចហៅបានថា "បច្ឆាញាតិ"។ បុគ្គលដែលអាចក្លាយជាសន្តតិជនលំដាប់ទី១ នោះគឺជាកូនរបស់មតកជន ទោះបីជាកូននោះជាកូនបង្កើត ឬកូនស្មុំក្តីក៏ជាសន្តតិជនលំដាប់ទី១ដែរ ហើយទទួលបានចំណែកមត៌ករបស់មតកជនស្មើៗគ្នា។[47] ចំពោះកូនស្មុំរបស់មតកជន អាចមានអនុភាពក្នុងការទទួលបានសន្តតិកម្មបាន លុះត្រាតែជាកូនស្មុំពេញលេញរបស់មតកជន ឬជាកូនស្មុំធម្មតា។ លើសពីនេះកូនបង្កើតរបស់សន្តតិជនអាចមានស្ថានភាពពីរគឺ ទីមួយកូនបង្កើតក្នុងចំណងអាពាហ៍ពិពាហ៍ និងទី២កូនបង្កើតក្រៅចំណងអាពាហ៍ពិពាហ៍។ ដើម្បីកាន់តែមានភាពក្បោះក្បាយ យើងនឹងធ្វើការបកស្រាយក្នុងចំណុចខាងក្រោមៈ

- កូនបង្កើតរបស់មតកជនក្នុងចំណងអាពាហ៍ពិពាហ៍ទូទៅគេហៅថា "កូនមានខាន់ស្លា" កូនក្នុងចំណងអាពាហ៍ពិពាហ៍ សំដៅលើកូនដែលបានបង្កើតឡើងដោយប្តី និងប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ស្របទៅតាមច្បាប់ មានន័យថាកូនក្នុងចំណងអាពាហ៍ពិពាហ៍ស្របតាមច្បាប់របស់មតកជន ជាមួយប្តី ឬប្រពន្ធរបស់មតកជន។ រីឯ កូនបង្កើតក្រៅចំណងអាពាហ៍ពិពាហ៍ទូទៅគេហៅថា "កូនឥតខាន់ស្លា" កូនបង្កើតក្រៅចំណងអាពាហ៍ពិពាហ៍ សំដៅលើកូនដែលបានកើតឡើងដោយ ប្តី ឬប្រពន្ធជាមួយបុគ្គលដទៃទៀតដែលមិនមែនជា ប្តី ឬ

[44] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥១។
[45] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ៩៣៨ កថាខណ្ឌ ក។
[46] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦១ កថាខណ្ឌទី ១។
[47] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៦។

ប្រពន្ធមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ (សហព័ទ្ធ) របស់ខ្លួន។ ចំពោះកូនបង្កើតក្រៅចំណង អាពាហ៍ពិពាហ៍ទូទៅនេះ ទទួលបាននូវចំណែកមត៌ក លុះត្រាតែមានសំបុត្រកំណើតដែលជាភស្តុតាងបញ្ជាក់នូវ ទំនាក់ទំនងគតិយុត្តរវាងកូន និងឪពុក ឬម្តាយ។

- ចំពោះកូនស្មុំរបស់មតកជន៖ ករណីកូនស្មុំពេញលេញរបស់មតកជន កូនស្មុំពេញលេញត្រូវស្ថិតក្រោម ការគ្រប់គ្រងទាំងស្រុងរបស់ឪពុក-ម្តាយចិញ្ចឹម ហើយញាតិលោហិតរបស់ឪពុក-ម្តាយបង្កើតត្រូវបានបញ្ចប់ ដូច នេះកូនស្មុំពេញលេញមិនអាចទទួលបានសន្តតិកម្មពីឪពុក-ម្តាយបង្កើតបាននោះទេ បានតែពីឪពុក-ម្តាយចិញ្ចឹម ប៉ុណ្ណោះ។[48] ចំណែកស្មុំកូនធម្មតា ញាតិភាពរវាងឪពុក-ម្តាយបង្កើតនៅតែបន្តអាចទទួលបានសន្តតិកម្មពី ឪពុក-ម្តាយបង្កើតបាន ហើយក៏អាចទទួលសន្តតិកម្មពីឪពុក-ម្តាយចិញ្ចឹងបានផងដែរ។[49]

ផ្ទុយទៅវិញ បើក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាពព្រមគ្នានឹងមតកជន ឬមុនពេល ចាប់ផ្តើមសន្តតិកម្ម ឬកូនរបស់មតកជនត្រូវបានបាត់បង់សិទ្ធិជាសន្តតិជនក្នុងករណីជាអភ័ព្វបុគ្គលនៃ សន្តតិកម្ម ឬក៏ជាជនដែលត្រូវបានផ្តាច់ចេញពីមត៌ក។ ហេតុនេះ ក្នុងស្ថានភាពនេះធ្វើឲ្យបាត់បង់នូវសន្តតិជន លំដាប់ទី១ ព្រមទាំងប្រយោជន៍របស់សន្តតិជនលំដាប់១។ ប៉ុន្តែ ក្នុងករណីនេះសន្តតិជនជំនួសជនត្រូវយកមក អនុវត្តបាន ដោយអាចទទួលមត៌កជំនួសសន្តតិជនលំដាប់ទី១បាន ហើយជននោះត្រូវជាកូនរបស់សន្តតិជន លំដាប់ទី១។[50] ក៏ប៉ុន្តែ សន្តតិជនជំនួសនេះគឺអនុវត្តជាបន្តបន្ទាប់ចំពោះបច្ឆាញាតិផ្ទាល់របស់មតកជនប៉ុណ្ណោះ[51] ពោលគឺការអនុវត្តបន្តបន្ទាប់ គឺក្នុងករណីបច្ឆាញាតិផ្ទាល់របស់សន្តតិជន បានទទួលមរណភាពមុនពេលចាប់ផ្តើម សន្តតិកម្ម នោះអានុភាពរបស់សន្តតិជនជំនួសនឹងបន្តឲ្យបច្ឆាញាតិផ្ទាល់របស់កូនមតកជន (ចៅរបស់មតកជន) ។ ម្យ៉ាងទៀត ក្នុងករណីកូនរបស់មតកជនជាកូនស្មុំ តាមរបបស្មុំកូនធម្មតា បានធ្វើឡើងមុនពេលកូនស្មុំមានកូន នៅពេលកូនស្មុំនោះទទួលមរណភាពមុនចាប់ផ្តើមសន្តតិកម្មកូនរបស់កូនស្មុំ (ចៅរបស់មតកជន) អាចទទួល បន្តមត៌កក្រោមរូបភាពជាសន្តតិកម្មជំនួស ប៉ុន្តែបើកូនស្មុំនោះ មានកូនមុនពេលភ្ជាប់ទំនាក់ទំនងជាកូនស្មុំរបស់ មតកជន កូនរបស់កូនស្មុំមតកជនមិនអាចអនុវត្តសិទ្ធិសន្តតិកម្មជំនួសបាននោះទេ។ ចំណែកមត៌ករបស់ សន្តតិជនជំនួស ត្រូវចែកស្មើៗគ្នានៃចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិនោះទទួលបាន ទោះ សន្តតិជនជំនួសមានច្រើនអ្នកក៏ដោយ។[52]

---

[48] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១០១៤។
[49] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១០២៦ កថាខណ្ឌទី ១។
[50] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៧ កថាខណ្ឌទី ១។
[51] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៧ កថាខណ្ឌទី ២។
[52] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹទី៨-ទី៩, ១៥។

### ១.២.២.២ សន្តតិជនលំដាប់ទី២

សន្តតិជនលំដាប់ទី២នេះ គេអាចហៅថា "បុព្វញាតិផ្ទាល់"។ បុព្វញាតិផ្ទាល់របស់មតកជនរួមមានដូចជា ឪពុក ម្តាយ ឬ ជាជីដូនជីតារបស់មតកជន។ សន្តតិជនលំដាប់ទី២ មានវត្តមានក្នុងការទទួលបានសន្តតិកម្មរបស់មតកជនបាន លុះត្រាតែគ្មានសន្តតិជនលំដាប់ទី១ និងសន្តតិជនជំនួសទើបមត៌ករបស់មតកជន ធ្លាក់ទៅសន្តតិជនលំដាប់ទី២។ បុព្វញាតិផ្ទាល់របស់មតកជនដែលនៅជិតជាងគេនឹងក្លាយជាសន្តតិជន។[53] ហេតុនេះសន្តតិជនលំដាប់ទី២ ដែលទទួលបានមត៌កពីមតកជននោះគឺ ឪពុក ម្តាយរបស់មតកជនដែលមានបុព្វញាតិជិតជាងគេ។

ប្រសិនបើបុព្វញាតិផ្ទាល់របស់មតកជនក្លាយជាសន្តតិជន ហើយមានច្រើននោះបុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។[54] ករណីមតកជនមានទាំងឪពុក និងម្តាយ នោះអ្នកទាំងពីរនឹងក្លាយជាសន្តតិជន ហើយចំណែកមត៌ករបស់មតកជនត្រូវបានចែកឲ្យស្មើៗគ្នា។ ប៉ុន្តែ ក្នុងករណីដែលឪពុករបស់មតកជនបានទទួលមរណភាពហើយ ទោះបីជាជីដូនជីតាខាងឪពុកនោះនៅរស់ក៏ដោយ ប្រសិនបើម្តាយរបស់មតកជននោះនៅរស់ ម្តាយនោះជាញាតិភាពជិតជាងគេក្នុងថ្នាក់ញាតិ ដូច្នេះ ម្តាយគឺជាសន្តតិជនលំដាប់ទីពីរតែម្នាក់ឯង ជីដូនជីតាខាងឪពុកមិនទទួលសន្តតិកម្មជំនួសឡើយ។ ក្នុងករណីដូចគ្នានេះ ប្រសិនបើម្តាយរបស់មតកជនក៏បានទទួលមរណភាពដែរ នោះជីដូនជីតាខាងម្តាយ និងជីដូនជីតាខាងឪពុកត្រូវទទួលសន្តតិកម្ម។ ប្រសិនបើជីដូន ឬជីតាខាងម្តាយណាម្នាក់បានទទួលមរណភាព ជីដូនជីតាដែលនៅរស់ត្រូវទទួលសន្តតិកម្មស្មើភាគគ្នា។ ដូចនេះ គឺត្រូវបែងចែកមត៌កស្មើភាគគ្នាទៅតាមចំនួនមនុស្ស។[55]

### ១.២.២.៣ សន្តតិជនលំដាប់ទី៣ និងសន្តតិជនជំនួស

សន្តតិជនលំដាប់ទី៣ គឺសំដៅលើបងប្អូនបង្កើតរបស់មតកជន។ បងប្អូនបង្កើតរបស់មតកជនមានច្រើននាក់ នោះចំណែកមត៌ករបស់សន្តតិជនលំដាប់ទី៣ដែលជាបងប្អូនបង្កើតរបស់មតកជន ត្រូវទទួលបានគឺមានចំណែកស្មើៗគ្នា។[56] កាលដែលសន្តតិជនលំដាប់ទី៣បានកើតឡើង ហើយក្លាយជាសន្តតិជនទទួលបានមត៌កពីមតកជននោះ លុះត្រាតែមតកជនមិនមានសន្តតិជនលំដាប់ទី១និងសន្តតិជនជំនួសដែលហៅថាបច្ឆាញាតិផ្ទាល់ព្រមទាំងបុព្វញាតិផ្ទាល់ដែលជាសន្តតិជនលំដាប់ទី២។ ប៉ុន្តែ បងប្អូនរបស់មតកជនអាចមានពីរ គឺករណីបងប្អូនបង្កើតដែលមានឪពុកម្តាយបង្កើតតែមួយ ករណីមួយទៀតគឺមតកជនអាចមានបងប្អូនបង្កើតដែលមានតែឪពុក ឬម្តាយណាម្ខាងផ្សេងគ្នា ដូចនេះ ការបែងចែកមត៌កក៏មានការប្រែប្រួលដែរ ដោយក្នុងករណីបងប្អូនបង្កើតដែលមាន

[53] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៩ កថាខណ្ឌទី ១។
[54] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៩ កថាខណ្ឌទី ២។
[55] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៨។
[56] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១។

ឪពុកម្តាយបង្កើតតែមួយ នោះបងប្អូនបង្កើតរបស់មតកជនទទួលបានចំណែកមត៌កស្មើៗគ្នា ផ្ទុយទៅវិញករណី មតកជនមាននូវបងប្អូនបង្កើតដែលមានឪពុក ឬម្តាយផ្សេងគ្នានោះចំណែកមត៌ករបស់បងប្អូនបង្កើតដែលមាន ឪពុក ឬម្តាយផ្សេងគ្នាត្រូវទទួលបានត្រឹមពាក់កណ្តាល នៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ម្តាយ បង្កើតតែមួយប៉ុណ្ណោះ។[57]

សន្តតិជនលំដាប់ទី៣ក៏មាននូវសន្តតិជនជំនួសដែរ ក្នុងស្ថានភាពដែលសន្តតិជនលំដាប់ទី៣បានទទួល មរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម នោះនាំឲ្យកើតឡើងនូវសន្តតិកម្មជំនួសដែលជាបច្ឆាញាតិផ្ទាល់របស់ សន្តតិជនលំដាប់ទី៣ត្រូវបានក្លាយជាសន្តតិជនជំនួស។ ក្នុងការអនុវត្តសន្តតិជនជំនួសនេះមិនមានការអនុវត្តជា បន្តបន្ទាប់ទៅលើបច្ឆាញាតិផ្ទាល់ទៅលើសន្តតិកម្មជំនួស ដូចការអនុវត្តបន្តបន្ទាប់របស់សន្តតិជនលំដាប់ទី១នោះ ទេ ពោលគឺមានតែកូនរបស់សន្តតិជនលំដាប់ទី៣ប៉ុណ្ណោះ ទើបអាចក្លាយជាសន្តតិជនជំនួសបាន។ ចំពោះ ចំណែកមត៌កសម្រាប់បែងចែងទៅឲ្យសន្តតិជនជំនួសក្នុងចំណុចនេះ គឺអនុវត្តដូចនឹងការអនុវត្តទៅលើសន្តតិជន ជំនួសក្នុងចំណុចសន្តតិជនលំដាប់ទី១ផងដែរ គឺត្រឹមចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះ ទទួលបាន។

### ១.២.២.៤ សន្តតិជនជានិច្ច

សន្តតិជនជានិច្ច សំដៅលើសហព័ទ្ធរបស់មតកជន។ សហព័ទ្ធ សំដៅលើប្តី ឬប្រពន្ធ ឬទាំងប្តី និងប្រពន្ធ ដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។[58] សន្តតិជនជា និច្ចមិនមានលំដាប់នោះទេ។

កាលបើមតកជនបានទទួលមរណភាព ហើយមានតែសហព័ទ្ធដែលជាសន្តតិជនជានិច្ចតែមួយ ហើយ មិនមានសន្តតិជនលំដាប់ណាផ្សេងនោះទេ នោះមត៌កនឹងបានទៅសន្តតិជនជានិច្ចទាំងអស់។ ប៉ុន្តែ បើក្នុងករណី ដែលសហព័ទ្ធរបស់មតកជន និងបុគ្គលផ្សេងទៀត ក្រៅពីសហព័ទ្ធត្រូវក្លាយជាសន្តតិជន នោះចំណែកមត៌ករបស់ សន្តតិជននឹងត្រូវធ្វើការបែងបែកដូចខាងក្រោម៖

- ក្នុងករណីដែលសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់ពោលគឺ សន្តតិជនលំដាប់ទី១ និងសន្តតិជនជំនួសរបស់ មតកជននោះជាសន្តតិជន នាំឲ្យសហព័ទ្ធ និងកូននីមួយៗរបស់មតកជននោះ ត្រូវទទួលចំណែកមត៌កស្មើគ្នា។ ក្នុងករណីដែលកូនបានទទួលមរណភាព ហើយបុគ្គលទទួលសន្តតិកម្មជំនួសជាសន្តតិជន ចំណែកមត៌កក៏ត្រូវ បែកចែកស្មើគ្នាផងដែរ។

[57] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២។
[58] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២២, លេខ ១៥០។

- ក្នុងករណីដែលសហព័ទ្ធ និងឪពុកម្ដាយរបស់មតកជនជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុក ម្ដាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី) ។ ប៉ុន្តែ បើឪពុក ឬម្ដាយរបស់មតកជនតែម្នាក់នៅរស់ ឪពុក ឬម្ដាយនោះ និងសហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា។ ក៏ប៉ុន្តែ ក្នុងករណីដែលមតកជនជាកូនសុំតាមសុំកូនធម្មតា មតកជនអាចមានទាំងឪពុកម្ដាយបង្កើត និងឪពុកម្ដាយចិញ្ចឹមថែមទៀត ប៉ុន្តែ ទោះជាក្នុងករណីបែបនេះក៏ដោយ ក៏សហព័ទ្ធគួរទទួលបានយ៉ាងតិច ១ ភាគ ៣ ដែរ ទើបជាការសមរម្យ។ ករណីនេះចែងពីសន្តតិជនលំដាប់ទី២ដែលជា ឪពុក ម្ដាយរបស់មតកជនប៉ុណ្ណោះ។

- ក្នុងករណីបើសហព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪពុកម្ដាយរបស់មតកជន ឬបងប្អូនបង្កើតរបស់មតកជន ឬអ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ ក្រៅពីឪពុកម្ដាយរបស់មតកជន ឬបងប្អូនបង្កើតរបស់មតកជន ឬអ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ)។ ករណីនេះប្រើចំពោះសន្តតិជនដែលមានលំដាប់ទី៣ តែមិនមែនជាបងប្អូនបង្កើតរបស់មតកជននោះទេ។[59]

## ១.៣ អានុភាពនៃសន្តតិកម្មតាមច្បាប់

ក្នុងការដែលនាំឲ្យសន្តតិកម្មតាមច្បាប់មានអានុភាពដែលជាផលគតិយុត្ត គឺច្បាប់បានចែងសម្រាប់យកមកអនុវត្តយ៉ាងត្រឹមត្រូវរួចរាល់ហើយ។ នោះគឺនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានចែងនៅក្នុងផ្នែកទី១ ការចាប់ផ្ដើមធ្វើសន្តតិកម្ម ជំពូកទី១ គន្ថីទី៨ ហើយបានកំណត់ពីពេល និងទីកន្លែងចាប់ផ្ដើមសន្តតិកម្ម។ ដើម្បីធ្វើការស្វែងយល់ឲ្យកាន់តែយល់ច្បាស់ពីអានុភាពនៃសន្តតិកម្មតាមច្បាប់ យើងនឹងបកស្រាយក្នុងពេលវេលាបើកសន្តតិកម្មតាមច្បាប់ (១.៣.១) និងទីកន្លែងបើកសន្តតិកម្មតាមច្បាប់ (១.៣.២)។

### ១.៣.១ ពេលវេលាបើកសន្តតិកម្មតាមច្បាប់

ការចាប់ផ្ដើមបើកសន្តតិកម្មតាមច្បាប់ ជាគោលការណ៍ត្រូវបានបើកនៅពេលមរណភាពរបស់មតកជន និងការបាត់ខ្លួនរបស់មតកជន ដែលចំណុចទាំងពីរខាងលើនឹងបកស្រាយក្នុងចំណុចមរណភាពនៃមតកជន (១.៣.១.១) និងការបាត់ខ្លួននៃមតកជន (១.៣.១.២)។

#### ១.៣.១.១ មរណភាពនៃមតកជន

ជាការពិតណាស់ ច្បាប់បានអនុញ្ញាតឲ្យសន្តតិកម្មត្រូវបានយកមកអនុវត្ត ហើយមិនអនីត្យានុកូលភាពលុះត្រាតែមតកជនបានទទួលមរណភាព ហើយនៅពេលដែលមតកជនទទួលមរណភាពសន្តតិកម្មត្រូវបានចាប់ផ្ដើម។[60] បន្ថែមពីនេះ មរណភាពរបស់មតកជនត្រូវមានភស្តុតាងដែលជាសាកសពរបស់មតកជន មកបង្ហាញថា

[59] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦២។

[60] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៤៥ កថាខណ្ឌទី ១។

មានការស្លាប់ ហើយមរណភាពរបស់មតកជនមិនអាចសម្រេចបានដោយមាត់របស់ជនណាម្នាក់បាននោះទេ ព្រោះអាចធ្វើឲ្យមានវិវាទណាមួយ ហេតុដូចនេះហើយ ទើបមរណភាពរបស់មតកជនត្រូវតែមានសំបុត្រដែលបញ្ជាក់ចេញពីមន្ត្រីអត្រានុកូលដ្ឋាន អំពីការទទួលមរណភាពរបស់មតកជន ពេលនោះទើបសន្តតិកម្មត្រូវចាប់ផ្ដើម។ ការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាពត្រូវធ្វើយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព។[61]

### ១.៣.១.២ ការបាត់ខ្លួននៃមតកជន

ការបាត់ខ្លួន សំដៅលើការបាត់ជនណាម្នាក់ពីទីលំនៅឋានខ្លួន ឥតមានដំណឹងជំនួយអ្វីសោះ ឥតមាននរណាដឹងថាជននោះស្លាប់ ឬរស់។[62] កាលណាមានករណីបាត់ខ្លួនលើជនណាម្នាក់ នោះអាចនាំឲ្យមានការខូចប្រយោជន៍ដល់ជន ដែលអាចទទួលបានប្រយោជន៍ពីជនដែលបាត់ខ្លួននោះ ហេតុនេះទើបជនដែលពាក់ព័ន្ធនោះអាចដាក់ពាក្យប្រកាសអំពីការបាត់ខ្លួនបាន។ បន្ថែមពីនេះ ការបាត់ខ្លួនមាន ២ ករណី៖

- ករណីទី១ គឺការបាត់ខ្លួនធម្មតា ដែលត្រូវមានល័ក្ខខ័ណ្ឌមិនដឹងថានៅរស់ ឬទទួលមរណភាពរយៈពេលយ៉ាងតិច៥(ប្រាំ)ឆ្នាំ ហើយតុលាការត្រូវប្រកាសអំពីការបាត់ខ្លួននោះតាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ដូចជាសហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្ដាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន។ ប៉ុន្តែក្នុងករណីនេះ មិនរួមបញ្ចូលមេឃុំ ចៅសង្កាត់ ឬព្រះរាជអាជ្ញាជាអ្នកអាចដាក់ពាក្យសុំទេ។ នេះគឺដោយសារតែគ្រួសារ កំពុងទន្ទឹងចាំការត្រឡប់មកវិញរបស់បុគ្គលដែលអវត្តមាននោះ តែប្រសិនបើអនុញ្ញាតឲ្យរដ្ឋអំណាច ជាអាទិ៍ អាចដាក់ពាក្យសុំឱ្យតុលាការប្រកាសអំពីការបាត់ខ្លួនទៅ គឺមិនសមរម្យឡើយ។
- ករណីទី២ គឺការបាត់ខ្លួនក្នុងលក្ខណៈពិសេស (គ្រោះថ្នាក់) ដូចជាសង្គ្រាម ការលិចនាវា រញ្ជួយផែនដី អគ្គីភ័យ ស៊ូណាមិ (រលកយក្ស) ការរអិលផ្ទាំងទឹកកកពីភ្នំ ជាអាទិ៍ ដែលជាមូលហេតុនៃមរណភាពរបស់ជនដែលជួបប្រទះគ្រោះថ្នាក់ទាំងនេះ ហើយការមិនដឹងថានៅរស់ ឬទទួលមរណភាពនោះ មានអំឡុងពេលយ៉ាងតិច១(មួយ)ឆ្នាំ គឺជាល័ក្ខខ័ណ្ឌការប្រកាសអំពីការបាត់ខ្លួន។ តុលាការត្រូវប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ដូចករណីទី១ ដែរ។[63]

ហេតុដូច្នេះហើយ ករណីបាត់ខ្លួនរបស់មតកជនអាចចាប់ផ្ដើមសន្តតិកម្មបាន ដូចករណីនៃមរណភាពរបស់មតកជនផងដែរ។

[61] អនុក្រឹតស្ដីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០, មាត្រា ៣៥ កថាខណ្ឌទី ៣។

[62] អេង សុត, *ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០* (ក្រសួងយុត្តិធម៌, បោះពុម្ពលើកទី១, ១៩៦៧), មាត្រា ៨៧។

[63] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ១, គន្ថីទី១-ទី៣, ៣៣-៣៤។

### ១.៣.២. ទីកន្លែងបើកសន្តតិកម្មតាមច្បាប់

ចំពោះទីកន្លែងក្នុងការបើកសន្តតិកម្ម ក្រមរដ្ឋប្បវេណីបានបញ្ញត្តិថាសន្តតិកម្មត្រូវចាប់ផ្ដើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព។[64] ហេតុដូចនេះ មានន័យថាការបើកសន្តតិកម្ម គឺនៅកន្លែងស្នាក់នៅរបស់មតកជនដែលបាននៅចុងក្រោយ។ តាមក្រមរដ្ឋប្បវេណីបានឲ្យអត្ថន័យនៃពាក្យ "លំនៅឋាន" ថាជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ។[65] ក៏ប៉ុន្តែ មតកជនខ្លះមានលំនៅឋានមិនច្បាស់លាស់ ឬមានលំនៅឋានច្រើន ដែលអាចជាការលំបាកក្នុងការជ្រើសរើសទីកន្លែងបើកសន្តតិកម្ម និងដំណើរការសន្តតិកម្ម។ ហេតុនេះ ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន។[66] ការស្វែងរកលំនៅឋានជាក់លាក់របស់មតកជនក្នុងការបើកសន្តតិកម្ម ដើម្បីងាយស្រួលដឹងថាតុលាការណាដែលមានសមត្ថកិច្ចក្នុងការចាប់ផ្តើមសន្តតិកម្ម ហេតុនេះតុលាការដែលនៅលំនៅឋានរបស់មតកជន គឺជាអ្នកដែលមានសមត្ថកិច្ចក្នុងការដោះស្រាយរឿងក្តី។

[64] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៤៦។
[65] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ៣៤។
[66] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ៣៥។

# ជំពូកទី២
# នីតិវិធីមុនការទទួលសន្តតិកម្មតាមច្បាប់

# ជំពូកទី២
# នីតិវិធីមុនការទទួលសន្តតិកម្មតាមច្បាប់

បន្ទាប់ពីបានសិក្សាជំពូកទី១ ដែលទាក់ទងនឹងសញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់រួចមក នៅក្នុងជំពូកទី២នេះផងដែរ យើងនឹងសិក្សាអំពីនីតិវិធីមុនការទទួលសន្តតិកម្មតាមច្បាប់។ នៅក្នុងជំពូកនេះទៀតសោត យើងបានធ្វើការបែងចែកជា២ផ្នែកធំៗរួមមាន ការអនុវត្តសិទ្ធិរបស់សន្តតិជនក្នុងសន្តតិកម្ម (២.១) និងរបបនៃការគ្រប់គ្រង និងការបែងចែកមត៌កតាមច្បាប់ (២.២)។

## ២.១ ការអនុវត្តសិទ្ធិរបស់សន្តតិជនក្នុងសន្តតិកម្ម

នៅក្នុងផ្នែកទី១ នេះយើងនឹងធ្វើការបកស្រាយអំពីការអនុវត្តសិទ្ធិរបស់សន្តតិជនក្នុងការយល់ព្រមទទួលយកសន្តតិកម្ម និងបោះបង់ចោលសន្តតិកម្មនៅក្នុងចំណុច ២.១.១។ ចំណែកឯចំណុច ២.១.២ វិញ នឹងធ្វើការបរិយាយអំពីការលុបចោលចំពោះការយល់ព្រម ឬបោះបង់សន្តតិកម្ម។

### ២.១.១. ការយល់ព្រម និងការបោះបង់សន្តតិកម្ម

សន្តតិជនមានរយៈពេល៣(បី)ខែ ក្នុងការធ្វើការសម្រេចចិត្តយល់ព្រម ឬបោះបង់ចោលទាំងស្រុង ឬដោយមានកម្រិត នូវសន្តតិកម្មគិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម។[67] ប្រសិនបើអំឡុងពេលនៃការសម្រេចចិត្តនេះវែងពេក អាចនឹងមានឥទ្ធិពលដល់ការអនុវត្តសិទ្ធិរបស់អ្នកមានសិទ្ធិលើបំណុលចំពោះមតកជន ដូច្នេះហើយបានជាមានការកំណត់អំឡុងពេលនេះ។ ក៏ប៉ុន្តែ អំឡុងពេលនេះទៀតសោត គឺអាចធ្វើការពន្យារពេលបានដោយធ្វើការដាក់ពាក្យសុំទៅតុលាការមុនរយៈពេល៣(បី)ខែនេះកន្លងផុតទៅ ក្នុងករណីដែលមត៌កស្ថិតនៅកន្លែងច្រើន ជាអាទិ៍ ដែលធ្វើឲ្យមានការលំបាកក្នុងការសម្រេចចិត្តក្នុងអំឡុងពេល៣(បី)ខែនេះ។ ចំពោះតុលាការដែលបានទទួលពាក្យស្នើសុំនេះ ត្រូវធ្វើការកំណត់អំឡុងពេល ដែលត្រូវពន្យារនេះឲ្យបានច្បាស់លាស់ ដោយវិនិច្ឆ័យទៅតាមចំនួន ឬគុណភាពនៃមត៌ក ឬកាតព្វកិច្ច ដែលទទួលដោយសន្តតិកម្មជាអាទិ៍។[68] យ៉ាងណាមិញ សន្តតិជនអាចធ្វើការស្រាវជ្រាវមត៌កបាន នៅមុនពេលធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្ម។[69]

ចំពោះករណីពិសេសនៃអំឡុងពេលដែលច្បាប់បានកំណត់ បើសន្តតិជនបានទទួលមរណភាពនៅមុនពេលដែលធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្មនេះ ការគណនាអំឡុងពេលត្រូវគិតចាប់ពីពេលដែលសន្តតិជន

[67] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៤៨ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១។
[68] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១០៩-១១០។
[69] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៤៨ កថាខណ្ឌទី ២។

របស់ជននោះបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម។[70] ឧទាហរណ៍៖ ក បានទទួលមរណភាពហើយមានសន្តតិជន ខ និង គ។ ប៉ុន្តែ គ បានទទួលបានមរណភាពមុនពេលធ្វើការយល់ព្រម ឬបោះបង់ក្នុងអំឡុងពេលគិតឲ្យបានដិតដល់ចំពោះមត៌ក ក ដោយ គ មាន ឃ ជាសន្តតិជនជំនួស។ ក្នុងករណីនេះ ឃ ក៏ត្រូវធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្មចំពោះមត៌ក ក ដែរ ដោយអំឡុងពេលគិតឲ្យបានដិតដល់នេះត្រូវគណនាចាប់ពីដែល ឃ បានដឹងថាបានចាប់ផ្តើមសន្តតិកម្មពី គ។ ប្រសិនបើ ឃ បានបោះបង់ចោលនូវសន្តតិកម្មចំពោះមត៌ក គ នោះ ឃ មិនអាចធ្វើការយល់ព្រម ឬបោះបង់ចោលសន្តតិកម្មចំពោះមត៌ក ក បានទេ ពោលគឺ ឃ បានបោះបង់ចោលនូវសន្តតិកម្មទាំងរបស់ គ និង ក។ ផ្ទុយមកវិញ ឃ អាចធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្មចំពោះមត៌ក ក បាន លុះត្រាតែ ឃ បានយល់ព្រមទទួលនូវសន្តតិកម្មចំពោះមត៌ក គ ជាមុនសិន។

ម្យ៉ាងទៀត ក្នុងករណីដែលសន្តតិជនជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅវិញ អំឡុងពេលដែលកំណត់ដោយច្បាប់ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់កំណត់បានដឹងថាសន្តតិកម្មចំពោះជនដែលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅនោះបានចាប់ផ្តើម។[71] មានន័យថា ប្រសិនសន្តតិជនជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ សន្តតិជននោះអាចធ្វើការបង្ហាញឆន្ទៈយល់ព្រម ឬបោះបង់មត៌កបានដោយចាំបាច់ត្រូវមានអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលធ្វើការសម្រេចដើម្បីសាមីខ្លួន ហើយចំពោះអំឡុងពេលគិតឲ្យបានដិតដល់របស់សន្តតិជនដែលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ត្រូវគណនាចាប់ពីពេលដែលអ្នកអាណាព្យាបាលរបស់អនីតិជននោះត្រូវបានជ្រើសតាំង។

បន្ថែមពីនេះទៀត ក្នុងករណីពិសេសដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឲ្យគ្រប់ចំនួនបាន បើសន្តតិជនមិនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬស្ថានភាពផ្សេងៗទៀត នោះអំឡុងពេលដែលច្បាប់កំណត់ត្រូវគណនាចាប់ពីពេលដែលសន្តតិជននោះដឹងពីអត្ថិភាពនៃកាតព្វកិច្ចនោះ។[72]

### ២.១.១.១ ការយល់ព្រមទទួលយកសន្តតិកម្ម

ការយល់ព្រមទទួលបន្តនូវសន្តតិកម្ម គឺជាការយល់ព្រមទទួលបន្តនូវទំនាក់ទំនងទ្រព្យសម្បត្តិ ក៏ដូចជាសិទ្ធិ និងករណីយកិច្ចពីមតកជន។ នេះមានន័យថា នៅក្នុងករណីអ្នកស្លាប់មានបំណុលកាលនៅរស់ បំណុលនោះក៏ត្រូវដាក់បញ្ចូលក្នុងមត៌កផងដែរ។ តាមរយៈនេះហើយ ទើបមានករណីខ្លះបំណុលមានច្រើនជាងទ្រព្យសកម្ម។ នៅក្នុងករណីបែបនេះក៏ដោយ តើបុគ្គលដែលក្លាយជាសន្តតិជនត្រូវតែទទួលសន្តតិកម្មដែរឬទេ? បើសិនជាពិចារណាពីទស្សនៈអំពីស្វ័យភាពនៃឆន្ទៈរបស់បុគ្គល យើងត្រូវតែផ្តល់ឱកាសឱ្យសន្តតិជនអាចសម្រេចចិត្ត

[70] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៤៩។
[71] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥០។
[72] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥១ កថាខណ្ឌទី ១។

ដោយខ្លួនឯង។ ដូចនេះ ក្រមរដ្ឋប្បវេណីបានទទួលស្គាល់នូវសិទ្ធិរបស់សន្តតិជនក្នុងការជ្រើសរើសយកការបដិសេធទាំងស្រុង ចំពោះការទទួលទ្រព្យសម្បត្តិបន្ត (ការបោះបង់សន្តតិកម្ម) ឬការទទួលយកទ្រព្យសម្បត្តិទាំងស្រុង (ការយល់ព្រមទាំងស្រុង) ឬទទួលខុសត្រូវក្នុងការសងកាតព្វកិច្ចជាដើម ក្នុងកម្រិតនៃទ្រព្យសម្បត្តិសកម្មដែលបានធ្វើសន្តតិកម្ម (ការយល់ព្រមដោយកម្រិត)។ គួរឲ្យកត់សម្គាល់ដែរថា សន្តតិជនពុំមានជម្រើសក្នុងការទទួលសន្តតិកម្មតែទ្រព្យសម្បត្តិសកម្ម ហើយមិនទទួលកាតព្វកិច្ចចំពោះទ្រព្យអកម្មនោះទេ។

**ក. ការទទួលយកទាំងស្រុង**

ជាទូទៅ ក្រោយពីធ្វើការពិចារណាក្នុងអំឡុងពេលដែលបានកំណត់រួចហើយ សន្តតិជនអាចធ្វើការសម្រេចទទួលយកសន្តតិកម្មនោះទាំងស្រុង ក្នុងករណីខ្លួនយល់ឃើញថានឹងទទួលបានផលប្រយោជន៍ពីសន្តតិកម្មនោះ។ ការយល់ព្រមទាំងស្រុង សំដៅទៅលើករណីដែលសន្តតិជនមានឆន្ទៈបានធ្វើការយល់ព្រមទាំងស្រុង ដោយទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះដោយគ្មានកម្រិត។[73] យ៉ាងណាមិញ ការយល់ព្រមទាំងស្រុង គឺមិនតម្រូវឲ្យមានការដាក់ពាក្យស្នើសុំទៅតុលាការ ដូចការយល់ព្រមមានកម្រិត និងការបោះបង់សន្តតិកម្មនោះទេ មានន័យថាការយល់ព្រមទាំងស្រុងតម្រូវឲ្យមានការយល់ព្រមតាមការបង្ហាញឆន្ទៈគឺគ្រប់គ្រាន់ហើយ។[74] ម្យ៉ាងទៀត ដោយសារការបង្ហាញឆន្ទៈ និងសកម្មភាពជាម្ចាស់កម្មសិទ្ធិទៅលើមត៌កនេះហើយ ទើបគេអាចកំណត់ថាសន្តតិជននោះទទួលយកសន្តតិកម្មទាំងស្រុង។ ដូចនេះ នៅពេលដែលសន្តតិជនបានយល់ព្រមទាំងស្រុងហើយ បានន័យថាទោះជាមត៌កនោះជាប់បំណុលប៉ុណ្ណាក៏ដោយ ឬបំណុលមានចំនួនច្រើនជាងទ្រព្យសកម្ម ក៏សន្តតិជននោះមានកាតព្វកិច្ចសងនូវបំណុលដែលមាននោះឲ្យអស់ដែរ។ ឧទាហរណ៍៖ ក បានទទួលមរណភាពហើយបានបន្សល់ទុកនូវឡាន ផ្ទះ ព្រមទាំងបំណុល ១០ ០០០$ ឲ្យទៅសន្តតិជន ខ។ ខ បានបង្ហាញឆន្ទៈថាខ្លួនយល់ព្រមទទួលមត៌កទាំងស្រុងទាំងទ្រព្យសកម្ម និងទ្រព្យអកម្មពីមតកជន ក។ ករណីនេះហៅថា ការយល់ព្រមទាំងស្រុង។

មួយវិញទៀត ក្នុងករណីដែលសន្តតិជនបានធ្វើសកម្មភាពណាមួយក្នុងសកម្មភាពខាងក្រោមនេះ គឺត្រូវចាត់ទុកថាសន្តតិជននោះបានយល់ព្រមទាំងស្រុងតាមច្បាប់ ទោះបីជាសន្តតិជននោះបានដាក់ពាក្យសុំទៅតុលាការធ្វើការយល់ព្រមដោយកម្រិត ឬបោះបង់មត៌កក៏ដោយ។ សកម្មភាពទាំងនោះមានដូចជា៖

- សន្តតិជនបានចាត់តែងមត៌កនោះទាំងអស់ ឬមួយភាគ ប៉ុន្តែលើកលែងតែសកម្មភាពរក្សា និងសកម្មភាពត្រឹមជាការគ្រប់គ្រង។
- សន្តតិជនមិនបានធ្វើការយល់ព្រមដោយកម្រិត ឬបោះបង់មត៌កក្នុងអំឡុងពេលនៃការយល់ព្រម ឬ

[73] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥៤។
[74] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១១៥។

បោះបង់សន្តតិកម្មដែលមានចែងក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណី។

- សន្តតិជនបានយល់ព្រមដោយកម្រិត ឬបោះបង់មត៌ក ប៉ុន្តែសន្តតិជននោះបានលាក់មត៌កទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មត៌កទាំងនោះដើម្បីខ្លួន។ លើកលែងតែ នៅក្រោយពេលដែលជនដែលក្លាយជាសន្តតិជន ដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម។[75]

### ខ. ការទទួលយកមានកម្រិត

ក្រៅពីការយល់ព្រមទាំងស្រុង ច្បាប់ក៏បានបើកសិទ្ធិឲ្យសន្តតិជនសម្រេចទទួលយកសន្តតិកម្មដោយមានកម្រិតផងដែរ បានន័យថាទទួលយកតែចំណែកណាមួយប៉ុណ្ណោះ។ ការយល់ព្រមដោយមានកម្រិត សំដៅទៅលើករណីដែលសន្តតិជនបានយល់ព្រមដោយបម្រុងទុកនូវកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ[76] ពោលគឺសន្តតិជនត្រូវបានក្លាយទៅជាកូនបំណុលដោយទទួលនូវកាតព្វកិច្ចទាំងអស់ពីមតកជន ប៉ុន្តែសន្តតិជនអាចកម្រិតនូវការទទួលខុសត្រូវសងនេះ ត្រឹមតែកម្រិតនៃមត៌កដែលខ្លួនទទួលបានពីសន្តតិកម្ម។ បានន័យថាបើសន្តតិជននោះទទួលចំណែកមត៌កប៉ុន្មានភាគ សន្តតិជននោះត្រូវទទួលកាតព្វកិច្ចនោះស្មើនឹងចំណែកភាគដែលគេយល់ព្រមទទួល ពោលគឺទ្រព្យសកម្មមានកម្រិតភាគស្មើនឹងទ្រព្យអកម្ម។

ឧទាហរណ៍៖ ប្រសិនបើបុគ្គល ក ដែលជាសន្តតិជនរបស់មតកជន ខ បានយល់ព្រមទទួលសន្តតិកម្មត្រឹមតែ ១/២(មួយភាគពីរ) នៃមត៌ករបស់មតកជន ខ នោះបុគ្គល ក ត្រូវទទួលកាតព្វកិច្ច ១/២(មួយភាគពីរ) នៃបំណុលរបស់មតកជន ខ ដូចគ្នា។ ដូចនេះ សន្តតិជននោះត្រូវធ្វើការសងនូវកាតព្វកិច្ចដែលទទួលបានពីសន្តតិកម្ម ត្រឹមកម្រិតនៃមត៌កដែលទទួលបានពីសន្តតិកម្មតែប៉ុណ្ណោះ។

ម៉្យាងទៀត ប្រសិនបើសន្តតិជនស្ម័គ្រចិត្តសងកាតព្វកិច្ចលើមត៌កសកម្មក៏ដោយ ក៏ការសងនេះមានសុពលភាពដែរ ហើយចំណែកនៃកាតព្វកិច្ចដែលលើសមត៌កសកម្មនេះហៅថា កាតព្វកិច្ចធម្មជាតិ។ ជាក់ស្តែងចំពោះករណីដែលសន្តតិជនមានច្រើននាក់ ការយល់ព្រមមានកម្រិតនេះអាចធ្វើទៅបាន លុះត្រាតែសហសន្តតិជននោះបានធ្វើការចូលរួមទាំងអស់។[77] ម៉្យាងទៀត ការយល់ព្រមដោយមានកម្រិតចាំបាច់ត្រូវតែមាននីតិវិធីជម្រះបញ្ជីនូវមត៌ក ដើម្បីឲ្យមានសមភាពក្នុងការសងកាតព្វកិច្ចចំពោះម្ចាស់បំណុលរបស់មតកជន ហើយត្រូវមានការឯកភាពក្នុងការសងនេះពីសហសន្តតិជនទាំងអស់ ដោយសារតែក្នុងករណីបើមានសន្តតិជនមួយចំនួនយល់ព្រមទាំងស្រុង ហើយបានអះអាងនូវមត៌កនោះ នោះការជម្រះបញ្ជីមត៌កមិនអាចធ្វើទៅបានល្អនោះទេ។ លើសពីនេះទៅទៀត ក្នុងករណីសន្តតិជនមួយចំនួនបានបោះបង់មត៌ក នោះជននោះត្រូវចាត់ទុកថាមិនមែនជាសន្តតិជន

[75] ក្រមរដ្ឋប្បវេណីនៃ ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥៥។

[76] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥៦ កថាខណ្ឌទី ១។

[77] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥៦ កថាខណ្ឌទី ២។

តាំងពីដំបូង ហើយសន្តតិជនដែលនៅសេសសល់អាចយល់ព្រមដោយមានកម្រិតរួមគ្នាបាន។ បន្ថែមពីនេះ ក្នុងករណីដែលសន្តតិជនមួយចំនួនក្នុងសន្តតិជនដែលយល់ព្រមដោយកម្រិត ដោយមានហេតុផលថាការយល់ព្រមតាមច្បាប់កើតឡើងក្រោយការយល់ព្រមមានកម្រិត (មាត្រា ១២៥៩ នៃក្រមរដ្ឋប្បវេណី) នោះការទទួលខុសត្រូវនឹងមានលក្ខណៈដូចគ្នានឹងការយល់ព្រមទាំងស្រុង ហើយមត៌កទាំងអស់ត្រូវឆ្លងកាត់នីតិវិធីជម្រះបញ្ជីមត៌ក។ ដូចនេះ សន្តតិជនដែលនឹងទទួលខុសត្រូវតាមមាត្រា ១២៥៩ នៃក្រមរដ្ឋប្បវេណី មិនអាចអះអាងថាខ្លួនមានសិទ្ធិលើចំណែកមត៌កសកម្ម ដែលមិនទាន់បញ្ចប់នីតិវិធីនៃការជម្រះបញ្ជីមត៌កឡើយ។[78] ជាងនេះទៅទៀត ការយល់ព្រមដោយកម្រិតគឺត្រូវធ្វើតាមទៅតាមវិធី និងអានុភាពដូចខាងក្រោម៖

### ខ.១ វិធីនៃការទទួលយកមានកម្រិត

នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មដោយមានកម្រិតហើយ សន្តតិជនមិនអាចគ្រាន់តែធ្វើការនិយាយទទួលយកដោយផ្ទាល់មាត់បាននោះទេ។ ដើម្បីធ្វើការយល់ព្រមដោយមានកម្រិត សន្តតិជនត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំទៅតុលាការអំពីការយល់ព្រមនេះ នៅក្នុងអំឡុងពេលដែលច្បាប់កំណត់[79] មានន័យថានៅក្នុងអំឡុង៣(បី)ខែ គិតចាប់ពីដែលបានដឹងថាសន្តតិកម្មបានចាប់ផ្ដើមចំពោះខ្លួន ប៉ុន្តែអំឡុងពេលនេះអាចពន្យារទៀតបាន តាមការដាក់ពាក្យសុំទៅតុលាការដោយសន្តតិជន។[80]

ក្នុងករណីសហសន្តតិកម្ម សហសន្តតិជនទាំងអស់ត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីធ្វើការយល់ព្រមដោយកម្រិត ហើយចំពោះការគណនាអំឡុងពេលដែលកំណត់តាមច្បាប់វិញ គឺត្រូវគិតចាប់ពីពេលដែលសន្តតិជនចុងក្រោយគេដឹងថា សន្តតិកម្មបានចាប់ផ្ដើមជាមូលដ្ឋាន ដើម្បីការពារសិទ្ធិរបស់សន្តតិជនដែលដឹងអំពីការចាប់ផ្ដើមសន្តតិកម្មក្រោយគេ។ នៅពេលដាក់ពាក្យស្នើសុំទៅតុលាការ សន្តតិជនត្រូវដាក់បញ្ជីសារពើភ័ណ្ឌនៃមត៌ក ដោយតម្រូវឲ្យសរសេរបញ្ជាក់នូវទ្រព្យសកម្ម និងទ្រព្យអកម្មដែលសន្តតិជនបានទទួលនាពេលចាប់ផ្ដើមសន្តតិកម្មទាំងអស់ នៅក្នុងកម្រិតមួយដែលខ្លួនអាចដឹង។ បញ្ជីនេះធ្វើឡើងដើម្បីធ្វើការរាយនាមវត្ថុដែលជាមត៌កដែលគេយល់ព្រមទទួលយក ក្នុងគោលបំណងឲ្យតុលាការដឹងថាទ្រព្យសម្បត្តិដែលជាមត៌កមានអ្វីខ្លះ និងដឹងថាសន្តតិជនទទួលយកនូវទ្រព្យសម្បត្តិខ្លះ ដែលងាយស្រួលដល់តុលាការគណនានៃតម្លៃ និងកាតព្វកិច្ចរបស់សន្តតិជន។ ក្នុងករណីមិនបានធ្វើការបញ្ជាក់ត្រឹមត្រូវដោយចេតនាក្នុងបញ្ជីសារពើភ័ណ្ឌទេនោះ នឹងត្រូវចាត់ទុកថាជាការយល់ព្រមទាំងស្រុង។[81]

[78] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១១៧-១១៨។

[79] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥៧។

[80] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៤៨ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២។

[81] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១១៨-១១៩។

### ខ.២ អានុភាពនៃការទទួលយកមានកម្រិត

នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មដោយមានកម្រិតហើយ អានុភាពនៃសន្តតិកម្មក៏មានត្រឹមតែកម្រិតចំនួនដែលបានទទួលតែប៉ុណ្ណោះ ពោលគឺអានុភាពជាសារជាតុនៃការយល់ព្រមដោយកម្រិតនេះ គឺម្ចាស់បំណុលរបស់មតកជន ពុំអាចតាមទាមទារឲ្យសន្តតិជនទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះឡើយ។[82] បានន័យថា សន្តតិជនមានកាតព្វកិច្ចត្រូវសងចំពោះកាតព្វកិច្ចតាមសមាមាត្រនឹងភាគដែលទទួលបានតែប៉ុណ្ណោះ ដូចនេះ ម្ចាស់បំណុលមិនអាចធ្វើការប្តឹងទាមទារចំពោះសន្តតិជន ឲ្យយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះមកសងនូវបំណុល ដែលលើសពីភាគដែលសន្តតិជនទទួលបានជាដាច់ខាត។ ទោះជាមតកជនជំពាក់ម្ចាស់បំណុលច្រើនយ៉ាងណាក៏ដោយ នៅពេលសន្តតិជនបានសងនូវកាតព្វកិច្ចចំពោះសន្តតិកម្មរួច ម្ចាស់បំណុលមិនអាចបង្ខំឲ្យសន្តតិជនសងបន្ថែមពីលើទៀតនោះទេ លុះត្រាតែសន្តតិជននោះយល់ព្រមសងដោយស្ម័គ្រចិត្ត។

ម៉្យាងទៀត សិទ្ធិ និងកាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយព្យាកុលភាពឡើយ[83] ព្រោះថាទ្រព្យសម្បត្តិដែលជាមត៌ករបស់មតកជននេះ ត្រូវយកទៅជម្រះបញ្ជីជាមុនសិនមុននឹងធ្វើការបែងចែកមកឲ្យសន្តតិជនគឺធ្វើការគណនាកាត់កងជាមួយបំណុលជាមុនសិន ដើម្បីការពារផលប្រយោជន៍របស់សន្តតិជនផ្សេងទៀត។ មានន័យថា ទោះបីជាមានការយល់ព្រមដោយកម្រិតក៏ដោយ តាមផ្លូវច្បាប់មត៌កដែលធ្លាក់ទៅសន្តតិជន ត្រូវធ្វើការជម្រះបញ្ជីផ្សេងពីទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជន ហេតុនេះសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់សន្តតិជន និងមតកជនមិនអាចរលត់ដោយព្យាកុលភាពទេ ពោលគឺចាំបាច់ត្រូវធ្វើការជម្រះដោយនីតិវិធីដូចគ្នានឹងការជម្រះបញ្ជីសិទ្ធិលើបំណុល និងកាតព្វកិច្ចផ្សេងដែរ។

### ២.១.១.២ ការបោះបង់ចោលសន្តតិកម្ម

ចំពោះបុគ្គលដែលមានឆន្ទៈបោះបង់ចោលនូវសន្តតិកម្មដែលទទួលបានពីមតកជន ត្រូវធ្វើការដាក់ពាក្យស្នើសុំទៅតុលាការ ក្នុងអំឡុងពេលដែលច្បាប់កំណត់ក្នុងអំឡុងពេល៣(បី)ខែ គិតចាប់ពីពេលដែលដឹងថាសន្តតិកម្មបានចាប់ផ្តើមចំពោះខ្លួន។[84] បុគ្គលដែលបានធ្វើការបោះបង់ចំណែកមត៌ក ត្រូវចាត់ទុកថាបុគ្គលនោះមិនមែនជាសន្តតិជនចំពោះសន្តតិកម្មនោះតាំងពីដំបូងមក។[85] ក្នុងករណីសហសន្តតិជន បើមានតែជនមួយចំនួនដែលបោះបង់សន្តតិកម្ម សន្តតិជនដទៃទៀតជាអ្នកទទួលចំណែកមត៌កបន្ត ចំណែកអ្នកដែលនៅលំដាប់បន្ទាប់ លុះត្រា

[82] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥៨ កថាខណ្ឌទី ១។
[83] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥៨ កថាខណ្ឌទី ២។
[84] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦០។
[85] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦១។

សហសន្តតិជននៅលំដាប់មុនទាំងអស់បានបោះបង់ចំណែកមត៌ក ទើបមានសិទ្ធិទទួលសន្តតិកម្មនោះបាន។

### ២.១.២ ការលុបចោលការយល់ព្រម ឬការបោះបង់សន្តតិកម្ម

ការលុបចោលនៃការយល់ព្រម ឬបោះបង់សន្តតិកម្មរបស់សន្តតិជន អាចធ្វើឡើងទៅបានលុះត្រាតែមានមូលហេតុសមហេតុផលដែលច្បាប់បានកំណត់ជាក់លាក់ ព្រមទាំងមានការកម្រិតនូវរយៈពេលជាក់លាក់យ៉ាងត្រឹមត្រូវក្នុងការលុបចោលនេះផងដែរ។

#### ២.១.២.១ មូលហេតុនៃការលុបចោលការយល់ព្រម ឬការបោះបង់សន្តតិកម្ម

ការយល់ព្រម និងការបោះបង់សន្តតិកម្មដែលបានធ្វើម្តងហើយ មិនអាចលុបចោលបានឡើយ ទោះបីជានៅក្នុងអំឡុងពេលដែលច្បាប់បានកំណត់ក៏ដោយ។[86] ការកម្រិតនូវសិទ្ធិលុបចោលនេះ ដោយសារតែការយល់ព្រម និងការបោះបង់សន្តតិកម្មនេះមានឥទ្ធិពលយ៉ាងខ្លាំងទៅលើផលប្រយោជន៍របស់ជនពាក់ព័ន្ធ ដូចជាសន្តតិជនដែលមានលំដាប់បន្ទាប់ ឬជនដែលមានសិទ្ធិលើបំណុលដែលទទួលដោយសន្តតិកម្ម ជាអាទិ៍ មានន័យថាក្នុងការអនុវត្តសិទ្ធិរបស់សន្តតិជនដែលយល់ព្រម និងបោះបង់សន្តតិកម្មនេះមិនមែនមានឥទ្ធិពលត្រឹមខ្លួនឯងតែម្នាក់ប៉ុណ្ណោះទេ គឺមានឥទ្ធិពលដល់ជនដទៃដែលមានពាក់ព័ន្ធជាមួយសន្តតិកម្មនេះតែម្តង។ ហេតុនេះហើយ ច្បាប់មិនអនុញ្ញាតឲ្យសន្តតិជនធ្វើការលុបចោលការសម្រេចចិត្តយល់ព្រម ឬបោះបង់របស់ខ្លួនដោយងាយៗបាននោះទេ។

យ៉ាងណាមិញ ទោះបីជាច្បាប់បានរិតត្បិតត្រង់ការលុបចោលការយល់ព្រម ឬបោះបង់សន្តតិកម្មយ៉ាងណាក៏ដោយ ប៉ុន្តែក្នុងករណីខ្លះច្បាប់ក៏បានបើកសិទ្ធិឲ្យសន្តតិជន លុបចោលលើការសម្រេចចិត្តរបស់ខ្លួននេះបានផងដែរ ដើម្បីការពារដល់ផលប្រយោជន៍ និងផលប៉ះពាល់ដែលអាចកើតឡើងចំពោះខ្លួន ដែលការលុបចោលនូវការយល់ព្រម និងបោះបង់សន្តតិកម្មនេះអាចធ្វើទៅបាន ក្នុងករណីដែលមានមូលហេតុថាមានវិការៈក្នុងការបង្ហាញឆន្ទៈ[87] ដូចជាការសម្រេចចិត្តដោយមានការភាន់ច្រឡំ ការឆបោក និងការគម្រាមកំហែង ជាអាទិ៍។ ឧទាហរណ៍៖ ក្នុងករណីដែល ក និង ខ ជាសហសន្តតិជន ហើយ ក បានធ្វើការគម្រាមកំហែងឲ្យ ក បោះបង់សន្តតិកម្មចោលដើម្បីខ្លួនទទួលមត៌កតែឯង។ ក្នុងករណីដែលមានវិការៈក្នុងការបង្ហាញឆន្ទៈបែបនេះ មានភាពចាំបាច់ក្នុងការការពារសិទ្ធិរបស់សន្តតិជនដែលបានបង្ហាញឆន្ទៈនេះ។ ហេតុនេះ ទើបច្បាប់បើកសិទ្ធិនូវការទទួលយកសិទ្ធិលុបចោលរបស់ជននោះ។

#### ២.១.២.២ រយៈពេលនៃការលុបចោលការយល់ព្រម ឬការបោះបង់សន្តតិកម្ម

រយៈពេលដែលអាចលុបចោលការយល់ព្រម ឬបោះបង់សន្តតិកម្ម គឺជាពេលវេលាសម្រាប់ឲ្យសន្តតិជនដែលបានយល់ព្រម ឬបោះបង់សន្តតិកម្មអាចពិចារណាសារជាថ្មីម្តងទៀត ទៅលើការសម្រេចចិត្តរបស់ខ្លួនទៅ

[86] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥២ កថាខណ្ឌទី ១។
[87] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥២ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១។

លើសន្តតិកម្ម។ ប៉ុន្តែសិទ្ធិលុបចោលនេះនឹងត្រូវរលត់ បើពុំបានអនុវត្តក្នុងអំឡុងពេល៦(ប្រាំមួយ)ខែ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិ ឬក្នុងករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលក្នុងអំឡុងពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម។[88] បានន័យថា អំឡុងពេលសម្រាប់ការលុបចោលសិទ្ធិមានរយៈពេលកំណត់ត្រឹម៦(ប្រាំមួយ)ខែ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ប្រសិនបើគេរកឃើញថាការយល់ព្រម ឬបោះបង់សន្តតិកម្មដែលបានធ្វើឡើងដោយសារមានវិការៈ។ លើសពីនេះទៅទៀត អំឡុងពេលដែលអាចលុបចោលបានអាចមានរហូតទៅដល់រយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ក្នុងករណីដែលសិទ្ធិនេះពុំទាន់អនុវត្តទាល់តែសោះ។ ចំណុចខុសគ្នារវាង រយៈពេល៦(ប្រាំមួយ)ខែ និងរយៈពេល៥(ប្រាំ)ឆ្នាំ នៃអំឡុងពេលសិទ្ធិលុបចោលជាចំណុចមួយគួរឲ្យកត់សម្គាល់ ដោយសារការលុបចោលគឺឈរលើមូលហេតុមានវិការៈដូចគ្នា ប៉ុន្តែរយៈពេលនៃការអនុវត្តសិទ្ធិលុបចោលមានរយៈពេលខុសគ្នាទៅវិញ។ មូលហេតុគឺដោយសារតែរយៈពេល ៦(ប្រាំមួយ)ខែ ត្រូវបានកំណត់នៅក្នុងន័យសន្តតិជនដែលមានបំណងក្នុងការលុបចោលនោះ អាចផ្តល់សច្ចានុមតិបានក្នុងរយៈពេលនោះ។ រីឯ រយៈពេល៥(ប្រាំ)ឆ្នាំវិញ ត្រូវបានកំណត់ក្នុងន័យសន្តតិជនដែលមិនមានឱកាសក្នុងការផ្តល់សច្ចានុមតិ ក្នុងករណីនេះច្បាប់បានបើកសិទ្ធិឲ្យពួកគាត់រហូតដល់ទៅ៥(ប្រាំ)ឆ្នាំ គិតចាប់ពីសន្តតិកម្មបានចាប់ផ្តើម។

ចំពោះបុគ្គលដែលមានបំណងចង់លុបចោលការយល់ព្រមដោយកម្រិត ឬការបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំលុបចោលនោះទៅតុលាការ។[89] ម្យ៉ាងទៀត ក្នុងករណីដែលមានការលុបចោលនូវសកម្មភាពចាត់ចែង ដែលត្រូវបានចាត់ទុកថាជាការជាការយល់ព្រមទាំងស្រុង ដោយសារមូលហេតុនៃការភាន់ច្រឡំ ជាអាទិ៍ ការយល់ព្រមទាំងស្រុងនោះនឹងបាត់បង់ ដូច្នេះមិនចាំបាច់ដាក់ពាក្យសុំលុបចោលទៅតុលាការទេ។

## ២.២ របបនៃការគ្រប់គ្រង និងការបែងចែកមត៌កតាមច្បាប់

នៅក្នុងផ្នែកទី២នេះផងដែរ យើងនឹងធ្វើការបកស្រាយអំពីរបបនៃការគ្រប់គ្រង និងការបែងចែកមត៌កតាមច្បាប់។ មុននឹងទទួលបានការធ្វើការសម្រេចចិត្តពីសន្តតិជនថា យល់ព្រមទទួលយក ឬបោះបង់ចោលសន្តតិកម្មនោះ យើងត្រូវមានការគ្រប់គ្រង និងបែងចែកទៅលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសន្តតិកម្មទាំងអស់នោះជាមុនសិន។ ជាតួយ៉ាង នៅក្នុងផ្នែកទី២នេះ យើងនឹងធ្វើការបែងចែងជាពីរចំណុច គឺនៅក្នុងចំណុច ២.២.១ នឹងធ្វើការបកស្រាយពីការគ្រប់គ្រងមត៌ក ចំណែកឯចំណុច ២.២.២ វិញ នឹងធ្វើការបកស្រាយពីការបែងចែកមត៌ក។

### ២.២.១ ការគ្រប់គ្រងមត៌ក

ការគ្រប់គ្រងមត៌កជារឿងដ៏សំខាន់សម្រាប់សន្តតិជន និងជនដែលពាក់ព័ន្ធទៅនឹងមត៌កនៅក្រោយពេលដែលមតកជនបានទទួលមរណភាព។ ហេតុនេះហើយទើបក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិទទួលស្គាល់នូវ

[88] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥២ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២។

[89] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៥២ កថាខណ្ឌទី ៣។

បុគ្គលដែលមានសិទ្ធិគ្រប់គ្រងទៅលើមត៌ករបស់មតកជនដែលបានទទួលមរណភាពនោះ។ ចំពោះបុគ្គលដែលអាចគ្រប់គ្រងមត៌កមាន ៣ ប្រភេទគឺ ការគ្រប់គ្រងដោយសន្តតិជន ការគ្រប់គ្រងដោយអ្នកប្រតិបត្តិមតកសាសន៍ និងការគ្រប់គ្រងមត៌កបណ្តោះអាសន្នដោយការជ្រើសតាំងដោយតុលាការ។

### ២.២.១.១ ការគ្រប់គ្រងមត៌កដោយសន្តតិជន

សន្តតិជនរូបណាដែលបានកាន់កាប់មត៌ក នៅពេលដែលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និងគ្រប់គ្រងមត៌កនោះដោយប្រុងប្រយ័ត្នរហូតដល់ពេលធ្វើការបែងចែកមត៌កបានចាប់ផ្តើម។[90] នេះគឺដោយសារតែ គេចង់ថែរក្សាមត៌កនោះឲ្យមានស្ថានភាពដដែល រហូតដល់ពេលធ្វើការបែងចែកមត៌ក។ ម៉្យាងទៀត ចំពោះមត៌កដែលមិនមានការកាន់កាប់ដោយសន្តតិជនណាមួយទេនោះ សហសន្តតិជនត្រូវធ្វើការរក្សាទុក និងគ្រប់គ្រងទាំងនោះរួមគ្នាដោយសុចរិត និងស្មោះត្រង់ នៅពេលដែលមតកជនទទួលមរណភាព។ ជាងនេះទៅទៀត ទោះបីជាមុនយល់ព្រម ឬបោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែរ។ ទោះបីជាសន្តតិជនរូបនោះបានបោះបង់ចំណែកមត៌ករបស់ខ្លួនក៏ដោយ ក៏កាតព្វកិច្ចនេះមិនអាចទម្លាក់ចោលបានដែរ។ ពោលគឺ សន្តតិជននោះនៅតែមានកាតព្វកិច្ចក្នុងការគ្រប់គ្រងរក្សាទុកនូវមត៌កនោះ រហូតដល់ពេលដែលអ្នកក្លាយជាសន្តតិជន ដោយសារការបោះបង់នេះ អាចចាប់ផ្តើមគ្រប់គ្រងមត៌កនោះបាន ហើយនៅពេលដែលសន្តតិជនថ្មីទាមទារឲ្យប្រគល់មត៌កនោះវិញ សន្តតិជនមុនដែលបានគ្រប់គ្រង និងរក្សាមត៌កនោះ ត្រូវប្រគល់មត៌កនោះទៅឲ្យសន្តតិជនថ្មីជាបន្ទាន់។[91]

ជាងនេះទៅទៀត ក្នុងករណីសន្តតិជនដែលបានធ្វើការយល់ព្រមទទួលមត៌កដោយមានកម្រិត សន្តតិជនរូបនោះមានករណីយកិច្ចបន្តការគ្រប់គ្រងមត៌កដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត។[92] ចំពោះករណីសហសន្តតិជនដែលមិនបានបោះបង់សន្តតិកម្មវិញ សន្តតិជនទាំងនោះនឹងត្រូវទទួលយល់ព្រមដោយកម្រិតទាំងអស់គ្នា ពេលនោះសន្តតិជនដែលត្រូវជ្រើសតាំងជាអ្នកគ្រប់គ្រងដោយតុលាការក្នុងចំណោមសន្តតិជនទាំងនោះ គឺជាអ្នកដែលមានករណីយកិច្ចគ្រប់គ្រងមត៌ក។[93]

### ២.២.១.២ ការគ្រប់គ្រងមត៌កដោយអ្នកប្រតិបត្តិមតកសាសន៍

ក្នុងករណីដែលសន្តតិកម្មធ្វើឡើងតាមរយៈមតកសាសន៍ និងមានកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍នោះមានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេង

[90] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦២ កថាខណ្ឌទី ១។
[91] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦២ កថាខណ្ឌទី ២។
[92] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៨០។
[93] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៨៩។

ទៀតដែលចាំបាច់ពេលចាប់ផ្តើមមុខងាររបស់ខ្លួន ដើម្បីប្រតិបត្តិមតកសាសន៍។[94] ប៉ុន្តែ ក្នុងករណីដែលមតកសាសន៍បានចែងជាក់លាក់នូវទ្រព្យសម្បត្តិណាមួយដូចជា ដីពីរឡូត៍ ឬផ្ទះមួយល្វែងជាអាទិ៍ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិដែលបានចែងជាក់លាក់នោះតែប៉ុណ្ណោះ។ ចំណែកឯទ្រព្យសម្បត្តិដែលមិនមានចែងនៅក្នុងមតកសាសន៍ គឺសន្តតិជន ឬសហសន្តតិជនជាអ្នកគ្រប់គ្រងទៅលើមត៌កទាំងនោះ។[95]

#### ២.២.១.៣ ការគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន

ក្នុងករណីគ្មានអ្នកប្រតិបត្តិមតកសាសន៍ក្នុងការគ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន អច្ច័យលាភី ឬម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការ ដើម្បីធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក។[96] ចំពោះសោហ៊ុយដែលទាក់ទងនឹងមត៌ក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ ប៉ុន្តែចំពោះសោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះវិញ។[97]

### ២.២.២ ការបែងចែកមត៌ក

ការបែងចែកចំណែកមត៌ក អាចធ្វើឡើងដោយមានការព្រមព្រៀងគ្នា ពីសំណាក់សហសន្តតិជន (២.២.២.១) និងការបែងចែកមត៌កតាមរយៈផ្លូវតុលាការ (២.២.២.២)។ ការបែងចែកនេះ ជាចំណុចក្នុងការកំណត់ចំណែករបស់សន្តតិជននីមួយៗ ដែលទទួលស្គាល់ដោយច្បាប់ ហើយបង្កើតបានជាអានុភាពគតិយុត្តមួយក្នុងការយកមកអនុវត្ត។

#### ២.២.២.១ ការបែងចែកតាមការពិភាក្សា

ការបែងចែកមត៌ក ជាគោលការណ៍ធ្វើឡើងតាមការពិភាក្សា និងការព្រមព្រៀងរវាងសហសន្តតិជនទាំងអស់ដោយសារតែក្នុងករណីដែលមានសន្តតិជនច្រើននាក់ នោះមត៌កត្រូវស្ថិតក្នុងក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជនទាំងនោះ ហើយការបែងចែងមត៌កនេះផងដែរ គឺជាការប្តូរគ្នាទៅវិញទៅមករវាងសន្តតិជននីមួយៗនូវចំណែកនៃកម្មសិទ្ធិអវិភាគរបស់សាមីជនម្នាក់ៗ ចំពោះទ្រព្យសម្បត្តិច្រើនដែលជាកម្មសិទ្ធិអវិភាគនេះ។ រួចកំណត់ឲ្យមត៌កនីមួយៗនេះធ្លាក់ជាកម្មសិទ្ធិឯករាជ្យដោយឡែករបស់សហសន្តតិជនណាម្នាក់ ឬជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជនកំណត់មួយ។ ហេតុនេះហើយ បានជាចាំបាច់ត្រូវមានការព្រមព្រៀងរវាងសហសន្តតិជនទាំងអស់ក្នុងការបែងចែកមត៌ក ទោះបីជាសន្តតិជនណាម្នាក់បានទទួលផលប្រយោជន៍ពិសេសច្រើនក៏ដោយ

[94] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦៣។
[95] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១២៤។
[96] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦៤ កថាខណ្ឌទី ១។
[97] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦៥។

ក៏ចាំបាច់តម្រូវឲ្យសន្តតិជននោះចូលរួមក្នុងការពិភាក្សាបែងចែកមត៌ក ដើម្បីឲ្យសន្តតិជននោះបញ្ជាក់អំពីការណ៍នេះដែរ។[98]

ក្រោយពីការចាប់ផ្ដើមសន្តតិកម្ម សហសន្តតិជនអាចចាប់ផ្ដើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បានក្រោយអំឡុងពេល១(មួយ)ខែ បានកន្លងផុត។[99] បានជាក្នុងអំឡុងពេល១(មួយ)ខែ ក្រោយមរណភាពរបស់មតកជននេះ ហាមមិនឲ្យធ្វើការបែងចែកមត៌ក ដោយសារចាំបាច់ត្រូវផ្ដល់ការគោរពចំពោះវិញ្ញាណក្ខ័ន្ធរបស់មតកជន និងត្រូវធ្វើការស្វែងរកសហសន្តតិជន ដែលត្រូវស្រាវជ្រាវមើលថាមតកជនមានកូនមកពីអាពាហ៍ពិពាហ៍មុនដែរឬទេ? ឬមានកូនដែលខ្លួនបានទទួលស្គាល់ឬក៏អត់? បន្ទាប់មកត្រូវកំណត់ថា សហសន្តតិជនយល់ព្រម ឬក៏បោះបង់ចោលសន្តតិកម្ម ដើម្បីកំណត់នូវទំហំនៃសហសន្តតិជន រួចទើបអាចធ្វើការពិភាក្សាដើម្បីបែងចែកមត៌ក។[100] ប៉ុន្តែចំពោះការផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌កនេះផងដែរ សន្តតិជន និងអ្នកគ្រប់គ្រងមត៌ក មិនអាចផ្លាស់ប្ដូរឈ្មោះសិទ្ធិលើមត៌កពីមតកជនទៅឲ្យសន្តតិជន ឬអច្ច័យលាភីក្នុងអំឡុងពេល៣(បី)ខែ នៃអំឡុងពេលនៃការយល់ព្រម ឬបោះបង់សន្តតិកម្មបានឡើយ។ ការផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិលើមត៌កក្នុងអំឡុងពេល៣(បី)ខែនេះ អាចធ្វើទៅបានលុះត្រាតែមានកាតព្វកិច្ចចាំបាច់ក្នុងការសងកាតព្វកិច្ចរបស់មតកជន។[101]

ការពិភាក្សាបែងចែកមត៌កនោះ មិនមែនជាសកម្មភាពចាំបាច់មានទម្រង់ ឬធ្វើជាលាយល័ក្ខណ៍អក្សរនោះទេ។ ក៏ប៉ុន្តែ ចំពោះមត៌កមួយចំនួនដើម្បីផ្ទេរសិទ្ធិ ឬដើម្បីឲ្យមានល័ក្ខខ័ណ្ឌតតាំងចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗនោះ ដូចជាលិខិតជាលាយល័ក្ខណ៍អក្សរ ជាអាទិ៍។[102] នៅពេលដែលធ្វើការពិភាក្សាបែងចែកមត៌ករវាងសហសន្តតិជន សហសន្តតិជនត្រូវពិចារណាដល់មូលដ្ឋាននៃការបែងចែក ដែលត្រូវពិចារណាទៅលើចំណុចសំខាន់ដូចជា ប្រភេទ និងលក្ខណៈនៃវត្ថុ ឬសិទ្ធិដែលមាននៅក្នុងមត៌ក ឬអាយុ មុខរបរ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និងស្ថានភាពផ្សេងទៀត។[103] ក៏ប៉ុន្តែ ប្រសិនបើសហសន្តតិជនទាំងអស់បានធ្វើការព្រមព្រៀងគ្នា ទោះបីជាខ្លឹមសារនៃការព្រមព្រៀងនោះផ្ទុយនឹងចំណុចខាងលើនេះក៏ដោយ តែបើខ្លឹមសារនោះមិនផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អទេ នោះការព្រមព្រៀងនឹងមានអានុភាព។[104] ក្នុងករណីដែលការបែងចែកមត៌កនោះបណ្ដាល

[98] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១២៨។
[99] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១។
[100] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១២៨។
[101] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦៦ កថាខណ្ឌទី១ វាក្យខណ្ឌទី ២ និង មាត្រា ១២៧៧។
[102] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦៦ កថាខណ្ឌទី ២។
[103] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦៧ កថាខណ្ឌទី ១។
[104] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៣០។

ឲ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃនៃមត៌ក សហសន្តតិជនអាចឲ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយតម្រូវឲ្យមានល័ក្ខខ័ណ្ឌតាមវិធីបង់ប្រាក់សម្រួល តាមការពិភាក្សាគ្នារវាងសហសន្តតិជនទាំងនោះ។[105]

ក្នុងករណីដែលមានសហព័ទ្ធក្លាយជាសន្តតិជនពីសន្តតិកម្មដែលជាមត៌ករបស់ប្តី ឬប្រពន្ធខ្លួន សហព័ទ្ធនោះនឹងទទួលបានទ្រព្យសម្បត្តិពាក់កណ្តាល ហើយទ្រព្យសម្បត្តិពាក់កណ្តាលទៀតជាមត៌កដែលជាកម្មវត្ថុនៃការបែងចែក។ បើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសន្តតិកម្មដែលទទួលបាន ជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជនក្នុងពេលចំណងអាពាហ៍ពិពាហ៍ នោះនៅក្នុងការបែងចែកមត៌ក សហព័ទ្ធនោះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគរបស់មតកជនចំពោះទ្រព្យសម្បត្តិរួមនោះ រហូតដល់គ្រប់ចំនួនចំណែកមត៌កដែលនឹងត្រូវទទួលបាន។[106] ម្យ៉ាងទៀត មត៌កដែលមតកជនបានបន្សល់ទុកមិនមែនមានទ្រព្យសកម្មតែប៉ុណ្ណោះនោះទេ គឺមានទាំងកាតព្វកិច្ចដែលសហសន្តតិជននីមួយៗត្រូវទទួលបន្តទៅតាមចំណែកមត៌ករបស់ខ្លួន ទៅតាមសមាមាត្ររបស់សហសន្តតិជនម្នាក់ៗ ដែលជាគោលការណ៍ទទួលខុសត្រូវដោយស្វ័យប្រវត្តិ។ មានន័យថាកាតព្វកិច្ចដែលទទួលបានដោយសន្តតិកម្ម ត្រូវបែងចែកដោយស្វ័យប្រវត្តិជាសមាមាត្រទាំងទ្រព្យសម្បត្តិ ទាំងកាតព្វកិច្ចពេលចាប់ផ្តើមសន្តតិកម្ម និងមិនអាចប្តូរភាគសមាមាត្រនៃបន្ទុកនេះបានទេ ទោះបីជាមានការព្រមព្រៀងគ្នាពីសហសន្តតិជនក៏ដោយ។ ក្នុងករណីដែលមតកជនបានធ្វើអាជីវកម្មដែលមានទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម ដើម្បីធ្វើការព្រមព្រៀងឲ្យសន្តតិជនណាម្នាក់ ឬច្រើននាក់ទទួលកាតព្វកិច្ចពាក់ព័ន្ធនឹងអាជីវកម្មនោះជំនួសឲ្យការបន្តអាជីវកម្ម លុះត្រាតែមានការយល់ព្រមពីម្ចាស់បំណុល និងមានការពិចារណាទៅលើសមត្ថភាពរបស់សកម្មជនពីម្ចាស់បំណុលនោះផងដែរ។[107]

### ២.២.២.២ ការបែងចែកតាមផ្លូវតុលាការ

ក្នុងករណីដែលការពិភាក្សាអំពីការបែងចែកមត៌ករវាងសហសន្តតិជនពុំអាចធ្វើទៅបាន ឬប្រព្រឹត្តដែរ ប៉ុន្តែមិនបានសម្រេច ក្នុងករណីនេះសន្តតិជនណាម្នាក់អាចធ្វើការដាក់ពាក្យសុំតុលាការឲ្យធ្វើការបែងចែកមត៌កនោះបាន។[108] មានន័យថាតុលាការមិនអាចធ្វើការបែងចែកដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានទេ លុះត្រាតែមានពាក្យសុំពីសន្តតិជនណាម្នាក់ ទើបតុលាការអាចធ្វើការបែងចែកមត៌កទាំងនោះបាន។ ម្យ៉ាងទៀត គោលការណ៍ក្នុងការបែងចែកមត៌កតាមការព្រមព្រៀងគ្នា ក៏ជាគោលការណ៍ក្នុងការបែងចែកដោយតុលាការនេះផងដែរ ពោលគឺតុលាការត្រូវធ្វើការពិចារណាទៅល័ក្ខខ័ណ្ឌមួយចំនួនដូចជា មូលដ្ឋាននៃការបែងចែក សិទ្ធិអាទិភាពរបស់

---

[105] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦៧ កថាខណ្ឌទី ២។

[106] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦៨។

[107] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹទី៨-ទី៩, ១៣២។

[108] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧០ កថាខណ្ឌទី ១។

សហព័ទ្ធ សំណាងនៃកាតព្វកិច្ចរបស់មតកជន។ មិនតែប៉ុណ្ណោះ តុលាការត្រូវធ្វើការពិចារណាទៅលើទំនៀមទម្លាប់នៅក្នុងតំបន់នោះ និងមតិលើសពីពាក់កណ្តាលរបស់សហសន្តតិជនផងដែរ។[109] ក៏ប៉ុន្តែ ទោះបីជាមានមតិភាគច្រើនរបស់សហសន្តតិជនក៏ដោយ ប្រសិនបើមតិនោះមិនសមរម្យទេនោះ ក៏តុលាការមិនត្រូវយកមតិនោះដែរ ហើយទោះបីជាមានមតិភាគតិចក៏ដោយ ប្រសិនបើសមរម្យតុលាការគួរតែស្តាប់តាមមតិភាគតិចនោះផងដែរ។

ចំពោះទ្រព្យសម្បត្តិដែលមិនអាចបែងចែកបានដោយគ្មានការព្រមព្រៀង ឬបុគ្គលក្នុងចំណោមសហសន្តតិជនដែលមានសិទ្ធិទទួលមិនយល់ព្រម តុលាការមានឆន្ទានុសិទ្ធិលក់ទ្រព្យសម្បត្តិនោះ ហើយធ្វើការបែងចែកប្រាក់ដែលបានមកពីការលក់នោះ។[110] នីតិវិធីនៃការលក់មត៌កនោះមានដូចជា ការបង្គាប់ដោយតុលាការឲ្យសហសន្តតិជនលក់តាមវិធីឡាយឡុង ជាអាទិ៍។[111] ម៉្យាងទៀត ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយផ្អែកលើសិទ្ធិដែលស្ថិតនៅក្នុងមត៌កនោះ (រាប់បញ្ចូលទាំងផលធម្មជាតិ និងផលស៊ីវិលដែលកើតឡើងពីមត៌ក) ត្រូវស្ថិតនៅក្នុងមត៌កនេះផងដែរ។ ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្មនោះមានដូចជា៖

- ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្មដោយផ្អែកលើសិទ្ធិស្ថិតក្នុងមត៌កនោះ៖ សំដៅទៅលើផលធម្មជាតិ ឬផលស៊ីវិលដែលកើតឡើងពីមត៌កដូចជា ការប្រាក់ដែលកើតឡើងក្រោយពេលចាប់ផ្តើមសន្តតិកម្ម ចំពោះប្រាក់បញ្ញើក្នុងធនាគារដែលជាមត៌ក ជាអាទិ៍។
- ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្មដោយការសងជំនួសនូវការខូចខាត ការបាត់បង់ ឬការបំពានយកកម្មវត្ថុមត៌ក៖ មានដូចជាសិទ្ធិលើបំណុលដែលអាចទាមទារសំណងនៃការខូចខាត ឬប្រាក់សំណងនៃការខូចខាតក្នុងករណីដែលសហសន្តតិជនណាម្នាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ឬតតិយជនណាមួយទទួលបន្ទុកនូវកាតព្វកិច្ចសងសំណងនៃការខូចខាត ដោយសារការធ្វើឲ្យបាត់បង់មត៌កជាដើម។
- ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្មតាមកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ៖ មានដូចជាប្រាក់ដែលបានមកពីការលក់មត៌កដោយសហសន្តតិជនទាំងអស់ ឬដោយតុលាការ។ ប្រាក់ទាំងអស់នេះ សុទ្ធតែជាវត្ថុជំនួសមត៌កហើយដែលជាភាគនៃមត៌កនោះ ដូច្នេះអាចក្លាយជាកម្មវត្ថុនៃការបែងចែកបាន។[112]

**២.២.២.៣ អានុភាពនៃការបែងចែក**

ការបែងចែកមត៌កមានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្មមកម្ល៉េះ។[113] នោះនៅពេលបានបែងចែកមត៌ក ប្រសិនបើទទួលស្គាល់នូវអានុភាពប្រតិសកម្មនេះ បានសេចក្តីថាសន្តតិជន

[109] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧០ កថាខណ្ឌទី ២។

[110] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧១។

[111] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៣៤។

[112] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧២ និងសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ៦, គន្លឹះទី៨-ទី៩, ១៣៥។

[113] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧៣ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១។

ទទួលមត៌កពីមតកជនផ្ទាល់ មិនមែនបានទទួលពីសហសន្តតិជនផ្សេងនោះទេ។ ម៉្យាងទៀតបើធ្វើដូច្នេះ នីតិវិធីនៃការចុះបញ្ជីអចលនវត្ថុ ក៏មិនចាំបាច់ឆ្លងកាត់តាមដំណាក់កាលចុះបញ្ជីនូវកម្មសិទ្ធិអវិភាគរបស់សហសន្តតិជនដែរ មានន័យថាអាចជ្រើសរើសយកនីតិវិធីផ្ទេរកម្មសិទ្ធិផ្ទាល់ពីមតកជន ទៅសន្តតិជនដែលបានលទ្ធកម្មដោយការបែងចែកនេះ។[114] តួយ៉ាង ការបែងចែកនេះពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬបានទទួលល័ក្ខខ័ណ្ឌតតាំងបានឡើយ[115] មានន័យថាការការពារតតិយជនដើម្បីឲ្យសុវត្ថិភាពក្នុងកិច្ចការជំនួញត្រូវបានយកមកអនុវត្ត។ ក្នុងករណីនៃសហសន្តតិជន មត៌កត្រូវស្ថិតនៅក្នុងកម្មសិទ្ធិអវិភាគទៅតាមសមាមាត្រនៃចំណែករបស់សហសន្តតិជននោះ ដូច្នេះទោះបីជាមុនការបែងចែកមត៌កក៏ដោយ ក៏សហសន្តតិជនអាចធ្វើអនុប្បទានចំណែករបស់ខ្លួនទៅឲ្យតតិយជនបាន ឬក៏ម្ចាស់ចំណុលរបស់សន្តតិជនណាម្នាក់អាចរឹបអូសនូវចំណែកមត៌ករបស់សន្តតិជននោះបានដែរ។ ហេតុដូចនេះហើយ បានជាអានុភាពប្រតិសកម្មនៃការបែងចែកនេះមិនត្រូវបានទទួលស្គាល់ ចំពោះតតិយជនដែលបានធ្វើនីតិវិធីចុះបញ្ជី ឬមានល័ក្ខខ័ណ្ឌតតាំងបានឡើយ ប្រសិនបើមានការទទួលស្គាល់អានុភាពប្រតិសកម្មនេះដោយគ្មានល័ក្ខខ័ណ្ឌទេ នឹងធ្វើឲ្យបាត់បង់សុវត្ថិភាពក្នុងកិច្ចការជំនួញ។ តាមលទ្ធផលនេះ ការបែងចែកអាចនឹងបាត់បង់នូវអត្ថន័យ តែពេលនោះសហសន្តតិជនដែលបានទទួលឥទ្ធិពលដោយសារតែវត្តមានរបស់តតិយជននេះ អាចទាមទារឲ្យសហសន្តតិជនដែលបានបង្កើតឲ្យមានមូលហេតុទទួលខុសត្រូវបាន ឬអាចលុបចោលការបែងចែកមត៌កនេះ ដោយយកការភាន់ច្រឡំជាមូលហេតុ ហើយបែងចែកសារជាថ្មីឡើងវិញ។[116]

តាមលទ្ធផលនៃការបែងចែក សហសន្តតិជននីមួយៗដែលបានធ្វើលទ្ធកម្មនូវសិទ្ធិទាក់ទងនឹងទ្រព្យសម្បត្តិដែលមានលិខិត ឬប័ណ្ណបញ្ជាក់សិទ្ធិ សហសន្តតិជននោះអាចទទួលបានលិខិត ឬប័ណ្ណបញ្ជាក់សិទ្ធិនោះបាន[117] ដើម្បីឲ្យការផ្ទេរសិទ្ធិនេះធ្វើឡើងដោយគ្មានការយឺតយ៉ាវ។ ឧទាហរណ៍៖ សន្តតិជនដែលបានទទួលលទ្ធកម្មនូវសិទ្ធិលើប្រាក់បញ្ញើរបស់មតកជន អាចទទួលយកសៀវភៅគណនីធនាគារពីសន្តតិជនដែលបានរក្សាសៀវភៅគណនីនោះទុកបាន។

ក្នុងករណីមានការទទួលស្គាល់សន្តតិជននៅក្រោយពេលមតកជនទទួលមរណភាព ហើយសន្តតិជននោះមិនបានចូលរួមក្នុងការពិភាក្សាបែងចែកមត៌កទេ ប៉ុន្តែដោយសារតែមានការបែងចែកមត៌កហើយ ហើយមានវត្តមានសហសន្តតិជនទាំងអស់រួចទៀតផង នោះការពិភាក្សាដែលបានធ្វើឡើងហើយនោះគឺមានសុពលភាព។

---

114 សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៣៦។

115 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧៣ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២។

116 សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៣៦-១៣៧។

117 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧៣ កថាខណ្ឌទី ២

ចំណែកឯសន្តតិជនដែលបានទទួលស្គាល់ក្រោយនោះ មិនអាចទាមទារឲ្យធ្វើការបែងចែកមត៌កសារជាថ្មីបានទេ ប៉ុន្តែជននោះមានសិទ្ធិទាមទារឲ្យសងបានត្រឹមតែតម្លៃជាប្រាក់តែប៉ុណ្ណោះ។[118] មានន័យថាច្បាប់បានការពារផលប្រយោជន៍របស់សន្តតិជនរូបនោះ ដោយបានផ្តល់សិទ្ធិឲ្យសន្តតិជននោះធ្វើការទាមទារឲ្យទទួលចំណែករបស់ខ្លួនជាតម្លៃក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃបានបែងចែកមត៌កនោះ។[119] យ៉ាងណាមិញ ក្នុងករណីដែលសន្តតិជនត្រូវបានមតកជនទទួលស្គាល់កាលមតកជននៅរស់ ហើយសន្តតិជនផ្សេងទៀតពុំបានដឹង ដែលធ្វើឲ្យការពិភាក្សាការបែងចែកមត៌កនោះមិនមានវត្តមានរបស់សន្តតិជននោះ ឬក្នុងករណីដែលសន្តតិជនត្រូវបានទទួលស្គាល់ក្រោយមរណភាពរបស់មតកជន មុនការបែងចែកមត៌ក ហើយសន្តតិជនផ្សេងទៀតមិនបានយកចិត្តទុកដាក់ដែលធ្វើឲ្យការបែងចែកមត៌កនោះមិនមានវត្តមានសន្តតិជននោះដូចគ្នា ដូច្នេះការបែងចែកទាំងនេះនឹងត្រូវចាត់ទុកជាមោឃភាព។ ក្នុងករណីនេះ ជនដែលត្រូវបានទទួលស្គាល់នោះនៅតែមានសិទ្ធិជាសន្តតិជនដដែល ហើយអាចទាមទារចំពោះសន្តតិជនផ្សេងទៀត ឲ្យធ្វើការមត៌កទាំងនោះសារជាថ្មីឡើងវិញ ដោយសារតែការទាមទារនេះជាការទាមទារឲ្យធ្វើបដិទានសន្តតិកម្ម ដែលអំឡុងពេលនៃការទាមទារនេះមានរយៈពេល ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃបានបែងចែកមត៌កនោះ។[120]

ចំពោះករណីការបែងចែកសិទ្ធិលើបំណុលវិញ ជាទូទៅសិទ្ធិលើបំណុលរបស់មតកជនដែលអាចបែងចែកបាន នឹងត្រូវបែងចែកដោយស្វ័យប្រវត្តិទៅឲ្យសន្តតិជនតាមសមាមាត្រដែលច្បាប់បានកំណត់។[121] ប៉ុន្តែ ក្នុងករណីដែលមានការព្រមព្រៀងគ្នារវាងសហសន្តតិជន សិទ្ធិលើបំណុលនោះអាចយកមកធ្វើជាកម្មវត្ថុនៃការបែងចែកមត៌កបាន ហើយក៏អាចធ្វើការបែងចែកទៅតាមភាគក្រៅពីចំណែកមត៌កដែលកំណត់ដោយច្បាប់បានដែរ។ ក៏ប៉ុន្តែ ការបែងចែកនេះសហសន្តតិជនទាំងអស់ត្រូវជូនដំណឹងពីការបែងចែកនេះ ឬការបែងចែកនេះដោយលិខិតយថាភូតត្រូវធ្វើការបង្ហាញលិខិតនោះ ឬប្រគល់លិខិតចម្លងនោះទៅឲ្យកូនបំណុលដើម្បីជាការតតាំងជាមួយកូនបំណុល។[122] យ៉ាងណាមិញ ក្នុងករណីកូនបំណុលនៃមតកជន បានសងសំណងតាមចំណែកមត៌កដែលកំណត់ដោយច្បាប់ ចំពោះសហសន្តតិជននៅមុនពេលទទួលដំណឹង សន្តតិជននោះអាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុលតាមការបែងចែកមត៌កនោះបាន។[123]

[118] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧៤ និងសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ៦, គន្លឹះទី៨-ទី៩, ១៣៧-១៣៨។

[119] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៣០៥។

[120] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៣៧-១៣៨ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៣០៥។

[121] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៤៨ កថាខណ្ឌទី ១។

[122] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧៥ កថាខណ្ឌទី ១។

[123] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧៥ កថាខណ្ឌទី ២។

## ២.២.៣ ការសម្រួលរវាងម្ចាស់បំណុល

ទោះបីជាមតកជនបានទទួលមរណភាពហើយក៏ដោយ ក៏កាតព្វកិច្ចរបស់មតកជននោះនៅតែមានដដែល ហើយកាតព្វកិច្ចទាំងនោះនឹងត្រូវបន្តទៅឲ្យសន្តតិជនទាំងអស់ ទៅតាមសមាមាត្រនៃចំណែកមត៌កដែលសន្តតិជននីមួយៗទទួលបានដែលហៅថាគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។

ពេលដែលបានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិសម្រាប់សន្តតិកម្ម ក្នុងករណីដែលមតកជនមានកាតព្វកិច្ច ហើយសន្តតិជនក៏មានកាតព្វកិច្ចផ្ទាល់ខ្លួន ប្រសិនបើគ្មានបញ្ញត្តិសម្រួលទេនៅក្រោយពេលចាប់ផ្តើមសន្តតិកម្ម ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជន ហើយម្ចាស់បំណុលរបស់សន្តតិជនក៏អាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះមត៌ករបស់សន្តតិជនដែរ។ ប៉ុន្តែជាក់ស្តែង ម្ចាស់បំណុលរបស់មតកជនច្បាស់ជាមានសិទ្ធិលើបំណុលដែលអាចយកមត៌កមកបម្រុងទុក ឬក៏ម្ចាស់បំណុលរបស់សន្តតិជនច្បាស់ជាមានសិទ្ធិលើបំណុលអាចយកទ្រព្យផ្ទាល់របស់សន្តតិជនដែរ។[124] ហេតុនេះមានន័យថា ម្ចាស់បំណុលរបស់មតកជនអាចមានសិទ្ធិលើមត៌កយកមកបម្រុងទុក និងមានសិទ្ធិលើទ្រព្យផ្ទាល់របស់សន្តតិជន ចំណែកឯម្ចាស់បំណុលរបស់សន្តតិជនអាចមានសិទ្ធិលើចំណែកមត៌ករបស់សន្តតិជន និងទ្រព្យផ្ទាល់របស់សន្តតិជន។ ក៏ប៉ុន្តែ ដើម្បីជាវិធីសម្រួលរវាងជនទាំងនោះ ក្នុងអំឡុងពេលមួយក្រោយពីសន្តតិកម្មចាប់ផ្តើម ត្រូវហាមមិនឲ្យមានការផ្ទេរឈ្មោះមត៌កទៅឲ្យសន្តតិជន ហើយម្ចាស់បំណុលរបស់មតកជនអាចជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន[125] ដើម្បីធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិទាំងនោះ។ ម្យ៉ាងទៀត ក្នុងអំឡុងពេលនេះម្ចាស់បំណុលរបស់មតកជនមិនអាចអនុវត្តសិទ្ធិលើទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនទេ ហើយម្ចាស់បំណុលរបស់សន្តតិជនក៏មិនអាចអនុវត្តសិទ្ធិលើចំណែកមត៌ករបស់សន្តតិជនដែរ ប៉ុន្តែម្ចាស់បំណុលរបស់សន្តតិជនអាចចាត់ចែងឲ្យរក្សាការពារទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបាន។[126]

ម៉្យាងទៀត ក្នុងករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ឬបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនមិនអាចអនុវត្តសិទ្ធិទៅលើទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានទេ ចំណែកឯម្ចាស់បំណុលរបស់សន្តតិជនក៏មិនអាចអនុវត្តសិទ្ធិលើចំណែកមត៌ករបស់សន្តតិជនបានដែរ។ ក្នុងករណីនេះមិនអាចធ្វើការអនុវត្តតាមវិធីសម្រួលនោះទេ។[127] លើសពីនេះទៅទៀត នៅក្នុងអំឡុងពេលនៃការយល់ព្រម ឬការបោះបង់សន្តតិកម្មមិនទាន់បានកន្លងផុតទេនោះ ម្ចាស់បំណុលនៃមតកជនពុំអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានឡើយ ទោះបីជាក្នុងករណីសន្តតិជនបានធ្វើការយល់ព្រមទាំងស្រុងក្នុងអំឡុងពេលនេះ

---

[124] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹទី៨-ទី៩, ១៤០។

[125] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៦៤។

[126] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹទី៨-ទី៩, ១៤០។

[127] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹទី៨-ទី៩, ១៤០។

ក៏ដោយ ក៏ម្ចាស់បំណុលនៃមតកជនត្រូវបានទទួលការកម្រិតក្នុងការអនុវត្តសិទ្ធិនេះ។[128] ក្រៅពីម្ចាស់បំណុលរបស់មតកជន ម្ចាស់បំណុលរបស់សន្តតិជនក៏មិនអាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះមត៌ក នៅក្នុងអំឡុងពេលនៃការយល់ព្រម ឬបោះបង់សន្តតិកម្មបានដែរ[129] ទោះបីជាកូនបំណុលរបស់ខ្លួនជាសន្តតិជនក៏ពិតមែន ប៉ុន្តែសន្តតិជនដែលជាកូនបំណុលនេះមិនទាន់បានបង្ហាញឆន្ទៈក្នុងការបោះបង់ ឬយល់ព្រមទាំងស្រុង ឬមានកម្រិតទេ ដូចនេះសន្តតិជននោះនៅមិនទាន់មានសិទ្ធិក្លាយជាកម្មសិទ្ធិករលើមត៌ករបស់មតកជននៅឡើយទេ។

[128] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧៨ និងសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ៦, គន្លឹះទី៨-ទី៩,១៤១-១៤២។

[129] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៧៩។

# ជំពូកទី៣
# នីតិវិធីក្នុងការទទួលចំណែកមត៌ក

# ជំពូកទី៣
# នីតិវិធីក្នុងការទទួលចំណែកមត៌ក

បន្ទាប់ពីបានសិក្សាជំពូកទី២ ដែលទាក់ទងនឹងនីតិវិធីមុនការទទួលសន្តតិកម្មរួចមក នៅក្នុងជំពូកទី៣នេះផងដែរ យើងនឹងធ្វើការសិក្សាអំពីនីតិវិធីក្នុងការទទួលចំណែកមត៌ក។ នៅក្នុងជំពូកនេះទៀតសោត យើងបានធ្វើការបែងចែកជា២ផ្នែកធំៗរួមមាន ការកំណត់អំពីចំណែកមត៌ក (៣.១) និងអំពីស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់ (៣.២)។

## ៣.១ ការកំណត់អំពីចំណែកមត៌ក

ក្រោយពីបានសិក្សាលក្ខណៈសម្បត្តិរបស់សន្តតិជន រួមទាំងលំដាប់នៃសន្តតិជននៅក្នុងជំពូកទី១រួចមក យើងនឹងធ្វើការបកស្រាយអំពីការកំណត់អំពីចំណែកមត៌ក ដែលសន្តតិជនទទួលបាននៅក្នុងចំណុច ៣.១.១។ ចំណែកឯចំណុច ៣.១.២ វិញ នឹងធ្វើការបរិយាយអំពីចំណែកមត៌កដែលមានជាក់ស្តែង ដែលសន្តតិជននីមួយៗត្រូវទទួលបាន។

### ៣.១.១ ចំណែកដែលសន្តតិជនទទួលបាន

ចំពោះចំណែកដែលសន្តតិជននីមួយៗនឹងទទួលបាន គឺអាស្រ័យទៅតាមកម្រិតនៃថ្នាក់ញាតិ ហើយការកម្រិតនេះអាស្រ័យទៅតាមករណីដែលមតកជននោះគ្មានសហព័ទ្ធតែមានញាតិ ឬករណីមានតែសហព័ទ្ធ ឬក្នុងករណីដែលមានទាំងសហព័ទ្ធ និងញាតិលោហិតដែលជាសន្តតិជនក្នុងពេលតែមួយ។

#### ៣.១.១.១ ករណីគ្មានសហព័ទ្ធ

ក្នុងករណីនេះ ការបែងចែកមត៌កទាំងអស់ត្រូវបែងចែកទៅតាមកម្រិតនៃថ្នាក់ញាតិ គឺទៅតាមលំដាប់នៃសន្តតិជនដែលច្បាប់បានកំណត់រួមមាន បច្ឆាញាតិដែលជាសន្តតិជនលំដាប់ទី១ បុព្វញាតិដែលជាសន្តតិជនលំដាប់ទី២ និងសាខាញាតិដែលជាសន្តតិជនលំដាប់ទី៣។

##### ក. បច្ឆាញាតិ

បច្ឆាញាតិ សំដៅទៅលើសន្តតិជនលំដាប់ទី១ដែលត្រូវជាកូនរបស់មតកជន មានន័យថាកូនដែលមានបុគ្គភាពត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ ទោះបីជាកូនបង្កើតក្តី ឬកូនសុំក្តី មិនថាកូននោះជាកូនសុំតាមសុំកូនពេញលេញ ឬសុំកូនធម្មតានោះទេ ចំណែកមត៌កដែលកូនទាំងអស់ដែលត្រូវទទួលបានត្រូវមានចំណែកស្មើៗគ្នា។[130] ប៉ុន្តែ ក្នុងករណីកូនសុំតាមសុំកូនធម្មតាវិញ កូននោះអាចទទួលសន្តតិកម្មពីឪពុកម្តាយបង្កើតផង និងពីឪពុកម្តាយចិញ្ចឹមផង។ ម្យ៉ាងទៀត ចំពោះកូនក្រៅអាពាហ៍ពិពាហ៍ ក៏ត្រូវមានចំណែកមត៌កស្មើគ្នានឹងកូនកើត

[130] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៦។

ដោយមានអាពាហ៍ពិពាហ៍ដែរ។[131]

ឧទាហរណ៍ទី១៖ មតកជនមានកូនបង្កើតចំនួន២នាក់ ក និង ខ ព្រមទាំងកូនសុំ ២នាក់ទៀត A និង B។ ហេតុនេះហើយ កូនទាំង៤ របស់មតកជនត្រូវទទួលបានចំណែកមត៌កក្នុងម្នាក់ទទួលបាន ១/៤(មួយភាគបួន) នៃចំណែកមត៌កសរុបរបស់មតកជន។




ឧទាហរណ៍ទី២៖ មតកជនមានកូនបង្កើតចំនួន ៣នាក់ ក ខ និង គ ព្រមទាំងកូនសុំ A ១នាក់។ នាពេលសន្តតិកម្មបានចាប់ផ្តើម សន្តតិជន ក បានទទួលមរណភាពប៉ុន្តែគាត់មានកូន ៣នាក់គឺ ក១ ក២ និង ក៣។ ចំណែកឯសន្តតិជន A ជាអភ័ព្វបុគ្គល ហើយគាត់មានកូន ២នាក់គឺ A១ និង A២។ ក្នុងករណីនេះយើងឃើញថា ក និង A មិនអាចទទួលចំណែកមត៌កបន្តពីមតកជនបានទេ ប៉ុន្តែកូនរបស់ ក ដែលទទួលមរណភាព និងកូនរបស់ A ដែលជាអភ័ព្វបុគ្គលនេះអាចទទួលបន្តនូវចំណែកមត៌កនោះបានក្នុងនាមជាសន្តតិជនជំនួស។[132] ដូចនេះ កូនរបស់ ក ចំនួន៣នាក់គឺ ក១ ក២ និងក៣ ព្រមទាំងកូនរបស់ A ចំនួន២នាក់គឺ A១ និងA២ ត្រូវក្លាយជាបច្ចាញាតិផ្ទាល់ ហើយចំណែកមត៌កដែលសន្តតិជននីមួយៗនឹងត្រូវទទួលបាននោះមានដូចជា៖

- ចំណែក ១/៤ របស់ ក នឹងត្រូវបែងចែកទៅឲ្យកូនចំនួន ៣ នាក់គឺ ក១ ក២ និងក៣ នោះកូនទាំង ៣ នាក់នឹងទទួលបានចំណែកស្មើៗគ្នានៃចំណែករបស់ ក គឺ ក១=ក២=ក៣=១/១២។
- ចំណែករបស់ ខ និង គ ទទួលបានក្នុងម្នាក់ៗ ១/៤។
- ចំណែក១/៤ របស់ A នឹងត្រូវបែងចែកទៅឲ្យកូនចំនួន២នាក់គឺ A១ និង A២ នោះកូនទាំង២នាក់នឹងទទួលបានចំណែកស្មើៗគ្នានៃចំណែករបស់ A គឺ A១=A២=១/៨។




[131] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៤-១៥។

[132] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៧ កថាខណ្ឌទី ១។

### ខ. បុព្វញាតិ

បុព្វញាតិ សំដៅទៅលើសន្តតិជនលំដាប់ទី២។ ក្នុងករណីដែលមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ នោះបុព្វញាតិផ្ទាល់របស់មតកជននឹងត្រូវក្លាយជាសន្តតិជន។[133] បុព្វញាតិផ្ទាល់ដែលច្បាប់បានកំណត់ដែលមានលំដាប់ជិតជាងគេរបស់មតកជន គឺជាឪពុកម្ដាយ។

ឧទាហរណ៍៖ មតកជនពុំមានកូនជាសន្តតិជន ប៉ុន្តែមានឪពុកម្ដាយ។ នៅពេលបើកសន្តតិកម្ម ឪពុកម្ដាយនឹងត្រូវក្លាយជាសន្តតិជន ដែលទទួលបានចំណែកមត៌កស្មើគ្នា គឺ១/២ (មួយភាគពីរ) នៃចំណែកមត៌កសរុប។




ម្យ៉ាងទៀត ក្នុងករណីប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវបានក្លាយជាសន្តតិជននោះ មានចំនួនច្រើននាក់ (ឪពុកម្ដាយបង្កើត និងឪពុកម្ដាយចិញ្ចឹម) នោះបុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។[134]

ឧទាហរណ៍៖ មតកជនជាកូនសុំធម៌តា នោះមានន័យថាមតកជនមានញាតិទាំងខាងឪពុកម្ដាយបង្កើតផង និងខាងឪពុកម្ដាយចិញ្ចឹមផង ពីព្រោះការសុំកូនធម៌តាញាតិលោហិតគឺមិនបានផ្ដាច់ចេញនោះទេ។ នោះនៅពេលមតកជនទទួលមរណភាព ឪពុកម្ដាយទាំងបង្កើត និងចិញ្ចឹមក្លាយជាសន្តតិជន ហើយត្រូវទទួលចំណែកមត៌ក ១/៤ (មួយភាគបួន) ស្មើគ្នា។




ជាងនេះទៅទៀត ក្នុងករណីដែលមតកជនមិនមានឪពុកម្ដាយទេ នោះជីដូនជីតានឹងក្លាយជាសន្តតិជនបន្តដោយទទួលនូវចំណែកមត៌កស្មើៗគ្នា។

ឧទាហរណ៍៖ មតកជនមិនមានបុព្វញាតិផ្ទាល់ទេ (ឪពុកម្ដាយបានស្លាប់) នោះចំណែកមត៌កត្រូវធ្លាក់ទៅជីដូនជីតាទាំងខាងឪពុក ទាំងខាងម្ដាយ មានន័យថាជីដូនជីតាទាំងសងខាងនឹងទទួលបានចំណែកមត៌កស្មើៗគ្នា ក្នុង

[133] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៩ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១។

[134] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៥៩ កថាខណ្ឌទី ២។

ម្នាក់ទទួលបានចំណែក ១/៤(មួយភាគបួន)។




**គ. សាខាញាតិ**

សាខាញាតិ សំដៅទៅលើសន្តតិជនលំដាប់ទី៣។ ក្នុងករណីដែលមតកជនពុំមានទាំងបច្ឆាញាតិ ព្រមទាំងបុព្វញាតិក្នុងការទទួលសន្តតិកម្មទេ នោះបងប្អូនបង្កើតរបស់មតកជននោះត្រូវក្លាយជាសន្តតិជន។ បើបងប្អូនបង្កើតមានចំនួនច្រើន នោះចំណែកមត៌កត្រូវបែងចែកជាភាគស្មើៗគ្នា ប៉ុន្តែក្នុងករណីដែលចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្ដាយតែម្ខាង នោះបងប្អូនបង្កើតនោះត្រូវទទួលបានចំណែក ១/២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុកម្ដាយទាំងសងខាងដូចគ្នា។[135]

ឧទាហរណ៍៖ មតកជនបានទទួលមរណភាពដោយគ្មានបច្ឆាញាតិ និងបុព្វញាតិ ប៉ុន្តែគាត់មានបងប្អូនបង្កើត៣នាក់ គឺ ក ខ និង គ។ ប៉ុន្តែ ក និង ខ ជាបងប្អូនបង្កើតដែលមានម្ដាយឪពុករួមគ្នាជាមួយនឹងមតកជន ចំណែក គ ជាបងប្អូនដែលមានឪពុករួមគ្នា តែម្ដាយខុសគ្នា។ នោះនៅពេលចាប់ផ្ដើមសន្តតិកម្ម ចំណែកមត៌ករបស់ គ ត្រូវទទួលបាន ១/២(មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានម្ដាយឪពុកដូចគ្នាគឺ ក និង ខ។ ពោលគឺ ក និង ខ ទទួលបានម្នាក់ ២/៥ (ពីរភាគប្រាំ) នៃចំណែកមត៌ក និង គ ទទួលបាន ១/៥ (មួយភាគប្រាំ) នៃចំណែកមត៌ក។




[135] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦០ កថាខណ្ឌទី ១ និងកថាខណ្ឌទី ២។

ក្នុងករណីដែលសន្តតិជនដែលជាបងប្អូនបង្កើតរបស់មតកជនទទួលមរណភាព ឬបាត់បង់សិទ្ធិដោយមូលហេតុណាមួយ (អភ័ព្វបុគ្គល ឬជនត្រូវផ្តាច់ចេញពីមត៌ក) នោះសន្តតិជនជំនួសនឹងត្រូវយកមកអនុវត្ត។ ក្នុងករណីនេះ មានន័យថាកូនរបស់សន្តតិជននោះ (ក្មួយប្រុស ឬក្មួយស្រីរបស់មតកជន) នឹងក្លាយទៅជាសន្តតិជនជំនួស។[136]

ឧទាហរណ៍៖ ក្នុងករណីឧទាហរណ៍ខាងលើ បើសិនបងប្អូនមតកជនដែលជាបុគ្គល បានទទួលមរណភាព ប៉ុន្តែ ក មានកូន ២នាក់ គឺ ក១ និង ក២។ ចំណែកឯ បងប្អូនរួមឪពុកដែលជាបុគ្គល គ ជាអភ័ព្វបុគ្គល ប៉ុន្តែ គ មានកូន ២នាក់ គឺ គ១ និង គ៣។ ក្នុងករណីនេះចំណែកមត៌កត្រូវបែងចែកដូចខាងក្រោម៖

- ចំណែក ២/៥ របស់ ក ត្រូវបែងចែកជា២ នោះ ក១ ទទួលបាន ២/១០ (ពីរភាគដប់) និង ក២ ទទួលបាន ២/១០ (ពីរភាគដប់)
- ចំណែក ២/៥ (ពីរភាគប្រាំ) ជារបស់ ខ
- ចំណែក ១/៥ របស់ គ ត្រូវបែកចែកជា២ នោះ គ១ ទទួលបាន ១/១០ (មួយភាគដប់) និង គ២ ទទួលបាន ១/១០ (មួយភាគដប់)។




### ៣.១.១.២ ករណីមានតែសហព័ទ្ធ

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ មានចែងបញ្ញត្តិអំពីសហព័ទ្ធរបស់មតកជន គឺជាសន្តតិជនជានិច្ច[137] ទោះបីជាមាន ឬគ្មានសន្តតិជនផ្សេងទៀតក៏ដោយ។ ក្នុងករណីដែលមតកជនគ្មាននូវសន្តតិជនលំដាប់ទាំងបីចូលរួមទេ នោះសហព័ទ្ធនោះនឹងត្រូវទទួលចំណែកមត៌កពីមតកជនតែម្នាក់ឯង វៀរលែងតែសហព័ទ្ធនោះជាអភ័ព្វបុគ្គល ឬជាបុគ្គលដែលផ្តាច់ចេញពីមត៌ក។[138]

[136] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦០ កថាខណ្ឌទី ៣។
[137] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦១ កថាខណ្ឌទី ១។
[138] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ២០១

### ៣.១.១.៣ ទំនាក់ទំនងរវាងសហព័ទ្ធ និងសន្តតិជនជាញាតិលោហិត

ជាគោលការណ៍ទ្រព្យសម្បត្តិដែលប្តីប្រពន្ធរកបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ជាទ្រព្យសម្បត្តិរួម[139] ហេតុនេះនៅពេលដែលសហព័ទ្ធណាមួយបានទទួលមរណភាព សហព័ទ្ធម្ខាងទៀតត្រូវទទួលបាននូវទ្រព្យសម្បត្តិពាក់កណ្តាលនៃទ្រព្យរួម។ ក្នុងករណីដែលសហព័ទ្ធជាសន្តតិជន ហើយមានសន្តតិជនផ្សេងទៀតក្នុងលំដាប់ណាមួយត្រូវជាសន្តតិជនដែរ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ[140] មានន័យថាសហព័ទ្ធដែលជាសន្តតិជនជានិច្ចនោះ នៅតែទទួលចំណែកមត៌កជានិច្ច ព្រោះសហព័ទ្ធគាត់មិនស្ថិតនៅក្នុងលំដាប់ណាមួយនៃសន្តតិជនឡើយ។ ក្នុងករណីនេះ បើសិនមាននូវសន្តតិជនដទៃតាមលំដាប់ណាមួយ នោះយើងនឹងធ្វើការបែងចែកមត៌កតាមករណីខាងក្រោម៖

#### ក. សហព័ទ្ធ និងបច្ឆាញាតិ

ក្នុងករណីដែលមតកជនមានសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជន នោះសន្តតិជនដែលជាសហព័ទ្ធ និងកូននីមួយៗរបស់មតកជននោះនឹងត្រូវមានចំណែកស្មើៗគ្នា។[141] ការកំណត់ឲ្យសហព័ទ្ធ និងកូនទាំងអស់មានចំណែកមត៌កស្មើគ្នានេះ គឺដោយសារតែការគិតពិចារណាទៅដល់ការចំណាយសម្រាប់ការរស់នៅនៅក្រោយពេលមតកជនទទួលមរណភាព។[142]

ឧទាហរណ៍៖ មតកជនមានសហព័ទ្ធម្នាក់ឈ្មោះ ក ហើយមានកូន ២នាក់ A និង B ព្រមទាំងកូនសុំម្នាក់ឈ្មោះ C។ នៅពេលបើកសន្តតិកម្ម សហព័ទ្ធ និងកូនទាំងអស់ត្រូវទទួលបានចំណែកមត៌កស្មើគ្នា គឺម្នាក់ទទួលបាន ១/៤ (មួយភាគបួន) នៃចំណែកមត៌កសរុបរបស់មតកជន។




ម្យ៉ាងទៀត ក្នុងករណីសន្តតិកម្មជំនួសក៏ត្រូវយកមកអនុវត្តផងដែរ មានន័យថាប្រសិនបើកូនរបស់មតកជនបានទទួលមរណភាព ឬត្រូវបានថ្លោះសិទ្ធិដោយមូលហេតុណាមួយ (អភ័ព្វបុគ្គល ឬជនផ្តាច់ចេញពីមត៌ក)

[139] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ៩៧៣។
[140] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦១ កថាខណ្ឌទី ២។
[141] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦២ កថាខណ្ឌទី ក។
[142] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹទី៨-ទី៩, ២២។

ហើយកូននោះមានសន្តតិជនជំនួស នោះចំណែកមត៌កក៏ត្រូវបែងចែកទៅតាមចំនួនកូនដែរ។[143]

ឧទាហរណ៍៖ ក្នុងករណីឧទាហរណ៍ខាងលើ បើសិនកូន B របស់មតកជនបានស្លាប់ដោយមានកូន ៣នាក់ គឺ B១ B២ និង B៣។ ចំណែកឯកូនសុំ C នោះជាអភ័ព្វបុគ្គលមានកូន ២នាក់ C១ និង C២។ ក្នុងករណីនេះ ចំណែកមត៌កត្រូវបែងចែកដូចខាងក្រោម៖

- សហព័ទ្ធ ក ទទួលបាន ១/៤ (មួយភាគបួន) នៃចំណែកមត៌កសរុប
- A ទទួលបាន ១/៤ (មួយភាគបួន) នៃចំណែកមត៌កសរុប
- ចំណែក ១/៤ របស់ B ត្រូវបែកចែកជា៣ នោះ B១ B២ និង B៣ ទទួលបានម្នាក់ៗ ១/១២ (មួយភាគដប់ពីរ) នៃចំណែកមត៌កសរុប
- ចំណែក ១/៤ របស់ C ត្រូវបែកចែកជា២ នោះ C១ និង C២ ទទួលបានម្នាក់ៗ ១/៨ (មួយភាគប្រាំបី) នៃចំណែកមត៌កសរុប។




### ខ. សហព័ទ្ធ និងបុព្វញាតិ

ចំពោះករណីបើសហព័ទ្ធ និងបុព្វញាតិរបស់មតកជនជាសន្តតិជន នោះក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិថាចំណែកមត៌ករបស់សហព័ទ្ធត្រូវជា ១/៣ (មួយភាគបី) ចំណែកឯចំណែកមត៌ករបស់បុព្វញាតិជាឪពុកម្តាយត្រូវជា ២/៣ (ពីរភាគបី) មានន័យថាឪពុកទទួលបាន ១/៣ (មួយភាគបី) និងម្តាយទទួលបាន ១/៣ (មួយភាគបី)។ ប៉ុន្តែ បើឪពុក ឬម្តាយរបស់មតកជននៅរស់តែម្នាក់ នោះចំណែកមត៌កនោះត្រូវចែកត្រឹមសហព័ទ្ធ និងម្តាយ ឬឪពុកដែលនៅរស់នោះតែប៉ុណ្ណោះ មានន័យថាសហព័ទ្ធទទួលបាន ១/២ (មួយភាគពីរ) និងម្តាយ ឬឪពុកនោះទទួលបាន ១/២ (មួយភាគពីរ) នៃចំណែកមត៌កដូចគ្នា។[144] ម៉្យាងទៀត វាជារឿងមួយដ៏កម្រ ដែលមតកជនមានឪពុកម្តាយច្រើនរូបតាមរយៈសុំកូនធម្មតា ក្នុងករណីនេះសហព័ទ្ធនៅតែទទួលបាន

[143] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ២២។

[144] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦២ កថាខណ្ឌ ២។

ចំណែកមត៌ក ១/៣ (មួយភាគបី) នៃចំណែកមត៌កសរុបដដែល ចំណែកឯឪពុកម្ដាយផ្សេងទៀតគឺទទួលចំណែកស្មើគ្នាក្នុងចំណែក ២/៣ (ពីរភាគបី)។[145]

ឧទាហរណ៍៖ មតកជនមានសហព័ទ្ធឈ្មោះ ក គាត់ពុំទាន់មានកូនក៏ត្រូវបានទទួលមរណភាព ប៉ុន្តែមតកជននេះនៅមានឪពុក-ម្ដាយបង្កើតដែលនៅរស់ ព្រមទាំងឪពុក-ម្ដាយចិញ្ចឹមបន្ថែមទៀត។ នៅពេលចាប់ផ្ដើមសន្តតិកម្ម សហព័ទ្ធ ក ត្រូវទទួលបានចំណែក ១/៣ (មួយភាគបី) នៃចំណែកមត៌កសរុប រីឯចំណែក ២/៣ (ពីរភាគបី) ទៀត ជាចំណែករបស់ឪពុក-ម្ដាយបង្កើត និងឪពុក-ម្ដាយចិញ្ចឹម ដែលត្រូវចែកជាចំណែកស្មើគ្នា នោះក្នុងម្នាក់ទទួលបាន ២/១២ (មួយភាគបី) នៃចំណែកមត៌ក។




ក្នុងករណីដែលមតកជនមិនមានឪពុកម្ដាយទាំងបង្កើត និងចិញ្ចឹមជាសន្តតិជននោះ ជីដូនជីតាត្រូវទទួលបន្តនូវចំណែកមត៌ក ដោយសហព័ទ្ធត្រូវទទួលបានពាក់កណ្ដាលនៃចំណែកមត៌កសរុប ចំណែកឯចំណែកមត៌កពាក់កណ្ដាលទៀតត្រូវបែងចែកស្មើគ្នារវាងជីដូនជីតាទាំងខាងម្ដាយ និងខាងឪពុក។

ឧទាហរណ៍៖ មតកជនមិនមានបុព្វញាតិផ្ទាល់ទេ (ឪពុកម្ដាយបានស្លាប់) ប៉ុន្តែមតកជនមានសហព័ទ្ធ ក ម្នាក់នោះនៅពេលចាប់ផ្ដើមសន្តតិកម្ម ចំណែកមត៌កត្រូវបែងចែកទៅឲ្យសហព័ទ្ធ ក ១/២ (មួយភាគពីរ) នៃចំណែកមត៌កសរុប និងចំណែក ១/២ (មួយភាគពីរ) ទៀត ចែកទៅជីដូនជីតាទាំងខាងឪពុក ទាំងខាងម្ដាយ មានន័យថាជីដូនជីតាទាំងសងខាងនឹងទទួលបានចំណែកមត៌កស្មើៗគ្នា ក្នុងម្នាក់ទទួលបានចំណែក ១/៨(មួយភាគបួន)។




[145] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ២២។

### គ. សហព័ទ្ធ និងសាខាញាតិ

ក្នុងករណីដែលសន្តតិជនជាសហព័ទ្ធ និងជាបងប្អូនបង្កើត ដោយមិនមានបុព្វញាតិ និងបច្ឆាញាតិផ្ទាល់ នោះចំណែកមត៌កត្រូវបែកចែកទៅឲ្យសហព័ទ្ធ ១/២ (មួយភាគពីរ) នៃចំណែកមត៌កសរុប។ ចំណែកឯមត៌ក ១/២ (មួយភាគពីរ) ទៀតត្រូវបែងចែកទៅឲ្យសហសន្តតិជនលំដាប់ទី៣ជាចំណែកស្មើគ្នា។[146] ក្នុងករណីនេះ គោលការណ៍នៃសន្តតិកម្មជំនួសក៏ត្រូវយកមកអនុវត្តផងដែរ ពោលគឺប្រសិនបើសន្តតិជនដែលជាបងប្អូនបង្កើតនោះទទួលមរណភាព ឬបាត់បង់សិទ្ធិដោយករណីណាមួយ (អភ័ព្វបុគ្គល ឬជនផ្ដាច់ចេញពីមត៌ក) ហេតុនេះ កូនរបស់ជននោះនឹងត្រូវក្លាយជាសន្តតិជនជំនួស ប៉ុន្តែបានត្រឹមតែមួយថ្នាក់ប៉ុណ្ណោះ។[147]

ឧទាហរណ៍៖ មតកជនមានសហព័ទ្ធ ក និងមានបងប្អូនបង្កើតឪពុកម្ដាយរួមគ្នា ៣នាក់គឺ ខ គ និង ឃ ហើយមានបងប្អូនបង្កើតឪពុករួម ២នាក់ គឺ ជ និង ឈ។ នៅពេលបើកសន្តតិកម្ម សហព័ទ្ធ ក នឹងទទួលបានចំណែកមត៌ក ១/២ (មួយភាគពីរ) នៃចំណែកមត៌កសរុប។ ចំណែកមត៌ក ដែលនៅសល់ត្រូវបែងចែកឲ្យបងប្អូននោះតាមការបែងចែកដូចខាងក្រោម៖

- ចំណែក ១/២ (មួយភាគពីរ) ដែលសល់ត្រូវបែងចែកឲ្យបងប្អូនដែលមានឪពុកម្ដាយរួមស្មើគ្នា និងបងប្អូនបង្កើតដែលមានឪពុករួម ពាក់កណ្ដាលនៃចំណែករបស់បងប្អូនដែលមានឪពុកម្ដាយរួម។
- តាង X ជាចំណែកមត៌ករបស់សន្តតិជននីមួយៗ ក្នុងចំណែក ១/២ (មួយភាគពីរ) យើងបាន៖
  - ១/២ = ខ + គ + ឃ + ជ + ឈ
  - ដោយ ជ និង ឈ មានឪពុករួមនឹង ខ គ និង ឃ នោះចំណែកមត៌ករបស់ ជ និង ឈ ស្មើពាក់កណ្ដាលនៃ ខ គ និង ឃ នោះ ជ = ឈ = ១/២(ខ/គ/ឃ)
  - យើងបាន ១/២ = ខ + គ + ឃ + ១/២(ជ) + ១/២(ឈ)

=> ១/២ = X + X + X + ១/២X + ១/២X

=> ១/២ = ៤X

=> X = ១/៨

ដូចនេះ ចំណែកមត៌កដែលសន្តតិជនម្នាក់ៗទទួលបានគឺ៖

- សហព័ទ្ធ ក ១/២ (មួយភាគពីរ)។
- បងប្អូនបង្កើតឪពុកម្ដាយរួមគ្នាគឺ ខ គ និង ឃ ម្នាក់ៗទទួលបាន ១/៨ (មួយភាគប្រាំបី) នៃចំណែកមត៌កសរុប។

[146] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦២ កថាខណ្ឌ គ។

[147] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៩។

- បងប្អូនបង្កើតឪពុករួមគ្នាគឺ ជ និង ឈ ម្នាក់ៗទទួលបានពាក់កណ្ដាលនៃចំណែក ១/៨ (មួយភាគប្រាំបី) នោះគឺ ១/១៦ (មួយភាគដប់ប្រាំមួយ) នៃចំណែកមត៌កសរុប។




### ៣.១.២ ចំណែកមត៌កជាក់ស្ដែង

ចំណែកមត៌កជាក់ស្ដែងរបស់សន្តតិជនម្នាក់ៗដែលត្រូវទទួលបាន ត្រូវបានកំណត់ឡើងដោយវិធីសម្រួលចំណែកមត៌ក ដើម្បីឲ្យមានសមភាពរវាងសហសន្តតិជន និងមានភាពសមស្របក្នុងករណីដែលសន្តតិជនណាម្នាក់ទទួលបានផលប្រយោជន៍ពិសេសនានា ដោយតម្រូវឲ្យទទួលបាននូវចំណែកបង្គ្រប់ទៅនឹងចំណែកមត៌កនោះ ឬមិនទទួលបាន។ យោងទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិអំពីការសម្រួលចំណែកមត៌ក ដែលយើងនឹងត្រូវលើកយកមកសិក្សាទៅលើចំណុចមួយចំនួនដូចជា ការទទួលបានផលប្រយោជន៍ពិសេស ការមានភាគនៃវិភាគទាន ការទទួលបានផលប្រយោជន៍ពិសេស និងមានភាគនៃវិភាគទានក្នុងពេលតែមួយ ព្រមទាំងការទទួលបានប្រទានកម្ម។

#### ៣.១.២.១ ករណីទទួលបានផលប្រយោជន៍ពិសេស

ការសម្រួលចំណែកមត៌ក ជាវិធានធ្វើឲ្យមានសមភាពជាក់ស្ដែងនៅក្នុងចំណោមសន្តតិជន ដែលបានទទួលនូវផលប្រយោជន៍ពិសេស ឬប្រទានកម្មនៅមុនពេលម្ចាស់ទ្រព្យបានស្លាប់។ ផលប្រយោជន៍ពិសេស សំដៅផលប្រយោជន៍ដែលបុគ្គលណាម្នាក់ ឬច្រើននាក់បានទទួលជាប្រទានកម្មក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬនៅពេលដែលទទួលបានអច្ច័យទានពីមតកជន។ ប៉ុន្តែអច្ច័យទានដែលអច្ច័យលាភី ឬសន្តតិជនដែលត្រូវទទួលបាន ត្រូវចាត់ទុកជាផលប្រយោជន៍ពិសេសមែន ប៉ុន្តែពុំត្រូវរាប់បញ្ចូលក្នុងការគណនានោះទេ ព្រោះពេលចាប់ផ្ដើមសន្តតិកម្ម អច្ច័យទានពុំទាន់បានបែងចែកឲ្យសន្តតិជនឡើយ។[148] ផលប្រយោជន៍ពិសេស ជាប្រទានកម្មពិសេស ដែលមតកជនបានផ្ដល់នូវទ្រព្យណាមួយទៅឲ្យសន្តតិជន។ មិនមែនឲ្យអ្វីបន្តិចបន្តួចសម្រាប់ចាយវាយប្រចាំថ្ងៃ ជាផលប្រយោជន៍ពិសេសនោះទេ ប្រសិនបើការនោះលើសពីទំហំធម្មតា ជាផលប្រយោជន៍ពិសេស។[149]

[148] អ៊ីវ ប៉ូលី, "ការបែងចែកមត៌ក," (មេរៀនសម្រាប់ចែករំលែក, វិភាគទានច្បាប់, ១៥ មករា ២០១៨), ១០។
[149] សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ៦ (បោះពុម្ពក្នុងខែមីនា ឆ្នាំ២០១២), ៣២។

ក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាម្នាក់ដែលបានទទួលប្រទានកម្ម ក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬនៅពេលដែលទទួលបានអច្ច័យទានពីមតកជន នោះតម្លៃសរុបនៃមត៌កត្រូវយកទ្រព្យរបស់មតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម បូកបញ្ចូលតម្លៃនៃប្រទានកម្មត្រូវបានចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ក្រោយដកតម្លៃនៃប្រទានកម្ម ឬអច្ច័យទានចេញពីចំណែកមត៌ក គឺជាចំណែកមត៌ករបស់នោះ។[150] ជាគោលការណ៍សន្តតិជន គឺត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា ប៉ុន្តែប្រសិនបើមានជនដែលទទួលបានផលប្រយោជន៍ពិសេស យើងមិនអាចយកចំណែកមត៌កជាក់ស្ដែងទៅចែកឲ្យសន្តតិជនទាំងអស់ ដោយមិនមានធ្វើការសម្រួលចំណែកមត៌កនោះទេ ព្រោះវាបំពានដល់ខ្លឹមសារនៃការទទួលបានមត៌កជាក់ស្ដែង។ ហេតុដូចនេះហើយ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីចំណែកមត៌កនៃជនដែលទទួលបានផលប្រយោជន៍ពិសេស តាមវិធីនៃការសម្រួលចំណែក។[151] ក្នុងករណីមានការទទួលបានផលប្រយោជន៍ យើងត្រូវពិចារណាទៅលើចំណុចមួយចំនួនដូចជា៖

- កំណត់ឲ្យបានច្បាស់អំពីផលប្រយោជន៍ពិសេសដែលទទួលបាន (អច្ច័យទាន ឬប្រទានកម្មកាលនៅរស់ដែលបានកំណត់)
- កំណត់អំពីទ្រព្យដែលត្រូវបានចាត់ទុកថាជាមត៌ក ដោយយកទ្រព្យសម្បត្តិដែលមាននៅពេលចាប់ផ្ដើមសន្តតិកម្ម (បញ្ជាក់ឲ្យច្បាស់នូវទ្រព្យសកម្មពេលចាប់ផ្ដើមសន្តតិកម្ម ដោយមិនគិតពីកាតព្វកិច្ចមតកជនទេ) បូកនឹងការទទួលផលប្រយោជន៍ពិសេស (ប្រទានកម្មកាលនៅរស់) ក្រៅពីអច្ច័យទាន (ការយកនូវផលប្រយោជន៍ពិសេសត្រឡប់មកវិញ)

| ទ្រព្យដែលចាត់ទុកជាមត៌ក = ទ្រព្យសកម្មពេលចាប់ផ្ដើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស(ដកអច្ច័យទាន) |
|---|

- ក្រោយពីកំណត់ទ្រព្យដែលត្រូវចាត់ទុកជាមត៌ករួចហើយ យើងអាចគណនាចំណែកមត៌កតាមច្បាប់របស់សន្តតិជនដែលទទួលបានផលប្រយោជន៍ពិសេស ដោយយកទ្រព្យដែលត្រូវបានចាត់ទុកជាមត៌កមកចែកនឹងចំនួនសន្តតិជនសរុប រួចដកនឹងផលប្រយោជន៍ដែលសន្តតិជននោះទទួលបាន

| ចំណែកមត៌កជាក់ស្ដែង = (ទ្រព្យដែលចាត់ទុកជាមត៌ក ÷ ចំនួនសន្តតិជនសរុប) - ផលប្រយោជន៍ពិសេស |
|---|

### ក. ករណីចំណែកមត៌កច្រើនជាងផលប្រយោជន៍ពិសេស

ក្នុងករណីដែលចំណែកមត៌កមានចំនួនច្រើនជាងផលប្រយោជន៍ពិសេស នោះដើម្បីបង្គ្រប់ចំណែកមត៌ករបស់សន្តតិជនណាមួយដែលបានទទួលផលប្រយោជន៍ពិសេស សន្តតិជននោះនឹងទទួលបាននូវចំណែកមត៌ក

[150] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦៣ កថាខណ្ឌទី ១។

[151] អ៊ីវ ប៉ូលី, "ការបែងចែកមត៌ក," (មេរៀនសម្រាប់ចែករំលែក, វិភាគទានច្បាប់, ១៥ មករា ២០១៨), ១១។

នៃចំណែកបន្ថែមនៅពេលសន្តតិកម្មត្រូវបានបើក បន្ថែមពីចំណែកផលប្រយោជន៍ពិសេសនោះ។

ឧទាហរណ៍៖ នៅពេលមរណភាព ឪពុកដែលជាមតកជនមានដី និងផ្ទះដែលមានតម្លៃ ៤០ ០០០ដុល្លារអាមេរិក និងមានប្រាក់បញ្ញើនៅធនាគារ ១០ ០០០ដុល្លារអាមេរិក។ គាត់មានកូន ក ខ និង គ ដែលត្រូវជាសន្តតិជន។ ពេលដែលកូន គ បានចាប់ផ្ដើមអាជីវកម្មរបស់ខ្លួន ឪពុកបានប្រគល់ប្រាក់ ១០ ០០០ដុល្លារអាមេរិកទៅឲ្យ គ ។ ក្នុងករណីនេះ៖

- តម្លៃនៃទ្រព្យសកម្មពេលចាប់ផ្ដើមសន្តតិកម្មគឺ ៥០ ០០០ដុល្លារអាមេរិក (ដី ផ្ទះ ៤០ ០០០ដុល្លារអាមេរិក + ប្រាក់បញ្ញើ ១០ ០០០ដុល្លារអាមេរិក)
- តម្លៃនៃផលប្រយោជន៍ពិសេសដែល គ ទទួលបានគឺ ១០ ០០០ដុល្លារអាមេរិក
- ទ្រព្យដែលត្រូវចាត់ទុកថាជាមត៌កគឺ ៦០ ០០០ដុល្លារអាមេរិក (ទ្រព្យសកម្មពេលចាប់ផ្ដើមសន្តតិកម្ម ៥០ ០០០ដុល្លារអាមេរិក + ផលប្រយោជន៍ពិសេសដែល គ ទទួលបាន ១០ ០០០ដុល្លារអាមេរិក)
- នោះចំណែកមត៌កជាក់ស្ដែងរបស់សន្តតិជននីមួយៗទទួលបានគឺ៖
    - ក ទទួលបាន ២០ ០០០ដុល្លារអាមេរិក (៦០ ០០០ / ៣នាក់)
    - ខ ទទួលបាន ២០ ០០០ដុល្លារអាមេរិក (៦០ ០០០ / ៣នាក់)
    - គ ទទួលបាន ១០ ០០០ដុល្លារអាមេរិក (៦០ ០០០ / ៣នាក់ - ១០ ០០០ ដែលជាផលប្រយោជន៍ពិសេស)

ដូចនេះ ចំណែករបស់សន្តតិជន ក និង ខ ទទួលបានក្នុងម្នាក់ៗ ២០ ០០០ដុល្លារអាមេរិក និងចំណែករបស់សន្តតិជន គ ទទួលបាន ១០ ០០០ដុល្លារអាមេរិក ដើម្បីបង្គ្រប់ចំណែកមត៌ករបស់ខ្លួន។

### ខ. ករណីចំណែកមត៌ក និងផលប្រយោជន៍ពិសេសមានចំនួនស្មើគ្នា

ក្នុងករណីដែលចំណែកមត៌ក និងផលប្រយោជន៍ពិសេសមានតម្លៃស្មើគ្នា នោះសហសន្តតិជនពុំអាចទទួលបាននូវចំណែកមត៌កពីមតកជនបានទៀតឡើយ។[152]

ឧទាហរណ៍៖ នៅពេលមរណភាព ឪពុកដែលជាមតកជនមានដី និងផ្ទះដែលមានតម្លៃ ៤០ ០០០ដុល្លារអាមេរិក។ គាត់មានកូន ក ខ និង គ ដែលត្រូវជាសន្តតិជន។ ពេលដែលកូន គ បានចាប់ផ្ដើមអាជីវកម្មរបស់ខ្លួន ឪពុកបានប្រគល់ប្រាក់ ២០ ០០០ដុល្លារអាមេរិក ទៅឲ្យ គ ។ ក្នុងករណីនេះ៖

- តម្លៃនៃទ្រព្យសកម្មពេលចាប់ផ្ដើមសន្តតិកម្មគឺ ៤០ ០០០ដុល្លារអាមេរិក (ដី ផ្ទះ)
- តម្លៃនៃផលប្រយោជន៍ពិសេសដែល គ ទទួលបានគឺ ២០ ០០០ដុល្លារអាមេរិក

[152] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦៣ កថាខណ្ឌទី ២។

- ទ្រព្យដែលត្រូវចាត់ទុកថាជាមត៌កគឺ ៦០ ០០០ដុល្លារអាមេរិក (ទ្រព្យសកម្មពេលចាប់ផ្ដើមសន្តតិកម្ម ៤០ ០០០ដុល្លារអាមេរិក + ផលប្រយោជន៍ពិសេសដែល គ ទទួលបាន ២០ ០០០ដុល្លារអាមេរិក)
- នោះចំណែកមត៌កជាក់ស្ដែងរបស់សន្តតិជននីមួយៗទទួលបានគឺ៖
  - ក ទទួលបាន ២០ ០០០ដុល្លារអាមេរិក (៦០ ០០០ / ៣នាក់)
  - ខ ទទួលបាន ២០ ០០០ដុល្លារអាមេរិក (៦០ ០០០ / ៣នាក់)
  - គ ទទួលបាន ០ដុល្លារអាមេរិក (៦០ ០០០ / ៣នាក់ - ២០ ០០០ ដែលជាផលប្រយោជន៍ពិសេស)

ដូចនេះ ចំណែករបស់សន្តតិជន ក និង ខ ទទួលបានក្នុងម្នាក់ៗ ២០ ០០០ដុល្លារអាមេរិក និងសន្តតិជន គ មិនទទួលបានចំណែកមត៌កឡើយ។

**គ. ករណីចំណែកមត៌កតិចជាងផលប្រយោជន៍ពិសេស**

ក្នុងករណីដែលចំណែកមត៌កមានតម្លៃតិចជាងតម្លៃនៃផលប្រយោជន៍ពិសេស នោះសហសន្តតិជននោះក៏ពុំអាចទទួលបាននូវចំណែកមត៌កពីមតកជនបានទៀតដូចគ្នា។[153] ក្នុងករណីនេះ ទោះបីជាតម្លៃនៃផលប្រយោជន៍ពិសេស ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ ក៏សហសន្តតិជននោះពុំចាំបាច់បង្វិលមកវិញនូវចំណែកដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ ចំណែកឯមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់តាមការគណនា ដោយយកមត៌ករបស់មតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ។[154]

| |
|---|
| ចំណែកមត៌កជាក់ស្ដែងដែលសន្តតិជនទទួល = ចំណែកមត៌ករបស់សន្តតិជន / តម្លៃសរុបនៃចំណែកមត៌ករបស់សន្តតិជនទាំងអស់ x មត៌កពេលចាប់ផ្ដើមសន្តតិកម្ម |

ឧទាហរណ៍៖ នៅពេលមរណភាព ឪពុកដែលជាមតកជនមានដី និងផ្ទះដែលមានតម្លៃ ២០ ០០០ដុល្លារអាមេរិក និងមានប្រាក់បញ្ញើនៅធនាគារ ១០ ០០០ដុល្លារអាមេរិក។ គាត់មានកូន ក ខ និង គ ដែលត្រូវជាសន្តតិជន។ ពេលដែលកូន ក បានចាប់ផ្ដើមអាជីវកម្មរបស់ខ្លួន ឪពុកបានប្រគល់ប្រាក់ ២៥ ០០០ដុល្លារអាមេរិក ទៅឲ្យ ក និង ៥ ០០០ដុល្លារអាមេរិក ឲ្យទៅ ខ ពេលរៀបការ។ ក្នុងករណីនេះ៖

- តម្លៃនៃទ្រព្យសកម្មពេលចាប់ផ្ដើមសន្តតិកម្មគឺ ៣០ ០០០ដុល្លារអាមេរិក (ដីផ្ទះ ២០ ០០០ដុល្លារអាមេរិក + ប្រាក់បញ្ញើ ១០ ០០០ដុល្លារអាមេរិក)

[153] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦៣ កថាខណ្ឌទី ២។

[154] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦៥។

- តម្លៃនៃផលប្រយោជន៍ពិសេសដែល ក ទទួលបានគឺ ២៥ ០០០ដុល្លារអាមេរិក
- តម្លៃនៃផលប្រយោជន៍ពិសេសដែល ខ ទទួលបានគឺ ៥ ០០០ដុល្លារអាមេរិក
- ទ្រព្យដែលត្រូវចាត់ទុកថាជាមត៌កគឺ ៦០ ០០០ដុល្លារអាមេរិក (ទ្រព្យសកម្មពេលចាប់ផ្តើមសន្តតិកម្ម ៣០ ០០០ដុល្លារអាមេរិក + ផលប្រយោជន៍ពិសេសដែល ក ទទួលបាន ២៥ ០០០ដុល្លារអាមេរិក និង ខ ទទួលបាន ៥ ០០០ដុល្លារអាមេរិក)
- នោះចំណែកមត៌កជាក់ស្តែងរបស់សន្តតិជននីមួយៗទទួលបានគឺៈ
  - ក ទទួលបាន -៥ ០០០ដុល្លារអាមេរិក (៦០ ០០០ / ៣នាក់ - ២៥ ០០០ ដែលជាផលប្រយោជន៍ពិសេស)
  - ខ ទទួលបាន ១៥ ០០០ដុល្លារអាមេរិក (៦០ ០០០ / ៣នាក់ - ៥ ០០០ ដែលជាផលប្រយោជន៍ពិសេស)
  - គ ទទួលបាន ២០ ០០០ដុល្លារអាមេរិក (៦០ ០០០ / ៣នាក់)

ដូចនេះ សន្តតិជន ក មិនទទួលបានចំណែកមត៌កឡើយ ហើយ ក ក៏មិនចាំបាច់បង្វិលសងវិញនូវចំណែកដែលទទួលបានលើសនោះដែរ។ ចំណែកឯចំណែករបស់សន្តតិជន ខ គឺទទួលបាន ១៥ ០០០ដុល្លារអាមេរិក និង គ ទទួលបាន ២០ ០០០ដុល្លារអាមេរិក បូកសរុបទៅគឺ ៣៥ ០០០ដុល្លារអាមេរិក ប៉ុន្តែចំនួនមត៌កពេលចាប់ផ្តើមសន្តតិកម្មមានតែ ៣០ ០០០ដុល្លារអាមេរិក ប៉ុណ្ណោះ។ ហេតុដូចនេះហើយ ខ និង គ ត្រូវទទួលបានចំណែកមត៌កទៅតាមសមាមាត្រ ១៥ ០០០ និង ២០ ០០០ នៃចំនួនមត៌ក ៣០ ០០០ដុល្លារអាមេរិក នោះយើងបានៈ

- ខ ទទួលបាន (១៥ ០០០ / ៣៥ ០០០ x ៣០ ០០០ = ១២ ៨៥៧.១៤) នោះ ខ ទទួលបាន ១២ ៨៥៧ ដុល្លារអាមេរិក។
- គ ទទួលបាន (២០ ០០០ / ៣៥ ០០០ x ៣០ ០០០ = ១៧ ១៤២.៨៥) នោះ គ ទទួលបាន ១៧ ១៤៣ ដុល្លារអាមេរិក។

**៣.១.២.២ ករណីមានភាគនៃវិភាគទាន**

ភាគនៃវិភាគទាន គឺជាប្រភេទមួយនៃការសម្រួលចំណែកមត៌កដោយសារនៅក្នុងចំណោមសន្តតិជនមានបុគ្គលម្នាក់ ឬច្រើននាក់បានធ្វើសកម្មភាពថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ឬថែទាំព្យាបាលមតកជន ឬបានធ្វើសកម្មភាពផ្សេងៗដែលចម្រើនដល់មតកជន។ សន្តតិជនអាចធ្វើវិភាគទាន ចំពោះមតកជនទៅតាមប្រភេទផ្សេងៗគ្នាបាន ដែលការធ្វើវិភាគនោះអាចជាៈ

- វិភាគទានជាការគ្រប់គ្រងទ្រព្យសម្បត្តិៈ ការជួយគ្រប់គ្រង និងការពារទ្រព្យសម្បត្តិរបស់មតកជនមិនឲ្យបាត់បង់ ឬវិនាសនៅពេលដែលមតកជនមានភារកិច្ចមិនអាចបំពេញការងារ ឬពេលដែលមតកជនមានជម្ងឺ។

- វិភាគទានជាគេហកិច្ចៈ ការជួយរកស៊ីមតកជន ដោយសន្តតិជនបានលះបង់នូវពេលវេលាផ្ទាល់ខ្លួន ដែលបានធ្វើឲ្យទ្រព្យមតកជនកើនឡើង និងមិនធ្វើឲ្យមានការខាតបង់នូវទ្រព្យសម្បត្តិរបស់មតកជន។
- វិភាគទានជាការចេញដើមទុនៈ ការឲ្យដើមទុនសម្រាប់ទៅរកស៊ី។
- វិភាគទានជាការថែទាំៈ ការលះបង់នូវពេលវេលានិងថវិកាផ្ទាល់ខ្លួនដើម្បីព្យាបាលជម្ងឺរបស់មតកជន។[155]

ភាគនៃវិភាគទាននេះ ជាការបង្រួមចំនួនមត៌កដើម្បីឲ្យមានសមភាពជាក់ស្តែងនៅចំណោមសន្តតិជនទាំងអស់ ដោយបុគ្គលណាម្នាក់ ឬច្រើននាក់បានចំណាយសម្រាប់មតកជនមុនពេលចាប់ផ្តើមសន្តតិកម្ម។[156] ជាទូទៅ កាលណាទ្រព្យសម្បត្តិរបស់មតកជនមិនបាត់បង់ ប្រយោជន៍របស់សន្តតិជនក៏ទទួលបានច្រើនទៅតាមនោះដែរ។ ហេតុនេះ ប្រសិនបើមានសន្តតិជនបានចំណាយនូវធនធានផ្ទាល់ខ្លួន ដើម្បីថែរក្សានូវទ្រព្យសម្បត្តិរបស់មតកជន នោះផលដែលកើតចេញពីសកម្មភាពទាំងនោះនឹងត្រូវទទួលដោយសន្តតិជនផ្សេងទៀតជាមិនខាន។ ដូច្នេះ វានឹងមិនមានតុល្យភាពទេរវាងសន្តតិជនដែលបានធ្វើវិភាគទាន ហើយបែរជាទទួលបានចំណែកស្មើគ្នាពេលចាប់ផ្តើមសន្តតិកម្ម។

ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេសដើម្បីថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬដោយការថែទាំព្យាបាលមតកជន ឬដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគនៅក្នុងសន្តតិកម្មដែលបានគណនាបូកនឹងភាគនៃវិភាគទានត្រូវជាចំណែកមត៌ករបស់ជននោះ។[157] ក្នុងករណីមានភាគនៃវិភាគទាន យើងត្រូវពិចារណាទៅលើចំណុចមួយចំនួនដូចជាៈ

- កំណត់ភាគនៃវិភាគឲ្យបានច្បាស់
- កំណត់អំពីទ្រព្យដែលត្រូវចាត់ទុកថាជាមត៌ក (ទ្រព្យដែលត្រូវមាន) ដោយដកភាគនៃវិភាគទានចេញពីទ្រព្យសម្បត្តិនៅពេលចាប់ផ្តើមសន្តតិកម្មៈ

| |
|---|
| ទ្រព្យដែលត្រូវចាត់ទុកជាមត៌ក = ទ្រព្យសកម្មពេលចាប់ផ្តើមសន្តតិកម្ម - ភាគនៃវិភាគទាន |

[155] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ៦ (បោះពុម្ពក្នុងខែមីនា ឆ្នាំ២០១២), ៣៤។
[156] អ៊ីវ ប៉ូលី, "ការបែងចែកមត៌ក," (មេរៀនសម្រាប់សម្រាប់ចែករំលែក, វិភាគទានច្បាប់, ១៥ មករា ២០១៨), ១៥។
[157] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦៦ កថាខណ្ឌទី ១។

- យកទ្រព្យដែលត្រូវចាត់ទុកថាជាមត៌ក គណនាចំណែកមត៌ក រួចបូកបន្ថែមនូវភាគនៃវិភាគទាន ហើយគណនាចំណែកមត៌កជាក់ស្តែង៖

| |
|---|
| ចំណែកមត៌កជាក់ស្តែង = (ទ្រព្យដែលចាត់ទុកជាមត៌ក ÷ ចំនួនសន្តតិជនសរុប) + ភាគនៃវិភាគទាន |

ឧទាហរណ៍៖ នៅពេលមរណភាព ឪពុកដែលជាមតកជនមានដី និងផ្ទះដែលមានតម្លៃ ៣០ ០០០ដុល្លារអាមេរិក និងមានប្រាក់បញ្ញើនៅធនាគារ ៣០ ០០០ដុល្លារអាមេរិក។ គាត់មានកូន ក និង ខ ដែលត្រូវជាសន្តតិជន។ កាលនៅរស់ ឪពុកបានគ្រប់គ្រងអាជីវកម្មរបស់ខ្លួនតែម្នាក់ឯង ប៉ុន្តែដោយសារឪពុកមានអាយុកាន់តែច្រើន កូនច្បង ក ក៏បានធ្វើការគ្រប់គ្រងអាជីវកម្មនោះជំនួសឪពុកតែម្នាក់ឯង។ គេបានវាយតម្លៃថា ការចូលរួមចំណែករបស់ ក បានរក្សា និងបង្កើនទ្រព្យសម្បត្តិរបស់មតកជនដែលជាឪពុកចំនួន ២០ ០០០ដុល្លារអាមេរិក។

ក្នុងករណីនេះ៖

- តម្លៃនៃទ្រព្យដែលមានពេលចាប់ផ្តើមសន្តតិកម្មគឺ ៦០ ០០០ដុល្លារអាមេរិក (ដី ផ្ទះ ៣០ ០០០ដុល្លារអាមេរិក + ប្រាក់បញ្ញើ ៣០ ០០០ដុល្លារអាមេរិក)
- តម្លៃនៃភាគនៃវិភាគទានរបស់ ក គឺ ២០ ០០០ដុល្លារអាមេរិក
- ទ្រព្យដែលត្រូវចាត់ទុកថាជាមត៌កគឺ ៤០ ០០០ដុល្លារអាមេរិក (ទ្រព្យសកម្មពេលចាប់ផ្តើមសន្តតិកម្ម ៦០ ០០០ដុល្លារអាមេរិក - ភាគនៃវិភាគទានរបស់ គ ២០ ០០០ដុល្លារអាមេរិក)
- នោះចំណែកមត៌កជាក់ស្តែងរបស់សន្តតិជននីមួយៗទទួលបានគឺ៖
  - ក ទទួលបាន ៤០ ០០០ដុល្លារអាមេរិក (៤០ ០០០ / ២នាក់ + ២០ ០០០ ដែលជាភាគនៃវិភាគទាន)។
  - ខ ទទួលបាន ២០ ០០០ដុល្លារអាមេរិក (៤០ ០០០ / ២នាក់)។

ការកំណត់អំពីចំនួន ឬតម្លៃនៃភាគនៃវិភាគទាន គឺសហសន្តតិជនពិភាក្សា ប៉ុន្តែប្រសិនបើការពិភាក្សាដែលបានកំណត់នេះពុំបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគទាន តាមពាក្យសុំរបស់បុគ្គលដែលបានធ្វើវិភាគទាន ដោយពិចារណាទៅលើពេល វិធី និងកម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និងស្ថានភាពទាំងអស់ផ្សេងទៀត។[158] ម្យ៉ាងទៀត ចំពោះពាក្យសុំនេះផងដែរ អាចធ្វើបានក្នុងករណីមានពាក្យសុំដោយយោងតាមកថាខណ្ឌទី១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬមានពាក្យបណ្តឹងដោយយោងតាមមាត្រា ១២៤៧ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក)។[159]

[158] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦៦ កថាខណ្ឌទី ២។
[159] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦៦ កថាខណ្ឌទី ៤។

ក្នុងករណីភាគនៃវិភាគទាន លើសចំណែកមត៌កដែលមានកំណត់ក្នុងបណ្ដាំមត៌ក ត្រូវយកបណ្ដាំមត៌កជាគោល ពោលគឺភាគនៃវិភាគទានមិនអាចឲ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និងតម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្មឡើយ មានន័យថាមតកសាសន៍ មានអាទិភាពជាងភាគនៃវិភាគទាន។[160]

### ៣.១.២.៣ ករណីមានភាគនៃវិភាគទាន និងផលប្រយោជន៍ពិសេសក្នុងពេលតែមួយ

ឧទាហរណ៍៖ នៅពេលមរណភាព ឪពុកដែលជាមតកជនមានដី និងផ្ទះដែលមានតម្លៃ ៣ ៥០០ដុល្លារអាមេរិក និងមានប្រាក់បញ្ញើនៅធនាគារ ៣ ៥០០ដុល្លារអាមេរិក។ គាត់មានកូន ក ខ និង គ ដែលត្រូវជាសន្តតិជន។ កាលនៅរស់ ឪពុកបានគ្រប់គ្រងអាជីវកម្មរបស់ខ្លួនតែម្នាក់ឯង ប៉ុន្តែដោយសារឪពុកមានអាយុកាន់តែច្រើន កូនច្បង ក ក៏បានធ្វើការគ្រប់គ្រងអាជីវកម្មនោះនោះជំនួសឪពុកតែម្នាក់ឯង។ គេបានវាយតម្លៃថា ការចូលរួមចំណែករបស់ ក បានរក្សា និងបង្កើនទ្រព្យសម្បត្តិរបស់មតកជនដែលជាឪពុកចំនួន ៣ ០០០ដុល្លារអាមេរិក។ ម៉្យាងទៀត កាល ខ រៀបអាពាហ៍ពិពាហ៍ ឪពុកបានឲ្យផ្ទះទៅ ខ ដែលមានតម្លៃ ៦ ០០០ដុល្លារអាមេរិកសម្រាប់ជាចំណងដៃ។ ប៉ុន្តែ នៅពេលឪពុកឈឺ គ បានចំណាយថ្លៃព្យាបាល និងធ្វើបុណ្យសពដែលចំណាយអស់ ១ ០០០ដុល្លារអាមេរិក។ ក្នុងករណីនេះ៖

- តម្លៃនៃទ្រព្យដែលមានពេលចាប់ផ្ដើមសន្តតិកម្មគឺ ៧ ០០០ដុល្លារអាមេរិក (ដី ផ្ទះ ៣ ៥០០ដុល្លារអាមេរិក + ប្រាក់បញ្ញើ ៣ ៥០០ដុល្លារអាមេរិក)
- តម្លៃនៃភាគនៃវិភាគទានរបស់ ក គឺ ៣ ០០០ដុល្លារអាមេរិក
- តម្លៃនៃផលប្រយោជន៍ពិសេស ខ ទទួលបានគឺ ៦ ០០០ដុល្លារអាមេរិក
- តម្លៃនៃភាគនៃវិភាគទានរបស់ គ គឺ ១ ០០០ដុល្លារអាមេរិក
- ទ្រព្យដែលត្រូវចាត់ទុកថាជាមត៌កគឺ ៩ ០០០ដុល្លារអាមេរិក (ទ្រព្យសកម្មពេលចាប់ផ្ដើមសន្តតិកម្ម ៧ ០០០ដុល្លារអាមេរិក - ភាគនៃវិភាគទានរបស់ ក ៣ ០០០ដុល្លារអាមេរិក + ផលប្រយោជន៍ពិសេស ខ ៦ ០០០ដុល្លារអាមេរិក - ភាគនៃវិភាគទានរបស់ គ ១ ០០០ដុល្លារអាមេរិក)
- នោះចំណែកមត៌កជាក់ស្ដែងរបស់សន្តតិជននីមួយៗទទួលបានគឺ៖
    - ក ទទួលបាន ៦ ០០០ដុល្លារអាមេរិក (៩ ០០០ / ៣នាក់ + ៣ ០០០ ដែលជាភាគនៃវិភាគទាន)
    - ខ ទទួលបាន -៣ ០០០ដុល្លារអាមេរិក (៩ ០០០ / ៣នាក់ - ៦ ០០០ ដែលជាផលប្រយោជន៍ពិសេស)

[160] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦៦ កថាខណ្ឌទី ៣។

- គ ទទួលបាន ៤ ០០០ដុល្លារអាមេរិក (៩ ០០០ / ៣នាក់ + ១ ០០០ ដែលជាភាគនៃវិភាគទាន)

ដូចនេះ សន្តតិជន ខ មិនទទួលបានចំណែកមត៌កឡើយ ហើយ ខ ក៏មិនចាំបាច់បង្វិលសងវិញនូវចំណែកដែលទទួលបានលើសនោះដែរ។ ចំណែកឯចំណែករបស់សន្តតិជន ក គឺទទួលបាន ៦ ០០០ដុល្លារអាមេរិក និង គ ទទួលបាន ៤ ០០០ដុល្លារអាមេរិក បូកសរុបទៅគឺ ១០ ០០០ដុល្លារអាមេរិក ប៉ុន្តែចំនួនមត៌កពេលចាប់ផ្តើមសន្តតិកម្មមានតែ ៧ ០០០ដុល្លារអាមេរិកប៉ុណ្ណោះ។ ហេតុដូចនេះហើយ ក និង គ ត្រូវទទួលបានចំណែកមត៌កទៅតាមសមាមាត្រ ៦ ០០០ និង ៤ ០០០ នៃចំនួនមត៌ក ៧ ០០០ដុល្លារអាមេរិក នោះយើងបាន៖

- ក ទទួលបាន (៦ ០០០ / ១០ ០០០ x ៧ ០០០ = ៤ ២០០) នោះ ខ ទទួលបាន ៤ ២០០ដុល្លារអាមេរិក
- គ ទទួលបាន (៤ ០០០ / ១០ ០០០ x ៧ ០០០ = ២ ៨០០) នោះ គ ទទួលបាន ២ ៨០០ដុល្លារអាមេរិក។

### ៣.១.២.៤ ករណីមានប្រទានកម្ម

ប្រទានកម្ម សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងដែលជាទាយក (អ្នកឲ្យ) បានផ្តល់នូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ទៅឲ្យភាគីម្ខាងទៀតដែលជាបដិគ្គាហក (អ្នកទទួល) ហើយភាគីនេះយល់ព្រមទទួល។[161] ក្នុងករណីដែលបដិគ្គាហក ឬអ្នកទទួលបានផលប្រយោជន៍ពិសេស បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬបើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬវិនាសមុនពេលចាប់ផ្តើមសន្តតិកម្ម នោះតម្លៃនៃប្រទានកម្មត្រូវគណនាដោយគិតតម្លៃនៃពេលដែលបានចាត់ចែង ឬនៅពេលបាត់បង់ ឬវិនាសនោះ។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះ ត្រូវបានផ្លាស់ប្តូរដោយសារលទ្ធផលដែលបដិគ្គាហកបានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវគណនាដោយចាត់ទុកថាមានស្ថានភាពដើមនៅពេលចាប់ផ្តើមសន្តតិកម្ម។ ម៉្យាងទៀត ការប្រាក់ និងផលចំណេញ ដែលកើតចេញពីប្រទានកម្មដែលសន្តតិជននោះទទួលបាន ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ។[162]

ដូចនេះ យើងបានតម្លៃផលប្រយោជន៍ពិសេសគឺ៖

- ផលប្រយោជន៍ពិសេសកើនឡើង៖ យកតម្លៃថ្ងៃធ្វើប្រទានកម្មមកធ្វើការគណនា
- ផលប្រយោជន៍ពិសេសធ្លាក់ចុះ៖ យកតម្លៃថ្ងៃបើកសន្តតិកម្មមកធ្វើការគណនា

ឧទាហរណ៍៖ មតកជនមានកូនចំនួន២នាក់ គឺ ក និង ខ ដែលជាសន្តតិជន។ មុនពេលមតកជនទទួលមរណភាពបានឱ្យដីទៅ ក ដែលមានតម្លៃ ៤០ ០០០ ដុល្លារអាមេរិក និងបានឱ្យរថយន្តតម្លៃ ២៥ ០០០ ដុល្លារអាមេរិក ទៅ

[161] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ១៤, លេខ ៩៩។

[162] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១១៦៤

ខ។ ពេលមតកជនបានទទួលមរណភាពបានបន្សល់ទុកមត៌កចំនួន ៥០ ០០០ ដុល្លារអាមេរិក។ នៅថ្ងៃបើកសន្តតិកម្ម ដីដែលជាប្រទានកម្មបានកើនឡើងដល់ ៦០ ០០០ ដុល្លារអាមេរិក រីឯតម្លៃនៃរថយន្តនៅថ្ងៃបើកសន្តតិកម្មបានធ្លាក់ចុះសល់ ២០ ០០០ ដុល្លារអាមេរិក។

យោងតាមមាត្រា ១១៦៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា៖

- ការគណនាតម្លៃដីដែលមតកជនបានធ្វើប្រទានកម្មទៅឱ្យ ក គឺត្រូវយកតម្លៃនៅថ្ងៃធ្វើប្រទានកម្មគឺ ៤០ ០០០ ដុល្លារអាមេរិក។
- ការគណនាតម្លៃរថយន្តដែលមតកជនបានធ្វើប្រទានកម្មទៅឱ្យ ខ គឺត្រូវយកតម្លៃនៅថ្ងៃបើកសន្តតិកម្មគឺ ២០ ០០០ ដុល្លារអាមេរិក។

ដូចនេះ ចំណែកមត៌កសរុប = ៥០ ០០០ + ៤០ ០០០ + ២០ ០០០ = ១១០ ០០០ ដុល្លារអាមេរិក។

## ៣.២ អំពីស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់

ស្ថានភាពពិសេសនៃសន្តតិកម្ម សំដៅទៅលើស្ថានភាពមួយនៅពេលដែលសន្តតិកម្មបានចាប់ផ្ដើម ប៉ុន្តែគ្មានសន្តតិជនដែលជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចនៃមត៌ក ហើយតម្រូវឲ្យមានការស្វែងរកសន្តតិជនដើម្បីមកស្នងនូវមត៌កទាំងនោះ។ ចំពោះស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់ អាចកើតឡើងបានក្នុងស្ថានភាពនត្ថិភាពនៃសន្តតិជនដែលនឹងលើមកបកស្រាយនៅចំណុច ៣.២.១ និងក្នុងស្ថានភាពការធ្វើនូវបដិទាននៃសន្តតិកម្មដែលនឹងធ្វើការបកស្រាយនៅចំណុច ៣.២.២។

### ៣.២.១ នត្ថិភាពនៃសន្តតិជន

នៅពេលដែលមតកជនទទួលមរណភាព នោះទ្រព្យសម្បត្តិរបស់គាត់នឹងត្រូវទទួលបន្តដោយសន្តតិជន។ ប្រសិនបើមានសន្តតិជន ប៉ុន្តែពួកគេបានបាត់ខ្លួន នោះបញ្ញត្តិស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់បុគ្គលដែលអវត្តមាន និងប្រកាសការបាត់ខ្លួន ត្រូវយកមកអនុវត្ត។ ក្នុងស្ថានភាពដែលមិនច្បាស់ថាមាន ឬគ្មានសន្តតិជនដើម្បីស្នងនូវមត៌កទេ នោះមត៌កទាំងនោះនឹងត្រូវក្លាយជានីតិបុគ្គលដោយស្វ័យប្រវត្តិ ឬអាចត្រូវធ្លាក់ទៅលើជនដែលមានប្រយោជន៍ពិសេសជាមួយនឹងមតកជន ឬធ្លាក់ទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ។

#### ៣.២.១.១ មត៌កជានីតិបុគ្គល

ក្នុងករណីដែលពុំច្បាស់ថាមានសន្តតិជនទេ នោះមត៌កនឹងទាំងនោះនឹងត្រូវក្លាយជានីតិបុគ្គល។[163] ភាពដែលមិនច្បាស់ថាមានសន្តតិជននេះរួមមាន ករណីដែលពុំមានសន្តតិជនសោះ ឬមានសន្តតិជនដែរ ប៉ុន្តែពួកគេជាជនបរទេសដែលមិនមានសញ្ជាតិខ្មែរ ឬពួកគេទាំងអស់បានបោះបង់នូវសន្តតិកម្ម ឬក្នុងករណីសន្តតិជននោះ

[163] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩០។

ជាអភ័ព្វបុគ្គល ឬជាជនដែលត្រូវផ្ដាច់ចេញពីមត៌ក ហើយគ្មានសន្តតិជនជំនួស។ ករណីដែលត្រូវក្លាយជានីតិបុគ្គលមត៌កនេះ ដោយសារតែនៅពេលគ្មានសន្តតិជន ប្រធាននៃសិទ្ធិមត៌កនោះក៏គ្មានដូចគ្នា។ ដូចនេះប្រសិនបើគ្មានបញ្ញត្តិអំពីនីតិបុគ្គលមត៌កនេះទេ នោះអចលនវត្ថុត្រូវធ្លាក់ទៅជាកម្មសិទ្ធិរបស់រដ្ឋ[164] ចំណែកឯចលនវត្ថុវិញ អ្នកដែលបានកាន់កាប់ពីមុននឹងត្រូវក្លាយជាកម្មសិទ្ធិករនៃចលនវត្ថុនោះ[165] ជាហេតុដែលនឹងធ្វើឲ្យម្ចាស់បំណុលរបស់មតកជនមានការពិបាកក្នុងការទាមទារបំណុល ឬក៏អាចបណ្ដាលឲ្យមានការប្រជែងយកនូវចលនវត្ថុដែលធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សង្គមផងដែរ។[166] ក៏ប៉ុន្តែ នីតិបុគ្គលនេះ គឺតម្រូវឲ្យមានអ្នកគ្រប់គ្រងមត៌កជាដាច់ខាត។

### ក. ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក

នៅពេលដែលមត៌កក្លាយទៅជានីតិបុគ្គល នោះនីតិបុគ្គលត្រូវគ្រប់គ្រងដោយអ្នកគ្រប់គ្រងមត៌ក ដែលអ្នកគ្រប់គ្រងមត៌កនេះត្រូវជ្រើសតាំងដោយតុលាការ តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានចុងក្រោយរបស់មតកជន ឬតំណាងអយ្យការ។[167]

អ្នកគ្រប់គ្រងមត៌ក គឺជាអ្នកតំណាងរបស់នីតិបុគ្គលមត៌ក (អ្នកតំណាងដែលច្បាប់កំណត់) ហើយធ្វើសកម្មភាពក្នុងនាមជាអ្នកគ្រប់គ្រងនីតិបុគ្គលមត៌ករបស់មតកជន។ ម្យ៉ាងទៀត អ្នកគ្រប់គ្រងនេះត្រូវទទួលនូវសិទ្ធិកាតព្វកិច្ច និងត្រូវប្រតិបត្តិនូវកិច្ចការច្បាប់មួយចំនួនធំ ហេតុនេះបានជាការជ្រើសតាំងអ្នកគ្រប់គ្រងភាគច្រើនគឺជ្រើសតាំងអ្នកច្បាប់ ដូចជាមេធាវីជាដើម។[168] ជាក់ស្ដែង សិទ្ធិ និងកាតព្វកិច្ច ព្រមទាំងការងារសំខាន់ៗរបស់អ្នកគ្រប់គ្រងមត៌ក គឺជាការក្ដាប់ឲ្យដឹងអំពីមត៌កទាំងអស់ ការសងបំណុលរបស់មតកជន ហើយការបែងចែកមត៌កដែលនៅសល់ទៅឲ្យអ្នកមាននិស្ស័យពិសេស ឬបង្វិលមត៌កនោះទៅឲ្យរដ្ឋ ហើយដើម្បីធ្វើការងារទាំងនេះ នៅក្នុងករណីចាំបាច់ត្រូវចាត់ចែងប្ដូរមត៌កនោះជាប្រាក់ ដោយទទួលការអនុញ្ញាតពីតុលាការ។ ក្រៅពីនេះ អ្នកគ្រប់គ្រងមត៌ក ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌទាក់ទងទៅនឹងមត៌ក ទាំងទ្រព្យសកម្ម និងកាតព្វកិច្ចរបស់សន្តតិកម្មដែលអាចដឹងបានដោយគ្មានការយឺតយ៉ាវ។[169] ចំពោះកម្រៃសម្រាប់អ្នកគ្រប់គ្រង តុលាការអាចផ្ដល់ជាកម្រៃសមរម្យចេញពីក្នុងចំណោមមត៌ក ឲ្យទៅអ្នកគ្រប់គ្រងបានដោយគិតពិចារណាទៅលើស្ថានភាពនៃមត៌ក និងស្ថានភាពផ្សេងទៀត។[170] ក្នុងករណីដែលបានដឹងថាមានសន្តតិជន នៅក្រោយពេលជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក នីតិបុគ្គល

[164] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៦១។

[165] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៨៧។

[166] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៥១-១៥២។

[167] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩១ កថាខណ្ឌទី ១។

[168] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៥២។

[169] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩២ កថាខណ្ឌទី ១។

[170] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩៣។

មត៌កនោះត្រូវចាត់ទុកថាគ្មានអត្ថិភាពតាំងពីដំបូង ហើយចាត់ទុកថាសន្តតិជនបានទទួលសន្តតិកម្មមត៌កនោះតាំងពីមតកជនទទួលមរណភាព។[171] ម៉្យាងទៀត ចំពោះសកម្មភាពដែលអ្នកគ្រប់គ្រងបានធ្វើហើយ ក្នុងទំហំសិទ្ធិអំណាចរបស់ខ្លួននៅមានអានុភាព មានន័យថាសកម្មភាពដែលបានធ្វើឡើងក្រោមសិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងមត៌កត្រូវចាត់ទុកថាមានសុពលភាព ដើម្បីការពារប្រយោជន៍របស់តតិយជនផងដែរ។ យ៉ាងណាមិញ សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងនេះ ត្រូវរលត់បានលុះត្រាតែមានការយល់ព្រមទទួលសន្តតិកម្មពីសន្តតិជន មិនថាជាការយល់ព្រមទាំងស្រុង ឬមានកម្រិតនោះទេ លើកលែងតែសន្តតិជននោះបោះបង់សន្តតិកម្ម។ បើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្ម ហើយអ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ដោយបង្ហាញឲ្យច្បាស់នូវស្ថានភាពដែលខ្លួនបានគ្រប់គ្រងដល់ពេលនោះ ដោយគ្មានការយឺតយ៉ាវ។[172]

**ខ. ការជូនដំណឹងជាសាធារណៈ**

នៅពេលដែលតុលាការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កហើយ តុលាការត្រូវធ្វើការជូនដំណឹងអំពីការណ៍នេះដោយគ្មានការយឺតយ៉ាវ។[173] ការជូនដំណឹងជាសាធារណៈនេះ ត្រូវធ្វើឡើងតាមរយៈការបិទប្រកាសរបស់តុលាការ និងការចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌។[174]

គោលបំណងនៃនីតិបុគ្គលមត៌ក គឺការជម្រះមត៌ក ហេតុនេះជាបឋម មត៌កត្រូវយកទៅសងម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភី។ ដូចនេះ បើពុំដឹងច្បាស់អំពីអត្ថិភាពនៃសន្តតិជនទេ ក្នុងអំឡុងពេល២(ពីរ)ខែបន្ទាប់ពីបានជូនដំណឹងជាសាធារណៈនៃការជ្រើសតាំងអ្នកគ្រប់គ្រងហើយ នោះអ្នកគ្រប់គ្រងមត៌កត្រូវជូនដំណឹងជាសាធារណៈ ដោយគ្មានការយឺតយ៉ាវទៅម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភីទាំងអស់អំពីការណ៍ដែលម្ចាស់បំណុល និងអច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារក្នុងអំឡុងដែលបានកំណត់ ដែលអំឡុងពេលនេះមិនត្រូវតិចជាង ២(ពីរ)ខែឡើយ។[175] ការជូនដំណឹងជាសាធារណៈ និងការដាស់តឿនចំពោះម្ចាស់បំណុលជាអាទិ៍នេះ ត្រូវធ្វើឡើងតាមរយៈការបិទប្រកាសរបស់តុលាការ និងការចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌។[176] ម៉្យាងទៀត អ្នកគ្រប់គ្រងមត៌កនេះពុំអាចក្លាយជាអ្នកទិញក្នុងការលក់ដោយបង្ខំ ឬការលក់តាមរយៈការប្តូរជាប្រាក់បាននោះឡើយ។[177]

[171] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩៤ វាក្យខណ្ឌទី ១។

[172] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩៥។

[173] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩១ កថាខណ្ឌទី ២។

[174] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា ១២ កថាខណ្ឌទី ២ (ពីពេលនេះតទៅហៅថា ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី) ។

[175] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩៦ កថាខណ្ឌទី ១។

[176] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, មាត្រា ១២ កថាខណ្ឌទី ២។

[177] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩៦ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២។

ក្រោយពីអំឡុងពេល២(ពីរ)ខែ នៃការជូនដំណឹងជាសាធារណៈ និងការដាស់តឿនចំពោះម្ចាស់បំណុលជាអាទិ៍នេះ បានកន្លងហួស ប្រសិនបើនៅតែមិនទាន់ដឹងច្បាស់ថាមានសន្តតិជននៅឡើយទេ នោះតុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈដើម្បីស្វែងរកសន្តតិជន ទៅតាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬតំណាងអយ្យការ។ ប៉ុន្តែ ប្រសិនបើមានសន្តតិជន សន្តតិជននោះត្រូវធ្វើការស្នើសុំអំពីការណ៍នោះក្នុងអំឡុងពេលកំណត់ ដែលអំឡុងពេលនេះមិនត្រូវតិចជាង ៦(ប្រាំមួយ)ខែឡើយ។[178] ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជននេះផងដែរត្រូវធ្វើឡើងតាមរយៈការបិទប្រកាសរបស់តុលាការ និងការចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌។[179] គោលបំណងនៃការជូនដំណឹងនេះទៀតសោត គឺដើម្បីផ្តល់នូវទ្រព្យសម្បត្តិដែលនៅសេសសល់ទៅឲ្យសន្តតិជននោះ បើប៉ាន់ប្រមាណឃើញថាគ្មានសេសសល់មត៌កទេនោះ អ្នកគ្រប់គ្រង ឬតំណាងអយ្យការមិនអាចធ្វើការទាមទារស្នើសុំស្វែងរកសន្តតិជនឡើយ។[180] ម៉្យាងវិញទៀត ក្នុងករណីបើគ្មានការស្នើសុំថាខ្លួនជាសន្តតិជន ក្នុងអំឡុងការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជននេះទេ សន្តតិជននោះពុំអាចអនុវត្តសិទ្ធិទទួលមត៌កតាមរយៈសន្តតិកម្មបានឡើយ។[181] ហេតុនេះ ក្នុងករណីដែលគ្មានសន្តតិជនបង្ហាញខ្លួនតាមការប្រកាសជាសាធារណៈស្វែងរកនេះទេ នោះការដកហូតនូវសិទ្ធិរបស់សន្តតិជនត្រូវយកមកអនុវត្ត ដើម្បីធ្វើការបែងចែកមត៌កទៅឲ្យអ្នកដែលមាននិស្ស័យពិសេស ជាអាទិ៍។ ចំណែកឯ ម្ចាស់បំណុល ឬអច្ច័យលាភីដែលអ្នកគ្រប់គ្រងមិនបានដឹង ដោយសារតែមិនបានស្នើសុំអំពីការទាមទារសិទ្ធិក្នុងអំឡុងពេលប្រកាសជាសាធារណៈ និងការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍ទេ នោះជាបឋមគឺអាចទទួលបានការសងពីទ្រព្យដែលនៅសេសសល់តែប៉ុណ្ណោះ។ លើសពីនេះ ប្រសិនពុំបានស្នើសុំសិទ្ធិក្នុងអំឡុងពេលការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជនថែមទៀតទេ នោះនឹងត្រូវដកហូតសិទ្ធិ។[182]

### ៣.២.១.២ ជនដែលមាននិស្ស័យពិសេស

ជនដែលមាននិស្ស័យពិសេស អាចជាជនដែលមានជីវភាពជាមួយនឹងមតកជន ជនដែលបានខិតខំប្រឹងប្រែងមើលថែទាំព្យាបាលមតកជន និងជនដែលមាននិស្ស័យផ្សេងទៀត ទោះបីជាជននោះពុំមានទំនាក់ទំនងញាតិលោហិតជាមួយមតកជនក៏ដោយ។ ជនដែលមាននិស្ស័យពិសេសនេះ អាចដាក់ពាក្យសុំទៅតុលាការ ដើម្បីឲ្យតុលាការចែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ក្រោយការជម្រះមកឲ្យខ្លួន តាមពាក្យសុំរបស់ជននោះបន្ទាប់ពីអំឡុងពេលនៃការជូនដំណឹងស្វែងរកសន្តតិជនបានកន្លងផុត។ ក៏ប៉ុន្តែ ចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវ

---

[178] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩៧ កថាខណ្ឌទី ១។

[179] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, មាត្រា ១២ កថាខណ្ឌទី ២។

[180] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩៧ កថាខណ្ឌទី ២។

[181] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩៨។

[182] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៥៨។

ចែកទៅឲ្យនោះ គឺមិនត្រូវលើសពីពាក់កណ្ដាលនៃមត៌កដែលនៅសល់នោះទេ។[183] ក្នុងករណីដែលមានជនមាននិស្ស័យពិសេសមានចំនួនច្រើន នោះត្រូវបែងចែកមត៌កឲ្យជនមាននិស្ស័យពិសេសទាំងនោះមួយភាគម្នាក់ ទៅតាមទំហំនៃនិស្ស័យពិសេសនោះ។ អាចមានករណីច្រើនដែលមតកជនគ្មានសន្តតិជន ហើយរស់នៅពឹងផ្អែកដោយជំនួយពីសង្គម ដូច្នេះ គួរសងគុណសង្គមវិញដោយឲ្យមត៌កនោះទៅជាទ្រព្យរដ្ឋយ៉ាងតិចពាក់កណ្ដាល។[184]

យ៉ាងណាមិញ ចំពោះពាក្យសុំរបស់ជនដែលមាននិស្ស័យពិសេស ត្រូវធ្វើឡើងក្នុងអំឡុងពេល៣(បី)ខែក្រោយអំឡុងពេលជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជនបានកន្លងហួស ដោយបញ្ជាក់ឲ្យបានច្បាស់លាស់អំពីអង្គហេតុនៃនិស្ស័យពិសេសនោះ។ ម្យ៉ាងទៀត តុលាការអាចធ្វើការស្រាវជ្រាវអំពីអង្គហេតុទាំងនេះដោយអាចសាកសួរយោបល់ពីមេឃុំ ឬចៅសង្កាត់បាន។[185]

#### ៣.២.១.៣ មត៌កដែលក្លាយជារបស់រដ្ឋ

ចំពោះមត៌កជាអចលវត្ថុ ដែលជាកម្មវត្ថុនៃសន្តតិកម្ម ហើយគ្មានសន្តតិជនស្នងលើអចលនវត្ថុនោះទេ នោះអចលនវត្ថុនោះនឹងត្រូវក្លាយទៅជារបស់រដ្ឋ។[186] ចំណែកឯ មត៌កដែលមិនត្រូវបានបែងចែកទៅឲ្យជនដែលមាននិស្ស័យពិសេសទេ ក៏ត្រូវធ្លាក់ទៅជារបស់រដ្ឋដែរ។ ក្នុងករណីនេះ អ្នកគ្រប់គ្រងមត៌កត្រូវធ្វើការគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការដោយគ្មានការយឺតយ៉ាវ។[187]

### ៣.២.២ ការធ្វើបដិទាននៃសន្តតិកម្ម

ការធ្វើបដិទានសន្តតិកម្ម សំដៅទៅលើការទាមទាររបស់សន្តតិជនពិតប្រាកដ ឲ្យធ្វើការទាមទារនូវចំណែក មត៌កនៃសន្តតិកម្ម ពីជនដែលត្រូវបានគេយល់ឃើញថាជាសន្តតិជន ប៉ុន្តែការពិតជននោះពុំមែនជាសន្តតិជននោះទេ ហេតុនេះ សន្តតិជនពិតប្រាកដអាចទាមទារឲ្យជននោះ ប្រគល់មកវិញនូវទ្រព្យដែលបានទទួលនោះមកវិញតាមសិទ្ធិសន្តតិកម្ម។[188] ម្យ៉ាងទៀត ចំពោះការទាមទារឲ្យធ្វើបដិទាននេះទៀតសោត មានភាពខុសគ្នានឹងករណីដែលសន្តតិជនធ្វើការទាមទារដើម្បីយកមត៌កមកវិញ នៅក្នុងករណីដែលតតិយជនគ្មានការពាក់ព័ន្ធបានកាន់កាប់នូវមត៌កដោយគ្មានសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តនៃការកាន់កាប់។ បន្ថែមពីនេះ ការទាម

[183] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩៩ កថាខណ្ឌទី ១។

[184] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹទី៨-ទី៩, ១៦០។

[185] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១២៩៩ កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣។

[186] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៦១។

[187] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៣០០។

[188] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៣០២។

ទារដើម្បីយកមត៌កមកវិញជាការទាមទារតាមបញ្ញត្តិសិទ្ធិប្រត្យក្ស ជាអាទិ៍ មិនមែនតាមបញ្ញត្តិនៃការទាមទារបដិទានសន្តតិកម្មនោះទេ។[189]

មូលហេតុដែលអាចបណ្តាលឲ្យមានការទាមទារបដិទានសន្តតិកម្ម មានករណីដូចខាងក្រោម៖

- ករណីដែលបុគ្គលដែលគ្មានលក្ខណៈសម្បត្តិជាសន្តតិជនបានទទួលសន្តតិកម្ម៖ កំណត់ត្រាខុសនៃសំបុត្រកំណើត ឬការក្លែងបន្លំនៃសំបុត្រកំណើត ដែលបណ្តាលឲ្យកូនមិនពិតប្រាកដទទួលនូវចំណែកមត៌កពីមកតជនដោយផ្អែកទៅលើសំបុត្រកំណើតនេះ។

- ករណីដែលសន្តតិជនទទួលនូវសន្តតិកម្មលើសចំណែកមត៌ករបស់ខ្លួន៖ ករណីមតកជនមុននឹងមានគ្រួសារថ្មី បានមានកូនជាមួយអ្នកផ្សេងហើយបានទទួលស្គាល់កូននោះពេលនៅរស់ ប៉ុន្តែនៅពេលសន្តតិកម្មចាប់ផ្តើមមានការទទួលសន្តតិកម្មតែក្នុងគ្រួសារថ្មី ជាអាទិ៍។[190]

ជាគោលការណ៍ ក្នុងករណីដែលពុំមែនជាសន្តតិជនបានទទួលចំណែកមត៌ក ហើយបានលក់មត៌កនោះទៅឲ្យ តតិយជនណាម្នាក់។ ក្នុងករណីនេះ សន្តតិជនពិតប្រាកដមិនអាចទាមទារឲ្យធ្វើបដិទានមត៌កនោះចំពោះអ្នកទិញ ត្រឡប់មកវិញបានទេ ប៉ុន្តែអាចធ្វើការទាមទារនូវថ្លៃលក់ដែលជាវត្ថុជំនួសមត៌កនោះបាន។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទិញនោះ បានដឹងថាជនដែលជាអ្នកលក់នោះគ្មានសិទ្ធិសន្តតិកម្មទៅលើមត៌កនោះទេ ហើយនៅតែធ្វើកិច្ចសន្យាលក់ទិញទៀត នោះសន្តតិជនពិតប្រាកដអាចទទួលមកវិញនូវវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនោះ ដោយអះអាងថាកម្មសិទ្ធិលើវត្ថុនោះមិនត្រូវបានផ្ទេរទៅអ្នកទិញដោយកិច្ចសន្យានោះទេ ព្រោះអ្នកទិញមានចេតនាទុច្ចរិត។[191]

តួយ៉ាង ចំពោះខ្លឹមសារនៃការប្រគល់វិញរបស់ភាគីម្ខាងទៀតនៃការទាមទារឲ្យធ្វើបដិទានសន្តតិកម្ម គឺត្រូវប្រគល់ត្រឡប់មកវិញនូវមត៌កតនោះមកឲ្យសន្តតិជនពិតប្រាកដដែលបានទាមទារវិញ។ ប្រសិនបើជនដែលមិនមែនជាសន្តតិជនពិតប្រាកដនោះជាជនសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល ការប្រាក់ដែលទទួលបាន និងសិទ្ធិទាមទារឲ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃនៃទ្រព្យនោះ ព្រមទាំងមានសិទ្ធិទាមទារសំណងកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបានសងរួចហើយនោះ។[192] ដោយឡែក ប្រសិនបើជននោះជាជនទុច្ចរិត ជននោះមានកាតព្វកិច្ចប្រគល់ត្រឡប់មកវិញនូវផល និងការប្រាក់ដែលបានទទួល មិនតែប៉ុណ្ណោះជននោះមិនត្រឹមតែគ្មានសិទ្ធិទាមទារសំណងកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបាន

[189] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៦១។
[190] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៦១-១៦២។
[191] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, គន្លឹះទី៨-ទី៩, ១៦៣។
[192] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៣០៣ កថាខណ្ឌទី ១។

សងនោះទេ ថែមទាំងគ្មានសិទ្ធិទាមទារឲ្យសងនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះផងដែរ។[193] ម្យ៉ាងទៀត ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម គឺមានអំឡុងពេល៥(ប្រាំ)ឆ្នាំ។ ក្នុងករណីនៃសហសន្តតិកម្ម ត្រូវធ្វើការគណនាពីថ្ងៃដែលមត៌កត្រូវបានផ្ទេរតាមមតកសាសន៍ ឬការបែងចែកមត៌កចំណែកឯករណីដែលបានទទួលសន្តតិកម្មតែឯងវិញ ទ្រព្យសម្បត្តិត្រូវបានផ្ទេរនៅថ្ងៃដែលមតកជនទទួលមរណភាព។ ហេតុដូចនេះ ក្នុងអំឡុងកាលនៃការរំលត់សិទ្ធិនោះ ត្រូវធ្វើការគណនាចាប់ពីថ្ងៃដែលមតកជនទទួលមរណភាពដែរ។[194]

[193] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៣០៣ កថាខណ្ឌទី ២។

[194] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, មាត្រា ១៣០៤។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការបកស្រាយទៅលើប្រធានបទ "**សន្តតិកម្មតាមច្បាប់**" រួចមកយើងអាចធ្វើការសន្និដ្ឋានបានថា សន្តតិកម្ម គឺជារបបគតិយុត្តមួយដែលបង្កើតឡើង ក្នុងគោលបំណងរក្សាស្ថេរភាពនៃទំនាក់ទំនងឯកជនរវាងបុគ្គល និងបុគ្គល ព្រមទាំងដើម្បីគោរពសិទ្ធិរបស់ញាតិភាពរបស់មតកជន ឬជនដែលមាននិស្ស័យពិសេសរបស់មតកជន ដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ នៃគន្ថីទី៨។ បន្ថែមពីនេះ ក្រមនេះក៏បានបង្ហាញពីការបែងចែកមត៌កទៅឲ្យសន្តតិជនដោយមិនមានភាពលម្អៀង ដោយភាគច្រើនប្រជាពលរដ្ឋគ្រប់រូបគិតថាការបែងចែកមត៌កនេះ គឺទទួលបានទ្រព្យសម្បត្តិស្មើគ្នា ដោយមិនគិតពីអតីតភាពថាបុគ្គលណាម្នាក់ដែលជាសន្តតិជននោះ បានទទួលនូវផលប្រយោជន៍ពិសេស ឬក៏បានធ្វើភាគនៃវិភាគទានជាមួយមតកជនពីមុនឡើយ។ ក៏ប៉ុន្តែ អ្វីដែលត្រឹមត្រូវតាមច្បាប់ដែលបានចែងពីបញ្ហានេះគឺ កាលបើបុគ្គលណាម្នាក់ធ្លាប់ទទួលបាននូវផលប្រយោជន៍ពិសេសពីមតកជន ឬបានធ្វើភាគនៃវិភាគទានទៅឲ្យមតកជននោះនាំឲ្យជននោះមិនអាចទទួលបាននូវចំណែកមត៌កស្មើគ្នានឹងបុគ្គលផ្សេងទៀតបានទេ នេះគឺជាភាពយុត្តិធម៌មួយដែលច្បាប់បានផ្ដល់ឲ្យសន្តតិជនគ្រប់រូបទទួលបានដោយស្មើគ្នាមិនលម្អៀង។

យ៉ាងណាមិញ ប្រជាពលរដ្ឋភាគច្រើនមិនទាន់យល់ដឹងបានច្បាស់លាស់ និងគ្បោះក្បាយទៅលើសន្តតិជន និងលំដាប់នៃសន្តតិជនទេ ថាតើបុគ្គលជាប់ខ្សែស្រឡាយខាងណានៃមតកជន ទើបអាចក្លាយជាសន្តតិជនបាន។ ដោយសារមានតែញាតិលោហិតរបស់មតកជនប៉ុណ្ណោះទើបអាចក្លាយជាសន្តតិជន មិនមែនជាញាតិពន្ធនោះទេ។ លើសពីនេះ កូនរបស់មតកជនបង្កើតដែលកើតឡើងក្នុងចំណងអាពាហ៍ពិពាហ៍ ព្រមទាំងកូនស្មុំពេញលេញ ឬជាកូនស្មុំធម្មតាសុទ្ធតែអាចក្លាយជាសន្តតិជនបាន ឲ្យតែមានការទទួលស្គាល់ពីមតកជន។ លើសពីនេះចំពោះលំដាប់នៃសន្តតិជន ច្បាប់បានចាត់ទុកសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ចំណែកសន្តតិជនដទៃទៀតគឺត្រូវមានលំដាប់នីមួយៗក្នុងការទទួលបានចំណែកមត៌ក។ ក្នុងការបែងចែកមត៌ក សន្តតិជនមានសិទ្ធិក្នុងការបោះបង់ ឬយល់ព្រមទទួលយក។ ក្នុងករណីមានសហសន្តតិជនច្រើននាក់គឺទាមទារឲ្យមានការពិភាក្សាក្នុងការបែងចែកមត៌ក បើពុំនោះទេគឺត្រូវអនុវត្តតាមនីតិវិធីតុលាការដែលមានសមត្ថកិច្ច។

រួមសេចក្ដីមក ការសិក្សាទៅលើប្រធានបទ "**សន្តតិកម្មតាមច្បាប់**" គឺមានសារៈសំខាន់ណាស់សម្រាប់ការប្រើប្រាស់ចំណេះដឹងនេះក្នុងការអនុវត្តជាក់ស្ដែងនៅក្នុងសង្គមបច្ចុប្បន្ន ព្រមទាំងអាចកាត់បន្ថយនូវវិវាទណាមួយ ដែលអាចកើតឡើង និងពាក់ព័ន្ធនឹងការបែងចែកមត៌ក។ នេះក៏បានសបញ្ជាក់ពីភាពសុក្រិតភាពស្មើភាពគ្នាដែលច្បាប់បានយកមកអនុវត្ត នាំឲ្យមានការលើកកម្ពស់នៃការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាព និរន្តរភាព តម្លាភាពក្នុងប្រទេសកម្ពុជាជាស្ពាននាំមកនូវសុខសន្តិភាពក្នុងសង្គម។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ "**សន្តតិកម្មតាមច្បាប់**" រួចមកយើងសង្កេតឃើញថា មាត្រាទាំងឡាយដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ក្នុងគន្ថីទី៨ គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការយកមកអនុវត្តជាក់ស្តែង ក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន។ យ៉ាងណាមិញ សង្គមនឹងមានការផ្លាស់ប្តូរបរិបទនាពេលអនាគតយ៉ាងច្រើនទៅមុខទៀតដែលយើងនឹកស្មានមិនដល់ ជាហេតុដែលតម្រូវឲ្យមានការកែតម្រូវច្បាប់ និងបទបញ្ញត្តិនានាឲ្យមានភាពសមស្របនឹងការវិវត្តន៍របស់សង្គម។ ដោយហេតុថាប្រជាពលរដ្ឋនីមួយៗខិតខំរកចំណូលមិនមែនត្រឹមតែផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃនោះទេ តែក៏មានបំណងចង់បន្សល់ទុកជាទ្រព្យសម្បត្តិតឲ្យកូនចៅ។ នៅក្នុងសង្គមមិនថាសម័យកាលណាឡើយ ប្រជាជាពលរដ្ឋភាគច្រើនតែងប្រកាន់នូវគោលគំនិតមួយ គឺខិតខំរកដើម្បីបន្សល់ទុកដល់កូនចៅ ឬញាតិរបស់ខ្លួន ក្រោយពេលដែលខ្លួនទទួលមរណភាពផងដែរ។ ទន្ទឹមនឹងនេះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ក៏បានចែងអំពីលក្ខខណ្ឌដែលនាំឲ្យជនណាម្នាក់បាត់បង់នូវលក្ខណៈសម្បត្តិក្លាយជាសន្តតិជន និងការបែងចែងនូវចំណែកមត៌កទៅឲ្យសន្តតិជន ក៏ដូចជាសហសន្តតិជន។

សង្គមបច្ចុប្បន្នយើងសង្កេតឃើញថា ការអនុវត្តច្បាប់របស់ប្រជាពលរដ្ឋទូទៅនៅមានកង្វះខាតច្រើន ជាពិសេសការយល់ដឹងអំពីការបែងចែងទ្រព្យសម្បត្តិរបស់មតកជនដែលមិនបានបន្សល់បណ្តាំមត៌ក ដែលជាហេតុបង្កនូវជម្លោះដណ្តើមទ្រព្យសម្បត្តិក្នុងរង្វង់គ្រួសារ ដែលជាបញ្ហាប្រឈមមួយដ៏គួរឲ្យព្រួយបារម្ភ និងជាកត្តាមួយបណ្តាលឲ្យមានគំនុំគុំគួន ហើយក៏អាចឈានទៅដល់ការប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយ ចំពោះគ្នាទៅវិញទៅមកទៀតផង។ ដូច្នេះ ដើម្បីធ្វើឲ្យសន្តតិកម្មដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧នេះ កាន់តែមានលក្ខណៈទូលំទូលាយ និងមានភាពល្អប្រសើរក្នុងការយកទៅអនុវត្តនៅក្នុងសង្គម យើងទាំងអស់គ្នាត្រូវចូលរួមចំណែកក្នុងការផ្សព្វផ្សាយច្បាប់ឲ្យកាន់តែមានភាពទូលំទូលាយ។ ជាពិសេស ស្ថាប័នដែលពាក់ព័ន្ធនានា ត្រូវធ្វើការផ្សព្វផ្សាយ និងអប់រំដល់ប្រជាពលរដ្ឋនៅតាមតំបន់នានា អំពីបញ្ហាច្បាប់ទាក់ទងនឹងការទទួលបន្តនូវទ្រព្យសម្បត្តិរបស់មតកជនឲ្យកាន់តែច្បាស់។ ដោយហេតុថា សង្គមដែលមានការអភិវឌ្ឍគឺអាស្រ័យទៅលើចំណេះដឹង និងការចូលរួមអនុវត្តរបស់ប្រជាពលរដ្ឋគ្រប់រូប។ ម៉្យាងវិញទៀត ប្រជាពលរដ្ឋទៀតសោតក៏ត្រូវស្វែងយល់នូវព័ត៌មានផ្សេងៗទាក់ទងនឹងបញ្ញត្តិច្បាប់ ដើម្បីជាការយល់ដឹងមួយមុននឹងសម្រេចចិត្តធ្វើបណ្តឹងប្តឹងគ្នាទៅវិញទៅមក ជាពិសេសនៅក្នុងរង្វង់គ្រួសារ គួរតែមានការយោគយល់ និងការអធ្យាស្រ័យគ្នាជាមុនសិន។ ថ្វីត្បិតតែ អនុសាសន៍ខាងលើមានភាពមិនគ្រប់គ្រាន់ និងស៊ីជម្រៅក៏ដោយ ក៏វាអាចជាកត្តាមួយជួយជម្រុញដល់ការចូលរួមកាត់បន្ថយនូវវិវាទផ្សេងៗ ដែលអាចធ្វើឲ្យមានភាពសុខសាន្ត និងសុខដុមរមនានៅក្នុងសង្គមគ្រួសារ និងសង្គមជាតិផងដែរ។

# ឯកសារយោង

# ឯកសារយោង


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស, នស/រកម/០៥១០/០០៦, ០៥ មេសា ២០១០។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

ច្បាប់ស្តីពីអន្តោប្រវេសន៍, ២៦ សីហា ១៩៩៤។

អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិ, លេខ ១១២ អនក្រ.បក, ៣០ សីហា ២០១៨។

អនុក្រឹតស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០។

សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, បោះពុម្ពក្នុងខែមីនា ឆ្នាំ២០១២, ភាគ ៦។

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ២០១០, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*, ភាគ៦, គន្លឹទី៨-ទី៩, ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ២០០៩, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*, ភាគ១, គន្លឹទី១-ទី៣, ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

អេង សុត, *ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០*, បោះពុម្ពលើកទី១ ឆ្នាំ១៩៦៧, ក្រសួងយុត្តិធម៌។

អ៊ីវ ប៉ូលី, ១៥ មករា ២០១៨, "ការបែងចែកមត៌ក," (មេរៀនសម្រាប់ចែករំលែក, វិភាគទានច្បាប់)។ https://scrapbox.io/masaoikeda/%E1%9E%87%E1%9F%86%E1%9E%96%E1%9E%BC%E1%9E%80%E1%9E%91%E1%9E%B8_9_:_%E1%9E%93%E1%9E%B8%E1%9E%8F%E1%9E%B7%E1%9E%9F%E1%9E%93%E1%9F%92%E1%9E%8F%E1%9E%8F%E1%9E%B7%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤) ។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ..............................
ក្រុង ស្រុក ខណ្ឌ ..............................
ឃុំ សង្កាត់ ..............................

លេខ..............................
សៀវភៅមរណភាពលេខ..............................
ឆ្នាំ..............................

# សំបុត្រមរណភាព

| | | | |
|---|---|---|---|
| នាមត្រកូល | | | ភេទ |
| នាមខ្លួនសព | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួនសព | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស | | | |
| ស្ថានភាពសព<br>នៅលីវ មានប្ដី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ | | | |
| នាមត្រកូល និង នាមខ្លួនឪពុកសព | | | សញ្ជាតិ |
| ជាអក្សរឡាតាំង | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| នាមត្រកូល និង នាមខ្លួនម្ដាយសព | | | សញ្ជាតិ |
| ជាអក្សរឡាតាំង | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |

ធ្វើនៅ.................... ថ្ងៃទី......... ខែ......... ឆ្នាំ.........

មន្ត្រីអត្រានុកូលដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង រាជធានី(១) ----- -----
ស្រុក ខណ្ឌ (២) ----- -----
ឃុំ សង្កាត់ (៣) ----- -----

លេខ (៤)------ ---------------------
សៀវភៅអាពាហ៍ពិពាហ៍លេខ
ឆ្នាំ (៦)------- ---------------------

# សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល (៧) | | | |
| នាមខ្លួន (៨) | | | |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | | |
| | នាមខ្លួន | | |
| សញ្ជាតិ (១០) | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | | |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្ត ក្រុង ប្រទេស | | | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៦) | | | |
| **អំពីឪពុក ម្តាយ** | | **ខាងប្តី** | **ខាងប្រពន្ធ** |
| នាមត្រកូល និង នាមខ្លួនឪពុក (១៧) | | | |
| ជាអក្សរឡាតាំង (១៨) | | | |
| សញ្ជាតិ (១៩) | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | | |
| នាមត្រកូល និង នាមខ្លួនម្តាយ (២១) | | | |
| ជាអក្សរឡាតាំង (២២) | | | |
| សញ្ជាតិ (២៣) | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | | |

(២៥) ធ្វើនៅ.... .... ថ្ងៃទី ខែ ឆ្នាំ

(២៦) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២៧) *ហត្ថលេខា និងត្រា*

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

NATION RELIGION KING

# សៀវភៅគ្រួសារ

# FAMILY RECORD BOOK

នាមត្រកូល-នាមខ្លួន ______________________

SURNAME AND NAME ______________________

№ ____________

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត.....................................
ក្រុង ស្រុក ខណ្ឌ.....................................
ឃុំ សង្កាត់.....................................

លេខ .....................................
សៀវភៅកំណើតលេខ .....................................
ឆ្នាំ.....................................

# សំបុត្រកំណើត

| | | | |
|---|---|---|---|
| នាមត្រកូល | | | ភេទ |
| នាមខ្លួនទារក | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួនទារក | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស | | ..........................................<br>.......................................... | |

| ឪពុក ម្តាយទារក | ឪពុក | ម្តាយ |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស | ..........................................<br>.......................................... | ..........................................<br>.......................................... |
| ទីលំនៅពេលទារកកើត | | |

ធ្វើនៅ.................................ថ្ងៃទី.........ខែ............ឆ្នាំ..............

**មន្ត្រីអត្រានុកូលដ្ឋាន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

លេខ ៖ [redacted]

| | | | |
|---|---|---|---|
| រាជធានី/ខេត្ត | ៖ កែប | សន្លឹកផែនទីលេខ | ៖ [redacted] |
| ក្រុង/ស្រុក/ខណ្ឌ | ៖ កែប | លេខក្បាលដី | ៖ [redacted] |
| ឃុំ/សង្កាត់ | ៖ អូរក្រសារ | ទំហំ | ៖ [redacted] |
| ភូមិ | ៖ អូរក្រសារ | ប្រភេទដី | ៖ |
| | | រូបភាពប្រើប្រាស់ដី | ៖ កសិកម្ម |
| | | លក្ខណៈនៃការប្រើប្រាស់ដី | ៖ ឯកជន |




មាត្រដ្ឋាន 1/1400

[redacted]

ថ្ងៃ ព្រហស្បតិ៍ ៣ កើត ខែ ស្រាពណ៍ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅ កែប, ថ្ងៃទី ២២ ខែ សីហា ២០២៤

តប.រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

និម្មាបនិក.សុខ ពុទ្ធិម៉ាន់ឆ

ចំណាំ៖ [illegible]

No. [illegible]

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

គម្រូពាក្យសុំសម្រាប់ករណីសិក្សាទី១

## ពាក្យស្នើសុំឲ្យបែងចែកមត៌ក

**អ្នកដាក់ពាក្យសុំ** ៖ ឈ្មោះ **A** អាយុ ៤០ ឆ្នាំ មុខរបរពាណិជ្ជករ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "អ្នកដាក់ពាក្យសុំ[1]" ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវី.................. ដែលមានអាសយដ្ឋានស្ថិតនៅ...............មហាវិថី............... សង្កាត់.............. ខណ្ឌ......... រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ............។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវី.................[2]

**ភាគីម្ខាងទៀតនៃពាក្យសុំ** ៖ ឈ្មោះ **B** អាយុ ៤២ ឆ្នាំ មុខរបរពាណិជ្ជករ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ៣៥ ផ្លូវលេខ៦៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ[3]**

**ក**-ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ

១.អ្នកដាក់ពាក្យសុំធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។

---

[1] មានករណីមួយចំនួនដែលការពិភាក្សាលក្ខណៈសារធាតុរវាងសហសន្តតិជនបានធ្វើឡើងរួចរាល់ ប៉ុន្តែ ចំណុចនេះបង្ហាញតែអំពីឧទាហរណ៍ដែលមេធាវីបានដាក់ពាក្យសុំក្នុងនាមជាអ្នកតំណាងដោយអាណត្តិឲ្យសន្តតិជនតែម្នាក់គត់ក្នុងចំណោមសហសន្តតិជន។ ប្រសិនបើមេធាវីបានដាក់ពាក្យសុំក្នុងនាមតំណាងឲ្យសន្តតិជនច្រើននាក់ក្នុងចំណោមសហសន្តតិជន (រួមបញ្ចូលទាំងករណីដែលធ្វើការតំណាងឲ្យសន្តតិជនទាំងអស់ផងដែរ) នឹងធ្វើឲ្យមានការព្រួយបារម្ភណ៍អំពីភាពផ្ទុយគ្នានៃផលប្រយោជន៍ ហេតុនេះមេធាវីចាំបាច់ត្រូវតែពន្យល់ឲ្យបានច្បាស់លាស់អំពីចំនុចនេះទៅកាន់អតិថិជន និងត្រូវទទួលការយល់ព្រមពីអតិថិជនផងដែរ។ យ៉ាងណាមិញ គេគិតថា វិធីដែលសន្តតិជនណាម្នាក់ក្នុងចំណោមសហសន្តតិជនតំណាងឲ្យសហសន្តតិជនផ្សេងទៀត ហើយបានដាក់ពាក្យសុំ នឹងធ្វើឲ្យមានការព្រួយបារម្ភថាខ្វះការធានាចំពោះនីតិវិធីសម្រាប់សហសន្តតិជនផ្សេងទៀត ហើយពួកគេនឹងមិនពេញចិត្ត។

[2]មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ទោះបីជាមិនដាក់ពីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ក៏ជាទូទៅគឺត្រូវធ្វើការបញ្ជូនទៅការិយាល័យមេធាវីនៃបណ្តឹង។ ប៉ុន្តែ ដើម្បីឲ្យមានភាពច្បាស់លាស់ពីទីកន្លែងដែលត្រូវបញ្ជូន វាជាការល្អដែលដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។ ជាពិសេស ក្នុងករណីដែលមានមេធាវីច្រើនធ្វើជាអ្នកតំណាងរបស់ដើមចោទ នោះដើម្បីឲ្យមានភាពច្បាស់លាស់ក្នុងការបញ្ជូនទៅការិយាល័យមេធាវីណាមួយ នោះត្រូវដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។

[3]តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃទីកន្លែងចាប់ផ្តើមសន្តតិកម្ម (តារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។ ហើយទីកន្លែងចាប់ផ្តើមសន្តតិកម្ម គឺជាអាសយដ្ឋាននៅពេលមរណភាពរបស់មតកជន (ក្រមរដ្ឋប្បវេណីមាត្រា១១៩៦)។

២.ភាគីម្ខាងទៀត......ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ២ ស្តីពីមត៌ក និងសាច់ប្រាក់ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ៣ស្តីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ ។

**ខ-អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

១.មតកជន...... បានទទួលមរណភាពនៅថ្ងៃទី......ខែ......ឆ្នាំ...... ហើយមត៌កដែលដឹងច្បាស់នាពេលបច្ចុប្បន្ន មានដូចទៅនឹងការសរសេរនៅក្នុងបញ្ជីសារពើភ័ណ្ឌស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ (តទៅនេះហៅថា "មត៌កនៃរឿងក្តីនេះ")។

២.នៅពេលទទួលមរណភាព មតកជន.............មានប្រពន្ធ..............ហើយរវាងមតកជន និងប្រពន្ធ.......នោះ មានកូន..........១នាក់។ មតកជនមិនមានកូនផ្សេងទៀតទេ។ មតកជន......មិនបានបន្សល់ទុកមតកសាសន៍ឡើយ[4]។

៣.សន្តតិជនរបស់មតកជនដែលជាអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានពិភាក្សាគ្នាអំពីការបែងចែកមត៌កនៃរឿងក្តីនេះ។ ជាលទ្ធផលនៃការពិភាក្សា ភាគីម្ខាងទៀតមានផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនរួចទៅហើយ ប៉ុន្តែ ដោយសារតែគាត់មានអាយុច្រើន និង មិនមានប្រាក់ចំណូល ដូច្នេះ គាត់ត្រូវការចាំបាច់នូវសាច់ប្រាក់និង ប្រាក់បញ្ញើក្នុងធនាគារ សម្រាប់ជីវភាពរបស់គាត់ក្នុងពេលខាងមុខ។ ចំណែកឯអ្នកដាក់ពាក្យសុំវិញ គឺជាបុគ្គលិកក្រុមហ៊ុនដែលមានប្រាក់ចំណូល ប៉ុន្តែ គាត់មិនទាន់មានផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួននៅឡើយទេ ដូច្នេះហើយ អ្នកដាក់ពាក្យសុំ ត្រូវធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ ហើយភាគីម្ខាងទៀតត្រូវធ្វើលទ្ធកម្មនូវសាច់ប្រាក់ និងប្រាក់បញ្ញើក្នុងធនាគារដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ២ និង ៣ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។ បន្ថែមពីនេះទៀត តម្លៃទីផ្សារនៃអចលនវត្ថុ ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ គឺប្រហែល......ដុល្លារ ហើយ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃនៃការបូកសរុបប្រាក់បញ្ញើនៅក្នុងធនាគារ និងសាច់ប្រាក់សុទ្ធដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ២ និង ៣ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។ ដូចនេះ នៅថ្ងៃទី......ខែ.......ឆ្នាំ២០១៧ ភាគីទាំង២ បានបង្កើត[5]នូវការព្រមព្រៀងដូចមាននៅក្នុងការសរសេរនៃចំណុចទី១ ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ។

៤.អាស្រ័យហេតុនេះ អ្នកដាក់ពាក្យសុំសូមឲ្យតុលាការចេញដីកាសម្រេចតាមការសរសេរនៅក្នុងចំណុចទី១ ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ ចំពោះពាក្យសុំនៃរឿងក្តីនេះ។

---

[4] បើសិនជាមានមតកសាសន៍ ករណីនេះនឹងក្លាយជាសន្តតិកម្មអនុវត្តតាមមតកសាសន៍ (សន្តតិកម្មតាមមតកសាសន៍)(ក្រមរដ្ឋប្បវេណី មាត្រា ១១៩៥ និង ចាប់ពីមាត្រា ១១៦៨)។

[5] ដើម្បីឲ្យតុលាការចេញដីកាសម្រេចទៅតាមខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ តើរវាងសហសន្តតិជនបានបង្កើតនូវការព្រមព្រៀងពិតប្រាកដដែរឬទេ? (តើសហសន្តតិជនទាំងអស់បានយល់ព្រមតាមការបែងចែកដូចនៅក្នុងខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញដែរឬទេ?)គឺជាចំណុចសំខាន់។ ដូច្នេះហើយ ត្រង់ចំណុចនេះ គួរតែមានការពន្យល់អំពីមូលហេតុលម្អិត ថាតើហេតុអ្វីបានជាបែងចែកតាមវិធីបែបនេះ?

**គ.ភស្តុតាងជាឯកសារ**[6]

១.សំបុត្រមរណភាពរបស់មតកជន

២.សំបុត្រកំណើតរបស់អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត

៣.ច្បាប់ចម្លងនៃសៀវភៅគ្រួសារ

៤.ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ

៥.លិខិតបញ្ជាក់ប្រាក់ដែលនៅសល់ក្នុងគណនីប្រាក់បញ្ញើ

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨

**អ្នកតំណាងដោយអាណត្តិ**

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-លិខិតបញ្ជាក់អះអាងអំពីតម្លៃដី "ចំនួន ០២ ច្បាប់"

**P**

[6] ចំពោះឯកសារបញ្ជាក់ដំបូង ចាំបាច់ត្រូវតែដាក់ឯកសារដែលចាំបាច់ និងគ្រប់គ្រាន់ទៅតុលាការ ដើម្បីឲ្យតុលាការទទួលស្គាល់នូវខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ប៉ុន្តែដំណើរការនៃការព្រមព្រៀងទាក់ទងនឹងវិធីបែងចែកមតិកជាដើម អំពីចំណុចដែលមិនមានឯកសារត្រឹមត្រូវ នឹងក្លាយជាការពន្យល់នៅក្នុងការសួរជំនួសនៅតុលាការ (ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមាត្រា ២៨ កថាខណ្ឌទី២) ។

## បញ្ជីសារពើភ័ណ្ឌស្តីពីមតិក[7]

១.អចលនវត្ថុ[8]

ទីតាំងស្ថិតនៅ ៖ ភូមិ...... សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

លេខវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ៖

លេខក្បាលដី ៖

កម្មសិទ្ធិករ ៖ ឈ្មោះ និង អាសយដ្ឋាន

អាគារដែលជាសមាសភាពនៃដីខាងលើ

២.ប្រាក់បញ្ញើក្នុងធនាគារ[9]

ធនាគារ ៖ ប្រទេសកម្ពុជា ធនាគារពាណិជ្ជទី១

សាខា ៖ សាខាតាមដងមហាវិថីព្រះមុន្នីវង្ស

លេខគណនីធនាគារ ៖

ឈ្មោះម្ចាស់គណនី ៖

៣.សាច់ប្រាក់ ៖ (អ្នកថែរក្សាគ្រប់គ្រង)[10]

ប្រាក់......រៀល

---

[7] បញ្ជីសារពើភ័ណ្ឌនៃមតិក ត្រូវសរសេរខ្លឹមសារដែលអាចឲ្យតុលាការយកមកប្រើប្រាស់ក្នុងដីកាសម្រេចបានតែម្តង។

[8] អចលនវត្ថុ ចាំបាច់ត្រូវធ្វើនូវបញ្ជីសារពើភ័ណ្ឌដែលមានទម្រង់ ឬ ខ្លឹមសារដែលអាចយកទៅធ្វើការចុះបញ្ជីបាន។

[9] ប្រាក់បញ្ញើក្នុងធនាគារ ចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពីខ្លឹមសារនៃប្រាក់បញ្ញើ ដើម្បីអាចតតាំងដោយភាពត្រឹមត្រូវជាមួយនឹងធនាគារ (ក្រមរដ្ឋប្បវេណី១២៧៥ កថាខណ្ឌទី១)។

[10] សាច់ប្រាក់ភាគច្រើនត្រូវកំណត់ដោយដាក់ឈ្មោះរបស់អ្នកថែរក្សាគ្រប់គ្រង ដោយសារតែវាមានភាពពិបាកក្នុងការកំណត់។